# ចំណាកស្រុកដើម្បីការងារ របស់ប្រទេសកម្ពុជា

## ការវិភាគអំពីក្របខ័ណ្ឌគតិយុត្ត

ខែមេសា ឆ្នាំ២០១១

USAID
FROM THE AMERICAN PEOPLE

The Asia Foundation

# ចំណាកស្រុកដើម្បីការងារ របស់ប្រទេសកម្ពុជា
# ការវិភាគអំពីក្របខ័ណ្ឌគតិយុត្ត
## ខែមេសា ឆ្នាំ២០១១


**សេចក្តីថ្លែងអំណរគុណ**

ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយរបាយការណ៍នេះ អាចធ្វើទៅបានដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារ សហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈអង្គការ មូលនិធិអាស៊ី (“TAF”) ។ សូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ ចំពោះ Jenna Holliday សម្រាប់ការសរសេររបាយការណ៍នេះ ។ ជាមួយគ្នានេះ យើងក៏សូមថ្លែងអំណរគុណផងដែរ ចំពោះអង្គការដៃគូដូចតទៅនេះ ដែលបានចូលរួមវិភាគទាន និងផ្តល់យោបល់ដ៏មានតម្លៃ : អង្គការ ចាប់ដៃ អង្គការសម្របសម្រួលសកម្មភាពស្រាវជ្រាវស្តីពីជំងឺអេដស៍ និងការបម្លាស់ទី (CARAM) វិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចិម (EWMI) បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) អង្គការពលកម្មអន្តរជាតិ (ILO) អង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) អង្គការគាំទ្រផ្នែកច្បាប់សម្រាប់ កុមារ និងស្ត្រី (LSCW) អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO), SISHA, ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) គម្រោងអន្តរ-ទីភ្នាក់ងារអង្គការ សហប្រជាជាតិប្រឆាំងការជួញដូរមនុស្ស (UNIAP) និងអង្គភាពសហប្រជាជាតិដើម្បីសមភាពយេនឌ័រ និងការពង្រឹងអំណាចស្ត្រី (UN Women) ។

មតិយោបល់ ការរកឃើញ និងសេចក្តីសន្និដ្ឋាន ដែលថ្លែងនៅក្នុងរបាយការណ៍នេះ គឺជាមតិយោបល់ ការរកឃើញ និងសេចក្តីសន្និដ្ឋានរបស់អ្នកសរសេររបាយការណ៍នេះ និងមិនឆ្លុះបញ្ចាំងអំពីមតិយោបល់របស់ USAID មូលនិធិអាស៊ី ឬម្ចាស់ជំនួយអ្នកឧបត្ថម្ភ ឬដៃគូដទៃទៀតឡើយ ។


**សំណួរ និងមតិកែលម្អ**

ប្រសិនបើលោកអ្នកមានសំណួរណាមួយ ឬត្រូវការព័ត៌មានបន្ថែមណាមួយអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់មតិកែលម្អណាមួយ សូមអញ្ជើញទាក់ទងតាមអ៊ីម៉ែល : annaolsen@asiafound.org ។


© ២០១១ អង្គការ មូលនិធិអាស៊ី



ផ្ទះលេខ ៥៩ ផ្លូវឧកញ៉ាពេជ្រ (ផ្លូវ ២៤២)

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## មាតិកា


**និយមន័យ/អក្សរកាត់**............ ៣

**សេចក្ដីសង្ខេប**............ ៥

**១. សេចក្ដីផ្ដើម**............ ១០

**២. ការផ្ដល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករ** (RAs)............ ១៣

រឿងទី១ របស់ សុភាព............ ១

**៣. ការចុះកិច្ចសន្យាជាមួយពលករ/ការជ្រើសរើសពលករ**............ ១៨

រឿងទី២ របស់ សុភាព............ ១

រឿងទី១ របស់ សំនៀង............ ១

រឿងទី៣ របស់ សុភាព............ ១

**៤. ការបណ្ដុះបណ្ដាល/ការស្នាក់អាស្រ័យ/ការដឹកជញ្ជូន**............ ៣០

រឿងទី២ របស់ សំនៀង............ ១

**៥. ការឆ្លងកាត់/ការមកដល់ក្នុងប្រទេសទទួល**............ ៣៦

**៦. លក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល**............ ៤១

រឿងទី៤ របស់ សុភាព............ ១

រឿងទី៣ របស់ សំនៀង............ ១

**៧. ការធ្វើមាតុភូមិនិវត្តន៍មកកម្ពុជា**............ ៥០

រឿងទី៤ របស់ សំនៀង............ ១

**៨. បណ្ដឹង : នីតិវិធី/ដំណោះស្រាយតាមផ្លូវច្បាប់**............ ៥៦

**៩. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**............ ៦០

**១០. ក្របខ័ណ្ឌគតិយុត្ត : ដ្យាក្រាម និងតារាងច្បាប់**............ ៦៤

**ឯកសារយោង**............ ៧១

**ឧបសម្ព័ន្ធ**............ ៧៧

ឧបសម្ព័ន្ធ ក : សេចក្ដីសង្ខេបអំពីច្បាប់ជាតិ តំបន់ និងអន្តរជាតិដែលពាក់ព័ន្ធនឹងចំណាកស្រុកដើម្បីការងារ............ ៧៧

## និយមន័យ/អក្សរកាត់

និយមន័យ និងអក្សរកាត់ខាងក្រោមនេះ ត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ និងរៀបតាមលំដាប់លំដោយអក្ខរាវិរុទ្ធ :

| | |
|---|---|
| ACRA | សមាគមភ្នាក់ងារជ្រើសរើសពលករកម្ពុជា |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( អាស៊ាន) |
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ( អាដហុក) |
| CARAM | អង្គការ សម្របសម្រួលសកម្មភាពស្រាវជ្រាវស្តីពីជំងឺអេដស៍ និងការបម្លាស់ទី |
| CEDAW | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី |
| CMW | អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការការពារសិទ្ធិពលករចំណាកស្រុកគ្រប់រូប និង សមាជិកគ្រួសាររបស់ពួកគេ |
| COMMIT | គំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់ក្រសួងប្រចាំតំបន់ទន្លេមេគង្គប្រឆាំងអំពើជួញដូរ |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| CRC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| GMS | មហាអនុតំបន់ទន្លេមេគង្គ |
| HRW | អង្គការឃ្លាំមើលសិទ្ធិមនុស្ស |
| ICCPR | អនុសញ្ញាអន្តរជាតិនៃអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IOM | អង្គការទេសន្តប្រវេសន៍អន្តរជាតិ |
| LSHTSE | ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |

| | |
|---|---|
| NPA | ផែនការសកម្មភាពជាតិរបស់កម្ពុជា |
| ពិធីសារ Palermo | ពិធីសារអង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញា Palermo |
| RA | ទីភ្នាក់ងារជ្រើសរើសពលករ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| TIP | អំពើជួញដូរមនុស្ស |
| UNIAP | គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិ ប្រឆាំងការជួញដូរមនុស្ស នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ |

## សេចក្តីសង្ខេប

### *ផ្នែកទី១ : សេចក្តីផ្តើម*

រាជរដ្ឋាភិបាលកម្ពុជា (“RGC”) បន្តរៀបចំតាក់តែងគោលនយោបាយស្តីពីការធ្វើចំណាកស្រុក (ទេសន្តប្រវេសន៍) នៃកម្លាំងពលកម្មកម្ពុជាទៅក្រៅប្រទេស ជាមធ្យោបាយមួយដើម្បីបង្កើនកំណើនសេដ្ឋកិច្ចក្នុងស្រុក និងប្រយុទ្ធប្រឆាំងនឹងភាពអត់ការងារធ្វើ ។ គោលដៅសំខាន់ៗសម្រាប់ពលករកម្ពុជា រួមមាន ប្រទេសកូរ៉េខាងត្បូង ម៉ាឡេស៊ី និងព្រះរាជាណាចក្រថៃ ។ ខណៈដែលចំណាកស្រុកប្រក្រតីដើម្បីការងារកើនឡើង ចំណាកស្រុកមិនប្រក្រតី និងខុសច្បាប់ក៏កើនឡើងដែរ[១] ។ របាយការណ៍នេះ ផ្តោតសំខាន់ទៅលើការធ្វើចំណាកស្រុករបស់ស្ត្រីកម្ពុជាទៅកាន់ប្រទេសម៉ាឡេស៊ី (ដើម្បីធ្វើការងារជាអ្នកបម្រើតាមផ្ទះ) និងការធ្វើចំណាកស្រុករបស់បុរសកម្ពុជាទៅកាន់ប្រទេសថៃ (ដើម្បីធ្វើការក្នុងវិស័យកសិកម្ម) ដោយធ្វើការវិភាគទៅលើវិធានទាំងឡាយដែលគ្រប់គ្រងការធ្វើចំណាកស្រុកប្រក្រតី និងកំណត់អំពីច្បាប់ដែលអាចប្រើប្រាស់ដើម្បីការពារជនរងគ្រោះនៃការធ្វើចំណាកស្រុកមិនប្រក្រតី និងដែលអាចប្រើប្រាស់ប្រឆាំងនឹងជនដែលប្រព្រឹត្តល្មើស និងទទួលបានផលចំណេញពីសកម្មភាពនេះ ។ រឿងរ៉ាវរបស់សំនៀង (បុរសខ្មែរម្នាក់ដែលបានធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃ) និង សុភាព (ស្ត្រីខ្មែរដែលត្រូវបានជ្រើសរើសឱ្យទៅធ្វើការងារនៅប្រទេសម៉ាឡេស៊ី) ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីដំណើរការខុសៗគ្នានៃការធ្វើចំណាកស្រុកដើម្បីការងារ និងលក្ខណៈដែលច្បាប់ពាក់ព័ន្ធអាចយកទៅអនុវត្តនៅក្នុងបរិបទទាំងនេះ ។ តួអង្គទាំងនេះត្រូវបានបង្កើតឡើងដើម្បីបម្រើគោលបំណងនៃរបាយការណ៍នេះ និងផ្អែកតាមបទពិសោធន៍របស់ពលករចំណាកស្រុកពិតប្រាកដ ប៉ុន្តែមិនមែនសំដៅលើបុគ្គលជាក់លាក់ណាមួយឡើយ ។

### *ផ្នែកទី២ : ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករ (RAs)*

នៅក្នុងផ្នែកទី២ លក្ខខណ្ឌតម្រូវសម្រាប់ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករ (RAs) ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ត្រូវបានពិចារណា ។ អនុក្រឹត្យលេខ៥៧ (ស្តីពីការនាំពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស ឆ្នាំ១៩៩៥) គឺជាប្រភពចម្បងសម្រាប់លក្ខខណ្ឌតម្រូវនានានៃការផ្តល់អាជ្ញាប័ណ្ណ ។ ផ្នែកនេះ ក៏ធ្វើសេចក្តីសន្និដ្ឋានផងដែរថា ជាការសមហេតុផលក្នុងការនិយាយថា មេខ្យល់ដែលជួលដោយ ឬធ្វើការនៅក្រោមការគាំទ្រពីទីភ្នាក់ងារជ្រើសរើសពលករ (RA) បង្កើតជាទំនួលខុសត្រូវស៊ីវិលនៅក្រោមអាជ្ញាប័ណ្ណរបស់ RA (ក្នុងករណីដែលមេខ្យល់នោះគ្មានអាជ្ញាប័ណ្ណដើម្បី ធ្វើការងារដោយឯករាជ្យ) និងថា ក្នុងករណីណាក៏ដោយ នៅពេលដែលបទល្មើសមួយត្រូវបានប្រព្រឹត្តដោយមេខ្យល់ ទំនួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌនឹងធ្លាក់ទៅលើទាំងមេខ្យល់ម្នាក់ៗ និងទាំង RA ។

### *ផ្នែកទី៣ : ការធ្វើកិច្ចសន្យាជាមួយ/ការជ្រើសរើសពលករ*

---

[១] មាត្រា ៥(ក) អនុសញ្ញាអន្តរជាតិស្តីពីពលករចំណាកស្រុក : ពលករប្រក្រតីត្រូវបាន“ចាត់ទុកថា មានឯកសារត្រឹមត្រូវ ឬស្ថិតក្នុងស្ថានភាពប្រក្រតី ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឱ្យចូលស្នាក់នៅ និងធ្វើសកម្មភាពការងារដែលទទួលបានប្រាក់ឈ្នួល នៅក្នុងរដ្ឋដែលផ្តល់ការងារ ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងកិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋនោះក៏ជាភាគីមួយដែរ” ។

ផ្នែកនេះត្រូវបានចែកជាពីរភាគដាច់ដោយឡែកពីគ្នា ដោយភាគទី១ ផ្តោតទៅលើច្បាប់នានាដែលពាក់ព័ន្ធការធ្វើកិច្ចសន្យាជាមួយ និងការជ្រើសរើសពលករចំណាកស្រុកប្រក្រតី តាមរយៈ RA ដែលមានអាជ្ញាប័ណ្ណ (ទោះយ៉ាងណា ករណីសិក្សានៃរបាយការណ៍នេះ ក៏ពិនិត្យលើប្រធានបទនេះដែរ ដោយផ្តោតបន្ថែមលើការជ្រើសរើសពលករក្រោមអាយុ) ។ ផ្នែកទី៣ ភាគទី១ សន្និដ្ឋានថា ក្នុងករណីដែលកិច្ចសន្យាត្រូវបានធ្វើឡើងដោយផ្អែកតាមការសន្មតខុសច្បាប់ ឧ. ក្នុងករណីដែលពលករមិនទាន់គ្រប់អាយុ ១៨ឆ្នាំ (តាមលក្ខខណ្ឌតម្រូវនៃអនុក្រឹត្យលេខ ៥៧) កិច្ចសន្យានេះអាចចាត់ទុកជាមោឃៈចាប់តាំងពីដើមទីទៅ (ក្រោមអនុក្រឹត្យលេខ៣៨ ចែងពីច្បាប់ស្តីពីកិច្ចសន្យា និងសំណងផ្សេងៗ ឆ្នាំ១៩៨៨) ។ ជាមួយគ្នានេះ ក៏មានការវែកញែកផ្សេងទៀតផងដែរ ដែលអាចជួយដល់ពលករក្នុងការធ្វើមោឃភាពលក្ខខណ្ឌកិច្ចសន្យាដែលខុសច្បាប់ ក្លែងបន្លំ ឬមិនអាចធ្វើទៅបាន ក្នុងនោះរាប់បញ្ចូលទាំងការវែកញែកហេតុផលថាបញ្ញត្តិនៃកិច្ចសន្យាដែលភ្ជាប់កាតព្វកិច្ចឱ្យជនណាម្នាក់ស្ថិតក្នុងការបង្ខាំង គួរតែចាត់ទុកថាខុសច្បាប់ និងមោឃៈ ។ មាត្រា ៣ នៃអនុក្រឹត្យលេខ ៥៧ ចែងថា បេក្ខជនសម្រាប់ការទៅធ្វើការងារនៅក្រៅប្រទេសគ្រប់រូប ត្រូវតែមានអាយុ ១៨ឆ្នាំឡើងទៅ ។ ក្នុងកាលៈទេសៈដែលអនីតិជនត្រូវបាននាំយកចេញពីអាណាព្យាបាលភាពស្របច្បាប់ (ដោយ RA ឬមេខ្យល់) ដោយគ្មានហេតុផលសំអាងផ្អែកច្បាប់ ឬក្នុងលក្ខណៈមួយដែលត្រូវបានចាត់ទុកថាខុសច្បាប់ ជនល្មើសអាចនឹងត្រូវទទួលទោសពីបទចោទប្រកាន់ព្រហ្មទណ្ឌ នៅក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (ឆ្នាំ២០០៨) (LSHTSE) ឬក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ។

ភាគទីពីរនៃផ្នែកទី៣នេះ ពិចារណាទៅលើរឿងរ៉ាវរបស់ សំនៀង និងពិចារណាទៅលើចំណុចដែលពលករចំណាកស្រុកមិនប្រក្រតីដោយស្ម័គ្រចិត្ត និងខុសច្បាប់អាចត្រូវបានចាត់ទុកថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស (TIP) ដោយធ្វើសន្និដ្ឋានថា ការដឹង និងចេតនារបស់ពលករក្នុងការចូលរួមក្នុងកម្លាំងពលកម្មចំណាកស្រុកមិនប្រក្រតី មិនរារាំងពួកគេមិនឱ្យស្វែងរកការផ្តន្ទាទោសជនល្មើសពីបទជួញដូរមនុស្សឡើយ នៅពេលដែលការកេងប្រវ័ញ្ចកើតឡើងជាក់ច្បាស់នៅពេលក្រោយមកទៀតណាមួយ ។ មាត្រាដែលពាក់ព័ន្ធនៃ LSHTSE ត្រូវបានពិចារណានៅក្នុងផ្នែកនេះ ។

### *ផ្នែកទី៤ : ការបណ្តុះបណ្តាល/ការស្នាក់អាស្រ័យ/ការដឹកជញ្ជូន*

ផ្នែកទី៥ ពិចារណាទៅលើច្បាប់នានាដែលអនុវត្តចំពោះការបណ្តុះបណ្តាល ការស្នាក់អាស្រ័យ និងការដឹកជញ្ជូនពលករចំណាកស្រុកប្រក្រត្រី និងមិនប្រក្រតី ។ ផ្នែកនេះរៀបរាប់អំពីបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ៥៧ និងប្រកាសលេខ ១០៨ (ឆ្នាំ២០០៦) ដែលចែងថា RA ត្រូវទទួលខុសត្រូវលើការបណ្តុះបណ្តាលពលករអំពីប្រព័ន្ធការងារ ទំនៀមទម្លាប់ប្រពៃណី និងច្បាប់ជាមូលដ្ឋានរបស់ប្រទេសដែលពួកគេនឹងទៅបម្រើការងារ ព្រមទាំងបញ្ហាសុខភាព ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិការងារ ។ ផ្នែកនេះក៏បង្ហាញផងដែរថា ក្នុងករណីដែលពលករត្រូវបានរឹតត្បិតសេរីភាពក្នុងការដើរហើរ (ឧទាហរណ៍ ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល) ជនល្មើសដែលប្រព្រឹត្តអំពើរឹតត្បិតនោះ អាចមានទោសពីបទបង្ខាំងមនុស្សដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ។ ជាងនេះទៅទៀត និងនៅក្នុងករណីរបស់ សំនៀង ច្បាប់ LSHTSE ផ្តន្ទាទោសអំពីការផ្តល់ជម្រក ឬដឹកជញ្ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្ស ។ ដូច្នេះ ក្នុងករណីដែលម្ចាស់ផ្ទះសំណាក់ ឬអ្នកបើកបរ អាចត្រូវបានបង្ហាញភ័ស្តុតាងឱ្យឃើញថា បានដឹងអំពីភាពត្រូវបានគេជួញដូររបស់ពលករ ឬការងារដែលមានភាពកេងប្រវ័ញ្ចនៅពេលចុងក្រោយ ពួកគេអាចនឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ។

### *ផ្នែកទី៥ : ការឆ្លងកាត់/ការមកដល់ប្រទេសទទួល*

ផ្នែកនេះ កំណត់អំពីច្បាប់ព្រហ្មទណ្ឌនានាដែលអាចអនុវត្តនៅក្នុងករណីដែលពលករធ្វើចំណាកស្រុកដោយប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ ឬលិខិតឆ្លងដែនដែលទទួលបានដោយការបន្លំ ។ ផ្នែកនេះក៏ពិនិត្យផងដែរទៅលើច្បាប់ក្នុងស្រុក និងច្បាប់នៅក្នុងប្រទេសទទួល ដែលចែងអំពីក្របខ័ណ្ឌសម្រាប់ការធ្វើចំណាកស្រុកដើម្បីការងារ ឧ. អនុក្រឹត្យលេខ៣៩ (ឆ្នាំ ២០០៩) ដែលចែងថា ពលករចំណាកស្រុកគ្រប់រូបមានសិទ្ធិទទួលបានលិខិតឆ្លងដែនឆាប់រហ័ស ។ សូម្បីតែមានឯកសារត្រឹមត្រូវក្តី ពលករចំណាកស្រុកជាច្រើនជ្រើសរើសវិធីធ្វើចំណាកស្រុកមិនប្រក្រតី ដើម្បីជៀសវាងថ្លៃចំណាយដែលពាក់ព័ន្ធនឹងច្រកផ្លូវការ ។ ប៉ុន្តែ នៅទីបំផុត ចំពោះពលករចំណាកស្រុកទាំងឡាយដែលបានធ្វើដំណើរតាមមធ្យោបាយមិនប្រក្រតី និង/ឬ ពលករចំណាកស្រុកដែលមានឯកសារមិនស្របច្បាប់ ពួកគេនឹងទៅដល់ប្រទេសទទួលដោយខុសនឹងច្បាប់អន្តោប្រវេសន៍ ។ ប្រការនេះអាចបណ្តាលឱ្យមានការចាប់ឃុំខ្លួន និងដាក់ទោសទណ្ឌ (ដែលអាចរួមបញ្ចូលទាំងការវាយនឹងរំពាត់នៅក្នុងប្រទេសម៉ាឡេស៊ី) ព្រមទាំងការនិរទេស (ដោយជារឿយៗ ភាគីដែលត្រូវចាប់ខ្លួននឹងត្រូវចេញសោហ៊ុយចំណាយដោយខ្លួនឯង) ។

### *ផ្នែកទី៦ : លក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល*

ផ្នែកទី៦ ពិចារណាទៅលើលក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល ជាពិសេស ដោយសារតែច្បាប់ការងាររបស់កម្ពុជា (ឆ្នាំ១៩៩៧) មិនអនុវត្តចំពោះអ្នកបម្រើការងារតាមផ្ទះ ឬការពារពលករចំណាកស្រុកឡើយ ។ អនុក្រឹត្យលេខ ៥៧ ចែងអំពីលក្ខខណ្ឌមួយចំនួន ដែលគួរដាក់បញ្ចូលនៅក្នុងកិច្ចសន្យាការងារ ប៉ុន្តែ មានបទដ្ឋានអប្បបរមាតិចតួចណាស់ដែលត្រូវបានអនុវត្ត និងការតាមដានតិចតួចទៅលើលក្ខខណ្ឌនៅក្នុងប្រទេសទទួល ។ ផ្នែកនេះ បន្តពិចារណាថា អាចមានបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌ ដែលពលករអាចធ្វើឡើងប្រឆាំងនឹង RA ក្នុងករណីដែលលក្ខខណ្ឌការងារនៅក្នុងប្រទេសទទួលមានកម្រិតទាបជាងលក្ខខណ្ឌដែលធានាអះអាងដោយ RA និងក្នុងករណីដែលមានភ័ស្តុតាងបញ្ជាក់ថា RA បានដឹងអំពីលក្ខខណ្ឌជាក់ស្តែងទាំងនោះ ។

### *ផ្នែកទី៧ : ការធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសកម្ពុជា*

ផ្នែកទី៧ ពិនិត្យទៅលើការធ្វើមាតុភូមិនិវត្តន៍ពលករមកកាន់ប្រទេសកម្ពុជា ដោយពិចារណាសំខាន់ទៅលើអ្នកណាដែលមានកាតព្វកិច្ចចេញសោហ៊ុយសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ក្នុងស្ថានភាពខុសៗគ្នា ។ ក្នុងករណីចំណាកស្រុកប្រក្រតី RA ជូនដំណឹងដល់ MoLVT រយៈពេល ៤៥ថ្ងៃនៅមុនពេលពលករត្រូវវិលត្រឡប់មកវិញ ហើយថ្លៃចំណាយត្រូវរ៉ាប់រងដោយ RA ឬនិយោជក (ប៉ុន្តែ នៅទីបំផុត ត្រូវកាត់ពីប្រាក់ឈ្នួលរបស់ពលករ) ។ ទោះជាយ៉ាងនេះក្តី មិនថា ពលករបានចាប់ផ្តើមតាមផ្លូវមិនប្រក្រតី ឬចាកចេញពីការងារប្រក្រតី (ដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត) នោះទេ គេឃើញមានពលករដែលគ្មានឯកសារមួយចំនួនធំ ត្រូវបានចាប់ឃុំខ្លួនជាអន្តោប្រវេសន៍ខុសច្បាប់ នៅក្រោមច្បាប់របស់ប្រទេសទទួល ។ កិច្ចប្រឹងប្រែងតិចតួចត្រូវបានធ្វើឡើង ដើម្បីកំណត់អត្តសញ្ញាណពលករគ្មានឯកសារ ដែលជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ហើយទោះបីជាមានការប្តេជ្ញាចិត្តក្នុងស្រុក និងនៅកម្រិតទ្វេភាគីកើនឡើងដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរមនុស្សក៏ដោយ ក៏ភាគច្រើននៃការប្តេជ្ញាចិត្តទាំងនោះជួយតែស្ត្រី និងកុមារ ដែលត្រូវបានកំណត់យ៉ាងទូលំទូលាយថាជាជនរងគ្រោះដែលងាយរងគ្រោះបំផុត ។

### ផ្នែកទី៨ : បណ្តឹង : នីតិវិធី/ដំណោះស្រាយផ្លូវច្បាប់

ផ្នែកទី៨ ពិចារណាទៅលើផ្លូវផ្សេងៗដែលបណ្តឹងមួយអាចនឹងឆ្លងកាត់ ក្នុងនោះរាប់បញ្ចូលទាំងបណ្តឹងទាមទារសំណងពីប្រាក់ធានា ១០០.០០០ដុល្លារសហរដ្ឋអាមេរិក នៅក្រោមអនុក្រឹត្យលេខ ៥៧ ។ ផ្នែកនេះ ក៏ពិចារណាទៅលើការពិតដែលថា ពលករជាច្រើនដែលមានបណ្តឹងត្រឹមត្រូវតាមច្បាប់ ត្រូវបានបញ្ចុះបញ្ចូលមិនឱ្យដាក់ពាក្យបណ្តឹង (ទោះជាបណ្តឹងព្រហ្មទណ្ឌក្តី ឬបណ្តឹងរដ្ឋប្បវេណីក្តី) ដោយសារតែ RA ទាញហេតុផលថា ពលករ (ឬគ្រួសាររបស់ពួកគេ) បានដឹង ឬផ្សំគំនិតនៅក្នុងសមាសភាគនៃភាពមិនប្រក្រតី ឧ. ផ្តល់ឯកសារអត្តសញ្ញាណក្លែងក្លាយ ។ ជាញឹកញយ RA ក៏ចោទប្រកាន់ផងដែរថា ដោយសារតែគ្រួសាររបស់ពលករនៅជំពាក់ប្រាក់ពួកគេ គឺ RAs ទេ ដែលត្រូវដាក់ពាក្យបណ្តឹងដើម្បីទាមទារសំណងនោះ ។ ផ្នែកនេះ ពិនិត្យទៅលើច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណីដែលអាចប្រើប្រាស់ដើម្បីជំទាស់ទៅនឹងហេតុផលទាំងនេះ ក្នុងករណីដែលពលករបានទទួលរងការខាតបង់ពិតប្រាកដ និង/ឬក្នុងករណីដែលភាពងាយរងគ្រោះរបស់ពលករ/គ្រួសាររបស់ពួកគេ អាចបញ្ជាក់ដោយភ័ស្តុតាងថាត្រូវបានកេងប្រវ័ញ្ចដោយ RA ។

### ផ្នែកទី៩ : សេចក្តីសន្និដ្ឋាន

ក្របខ័ណ្ឌគតិយុត្តនៅក្នុងប្រទេសកម្ពុជា កំពុងប្រឹងប្រែងដើម្បីដើរឱ្យទាន់ការវិវត្តន៍ដ៏លឿននៃនិន្នាការចំណាកស្រុកដើម្បីការងារ ដែលទុកឱ្យពលករចំណាកស្រុករាប់ពាន់នាក់គ្មានការការពារសំខាន់ចាំបាច់ ដែលការតាមដាន និងការត្រួតពិនិត្យគួរតែផ្តល់ឱ្យ ។ ដូច្នេះហើយ មនុស្សកាន់តែកេងចំណេញលើចន្លោះដែលរីកកាន់តែធំ ដែលតាមរយៈចន្លោះនេះ ការធ្វើចំណាកស្រុកមិនប្រក្រតីអាចធ្វើឡើងដោយមានហានិភ័យតិចតួច ឬគ្មានហានិភ័យទាល់តែសោះ ។ ចំពោះពលករទាំងឡាយដែលចង់ស្វែងរកផ្លូវនេះដើម្បីស្ថិរភាពសេដ្ឋកិច្ច កង្វះព័ត៌មាន និងភាពចន្លោះប្រហោងនានា មានន័យថា ពលករចំណាកស្រុកពីបីនាក់អាចនឹងចាប់យកជំហានដ៏ឈ្លាសវៃ ដើម្បីការពារខ្លួនពួកគេពីស្ថានភាពគ្រោះថ្នាក់ រឺការកេងប្រវ័ញ្ច ។

រាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងអនុម័តអនុក្រឹត្យថ្មីមួយស្តីពីការងាររបស់ពលករចំណាកស្រុក (ដែលចេញជាសេចក្តីព្រាងក្នុងពេលដ៏ខ្លីខាងមុខ) និងក្រមរដ្ឋប្បវេណីថ្មី (ឆ្នាំ២០០៧) ដែលបានចូលជាធរមាននាពេលថ្មីៗកន្លងទៅនេះ ។ ច្បាប់ទាំងពីរនេះ នឹងមានផលប៉ះពាល់ដ៏ច្រើនទៅលើការការពារពលករចំណាកស្រុក ។ គេសង្ឃឹមថា អនុក្រឹត្យនេះនឹងកំណត់បទដ្ឋានសម្រាប់ការជ្រើសរើសពលករចំណាកស្រុក ដោយចែងអំពីលក្ខខណ្ឌកិច្ចសន្យា លក្ខខណ្ឌតម្រូវសម្រាប់ការបណ្តុះបណ្តាល និងនីតិវិធីសម្រាប់បណ្តឹង ។ ក្រមរដ្ឋប្បវេណីនឹងចែងអំពីមាត្រាស្តីពីអំពើធ្វេសប្រហែស ដែលអាចប្រើប្រាស់ប្រឆាំងនឹងជនទាំងឡាយដែលការជ្រើសរើស ឬការបណ្តុះបណ្តាលដោយធ្វេសប្រហែសរបស់ខ្លួន បង្កគ្រោះថ្នាក់ដល់ពលករចំណាកស្រុក ។ កិច្ចព្រមព្រៀងទ្វេភាគីកាន់តែរឹងមាំជាមួយប្រទេសទទួលពលករ និងរចនាសម្ព័ន្ធតាមដាន និងវាយតម្លៃដែលកាន់តែមានភាពស៊ីសង្វាក់គ្នា ក៏នឹងធានាបានថា ពលករទទួលបានប្រព្រឹត្តកម្មដោយយុត្តិធម៌ និងត្រឹមត្រូវ នៅពេលដែលពួកគេបានចាកចេញពីប្រទេស ។

### ផ្នែកទី១០ : ក្របខ័ណ្ឌគតិយុត្ត— ដ្យាក្រាម និងតារាងនៃច្បាប់

ផ្នែកនីមួយៗនៃរបាយការណ៍នេះ ចាប់ផ្តើមដោយដ្យាក្រាមមួយដែលបង្ហាញអំពីភាពខុសគ្នា និងសកម្មភាពនានា ដែលកើតឡើងនៅក្នុងដំណាក់កាលនោះនៃដំណើរការចំណាកស្រុក ដោយទន្ទឹមនឹងនោះ បង្ហាញអំពីច្បាប់នានា (រដ្ឋប្បវេណី ព្រហ្មទណ្ឌ

និងអន្តរជាតិ) ដែលអាចអនុវត្តចំពោះសកម្មភាពទាំងនេះ ។ ផ្នែកទី១០ មានដ្យាក្រាមមេមួយ ដែលដាក់បញ្ចូលដ្យាក្រាមជាក់លាក់តាមផ្នែកនីមួយៗទាំងអស់ចូលគ្នា ។ តារាងដែលនៅក្រោមដ្យាក្រាមនោះ រួមមានព័ត៌មានបន្ថែមទៀតអំពីច្បាប់នីមួយៗដែលលើកឡើងនៅក្នុងដ្យាក្រាម ។ តារាង និងដ្យាក្រាមមានបំណងដើម្បីបង្កើតជាមគ្គុទ្ទេសក៏សង្ខេបមួយសម្រាប់អ្នកអានដែលមានបំណងរកមើលច្បាប់នានា ដែលអាចអនុវត្តចំពោះស្ថានភាពនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃដំណើរការចំណាកស្រុក ។ ឧបសម្ព័ន្ធ ខ រួមមានដ្យាក្រាមមេមួយដែលមានទំហំប៉ុនក្រដាស A3 សម្រាប់ការប្រើប្រាស់នៅក្នុងចំណុចនេះ ។

## ១. សេចក្តីផ្តើម

១.១.១. ផ្អែកតាមជំរឿនប្រជាជនឆ្នាំ២០០៨ ប្រជាជនកម្ពុជាមានចំនួន ១៣,៤លាននាក់ ជាមួយនឹងការព្យាករណ៍ថា នឹងកើនដល់ ១៩លាន នៅឆ្នាំ២០២០[២] ។ មួយភាគធំនៃប្រជាជនកម្ពុជា គឺជាយុវជនវ័យក្មេង ដែលជាលទ្ធផលកំណើននៃអត្រាកំណើតរបស់ប្រទេសកម្ពុជា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ដូច្នេះហើយ ប្រទេសកម្ពុជាបច្ចុប្បន្នកំពុងប្រឈមមុខនឹងលំហូរនៃពលករថ្មីប្រមាណ ២៥០.០០០នាក់ទៅក្នុងទីផ្សារការងារក្នុងមួយឆ្នាំៗ នៅក្នុងបណ្តាឆ្នាំខាងមុខ[៣] ។ ជាកិច្ចឆ្លើយតបចំពោះចំនួនប្រជាជនកម្ពុជាកាន់តែច្រើនឡើងដែលចូលក្នុងទីផ្សារពលកម្ម និងធាតុពិតនៃការបង្កើតការងារមិនអាចដើរទន្ទឹមគ្នានឹងចំនួនពលករដែលចូលក្នុងទីផ្សារការងារ រាជរដ្ឋាភិបាលកម្ពុជា ពឹងផ្អែកកាន់តែខ្លាំងឡើងទៅលើការធ្វើចំណាកស្រុករបស់ពលករកម្ពុជាទៅក្រៅប្រទេស ។ ប្រការនេះបានបង្កើនតម្រូវការឱ្យមានគោលនយោបាយ ដែលសម្របសម្រួលការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការការពារសិទ្ធិរបស់ពលករចំណាកស្រុកឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

១.១.២. ប្រទេសគោលដៅសំខាន់ៗសម្រាប់ពលករចំណាកស្រុកកម្ពុជា រួមមាន ម៉ាឡេស៊ីសម្រាប់ការងារតាមផ្ទះ ប្រទេសថៃសម្រាប់ការងារនៅក្នុងវិស័យកសិកម្ម និងកូរ៉េខាងត្បូងសម្រាប់ការងារនៅក្នុងវិស័យផលិតកម្ម សំណង់ និងកសិកម្ម ។ គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស (UNIAP) បានបោះពុម្ពផ្សាយតួលេខរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ដែលបង្ហាញថា នៅក្នុងឆ្នាំ២០០៩ ពលករចំនួន ១៤.៩១២នាក់ បានចាកចេញពីប្រទេសកម្ពុជាតាមច្រកប្រក្រតីដើម្បីធ្វើការនៅក្នុងប្រទេសគោលដៅសំខាន់ៗទាំងបីនេះ[៤] ។ តួលេខដែលចេញផ្សាយដោយសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) សម្រាប់ឆ្នាំ២០១០ ទំនងជាកើនឡើងច្រើនជាងទ្វេដង ដោយមានពលករកម្ពុជា ៣០.៥១១នាក់ បានចាកចេញទៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃ ក្នុងរយៈពេល ១០ខែដំបូងតែប៉ុណ្ណោះ (២២.៤២៥នាក់ ទៅកាន់ប្រទេសម៉ាឡេស៊ី និង ៨.០៨៦នាក់ ទៅកាន់ប្រទេសថៃ)[៥] ។

១.១.៣. ចំនួនពលករដែលធ្វើចំណាកស្រុក និងតម្រូវការសម្រាប់ពលករចំណាកស្រុកកំពុងមានការកើនឡើង ។ ប្រសិនបើការប៉ាន់ស្មានតម្រូវការពលករ ៣០.០០០នាក់ក្នុងមួយឆ្នាំនៅក្នុងប្រទេសម៉ាឡេស៊ី និង ៥០.០០០នាក់ នៅក្នុងប្រទេសថៃ ពិតជាត្រឹមត្រូវនោះ ឱកាសសម្រាប់ប្រទេសកម្ពុជាក៏នឹងបន្តកើនឡើងផងដែរ ។ ប៉ុន្តែ នៅទីណាដែល

---

[២] ព្រះរាជាណាចក្រកម្ពុជា *គោលនយោបាយស្តីពីការធ្វើចំណាកស្រុកដើម្បីការងារសម្រាប់ប្រទេសកម្ពុជា* (MOLVT/ILO ខែមិថុនា ឆ្នាំ២០១០) ទំព័រ ៩ ។

[៣] Ibid ទំព័រ ៩ ។

[៤] បណ្តាញឆ្លើយតបព័ត៌មានយុទ្ធសាស្ត្រ UNIAP ("SIREN") *ឯកសារទិន្នន័យអេឡិចត្រូនិកស្តីពីការជួញដូរមនុស្ស នៅក្នុងប្រទេសនៃតំបន់ទន្លេមេគង្គ* (ខែកញ្ញា ឆ្នាំ២០១០) ដែលមាននៅលើ : www.no-trafficking.org/story_2010ht_datasheets.html បើកមើលនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[៥] May Kunmakara, "តម្រូវការពលកម្មកើនឡើង" កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០) ។

មានការធ្វើចំណាកស្រុកប្រក្រតី (ដែលកើតឡើងនៅក្នុងក្របខ័ណ្ឌនៃបទដ្ឋាន និងការអនុវត្ត ដែលកំណត់ដោយរដ្ឋ ដើម្បីគ្រប់គ្រងលំហូរដែលមានសណ្ដាប់ធ្នាប់នៃការធ្វើចំណាកស្រុកដើម្បីការងារ) នៅទីនោះក៏មានទំហំនៃការធ្វើចំណាកស្រុកមិនប្រក្រតីស្មើគ្នា និងកើនឡើងផងដែរ ។ ការចំណាយ ការិយាធិបតេយ្យ និងពេលវេលា ដែលទាក់ទងនឹងការធ្វើចំណាកស្រុកប្រក្រតី អាចជាឧបសគ្គដ៏ធំពេកចំពោះអ្នកដែលស្វែងរកប្រាក់ចំណូលដើម្បីចាកផុតពីភាពក្រីក្រ ។ ដូចគ្នានេះដែរ កង្វះក្របខ័ណ្ឌគតិយុត្តិរួម និងការត្រួតពិនិត្យការជ្រើសរើសពលករប្រក្រតី មានន័យថា ក្រុមហ៊ុនជ្រើសរើសពលករដែលផ្ដោតទៅលើការរកកម្រៃចំណេញ អាចប្រតិបត្តិការក្រុមហ៊ុនរបស់ខ្លួន ដោយផ្ដោតសំខាន់ទៅលើកម្រៃចំណេញ ដោយគ្មានការការពារសិទ្ធិពលករគ្រប់គ្រាន់ ។ ដោយសារតែការត្រួតពិនិត្យ និងការគ្រប់គ្រងទៅលើការជ្រើសរើសពលករមានកម្រិតទាប និងតម្រូវការខ្ពស់នៅក្រៅប្រទេស ពលករទាំងឡាយដែលស្វះស្វែងធ្វើចំណាកស្រុកដើម្បីការងារ ងាយនឹងទទួលរងគ្រោះពីការកេងប្រវ័ញ្ច និងការជួញដូរ ហើយក្នុងស្ថានភាពអាក្រក់បំផុត ពួកគេអាចនឹងត្រូវរត់ពន្ធឆ្លងដែន និងលក់ដូរទៅក្នុងទាសភាព ។

១.១.៤. ការធ្វើចំណាកស្រុករបស់ពលករកម្ពុជាទៅកាន់ប្រទេសម៉ាឡេស៊ី បានកើនឡើងដ៏គួរឱ្យកត់សម្គាល់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ប្រការនេះគឺដោយសារតែនៅឆ្នាំ២០០៩ ប្រទេសឥណ្ឌូនេស៊ីបានសម្រេចចិត្តឈប់អនុញ្ញាតឱ្យពលកររបស់ខ្លួនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ដោយសារតែលក្ខខណ្ឌការងារមិនល្អ[៦] ។ បច្ចុប្បន្នបញ្ហាចម្បងៗដែលបានរកឃើញទាក់ទងនឹងការធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ី គឺថា ពលករកំពុងត្រូវបានកេងប្រវ័ញ្ចដោយក្រុមហ៊ុនជ្រើសរើសពលករកម្ពុជា ដែលស្របច្បាប់ និងមានអាជ្ញាប័ណ្ណ (ឬដែលអះអាងថា) ស្របច្បាប់ និងមានអាជ្ញាប័ណ្ណ ហើយកំពុងត្រូវបានបញ្ជូនទៅឱ្យធ្វើការងារដែលមានលក្ខខណ្ឌមិនល្អនៅក្នុងប្រទេសម៉ាឡេស៊ី ដោយមានការគាំទ្រតិចតួច ឬគ្មានការគាំទ្រទាល់តែសោះ ។ ម្យ៉ាងទៀត ប្រទេសថៃមានព្រំដែនជាប់ប្រទេសកម្ពុជា ដូច្នេះហើយ ករណីចំណាកស្រុកមិនប្រក្រតីជាច្រើនជាប់ទាក់ទងនឹងការឆ្លងដែនខុសច្បាប់ (ទាំងដោយស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត) ។

១.១.៥. របាយការណ៍នេះ ព្យាយាមកំណត់និងវិភាគអំពីច្បាប់ជាតិ តំបន់ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកដើម្បីការងារនៅប្រទេសកម្ពុជា ។ ក្នុងការធ្វើដូច្នេះ របាយការណ៍មានបំណងដើម្បីបង្ហាញអំពីច្បាប់ ដែលគ្រប់គ្រងការធ្វើចំណាកស្រុកប្រក្រតីដើម្បីការងារ ព្រមទាំងច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌដែលកំពុងរំលោភបំពានដោយពលករទាំងឡាយដែលវង្វេងនៅក្នុងផ្លូវមិនប្រក្រតីនៃការធ្វើចំណាកស្រុក ។ របាយការណ៍នេះ មិនផ្ដោតលើការធ្វើចំណាកស្រុកដើម្បីការងារនៅក្នុងប្រទេស ឬសកម្មភាពជួញដូរមនុស្សមិនឆ្លងដែនឡើយ ។

១.១.៦. ដើម្បីបង្ហាញអំពីក្របខ័ណ្ឌគតិយុត្តស្ដីពីការធ្វើចំណាកស្រុកដើម្បីការងារ របាយការណ៍នេះផ្ដោតសំខាន់ទៅលើដំណើររឿងនៃការធ្វើចំណាកស្រុកខុសគ្នាចំនួនពីរ គឺរឿងរ៉ាវរបស់ សំនៀង (បុរសម្នាក់ដែលត្រូវបានជ្រើសរើសឱ្យធ្វើ

---

[៦] "ពុំទាន់មានកិច្ចព្រមព្រៀងជាក់លាក់នៅឡើងស្ដីពីពលករចំណាកស្រុកឥណ្ឌូនេស៊ីនៅក្នុងប្រទេសម៉ាឡេស៊ី" *The Jakarta Globe* (ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០) អាចបើកមើលនៅលើ : http://www.thejakartaglobe.com/home/no-firm-agreement-yet-on-indonesian-migrant-workers-in-malaysia/375755 ។

ការងារនៅក្នុងវិស័យនេសាទនៅប្រទេសថៃ) និងរឿងរ៉ាវរបស់ សុភាព (ក្មេងស្រីម្នាក់ដែលត្រូវបានជ្រើសរើសឱ្យបម្រើការងារនៅក្នុងផ្ទះនៅប្រទេសម៉ាឡេស៊ី) ។ រឿងរ៉ាវទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីបម្រើគោលបំណងរបស់របាយការណ៍ ហើយផ្អែកលើដំណើររឿងពិត ប៉ុន្តែ មិនមែនលើមនុស្សពិតប្រាកដនោះទេ ។ របាយការណ៍ក៏ប្រើប្រាស់ផងដែរ នូវដ្យាក្រាម ដើម្បីបង្ហាញអំពីដំណាក់កាលនីមួយៗនៃការធ្វើចំណាកស្រុក ភាពខុសគ្នា និងសកម្មភាពផ្សេងៗ ដែលពាក់ព័ន្ធនៅក្នុងដំណាក់កាលនីមួយៗ ព្រមទាំងច្បាប់ដែលអាចប្រើប្រាស់ ដើម្បីការពារជនរងគ្រោះ និងផ្តន្ទាទោសជនល្មើសដែលធ្វើចំណាកស្រុកមិនប្រក្រតី និងប្រព្រឹត្តអំពើកេងប្រវ័ញ្ច ។

១.១.៧. របាយការណ៍នេះ ពិភាក្សាអំពីរបៀបដែលច្បាប់ព្រហ្មទណ្ឌ និងច្បាប់មិនមែនព្រហ្មទណ្ឌ អាចប្រើប្រាស់ដើម្បីការពារជនរងគ្រោះ (និងផ្តន្ទាទោសជនល្មើស) ដែលប្រព្រឹត្តអំពើកេងប្រវ័ញ្ច ។ របាយការណ៍នេះ ក៏ពិនិត្យត្រួសៗផងដែរទៅលើបទដ្ឋានការងារដែលប្រើប្រាស់នៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសថៃ ។ របាយការណ៍នេះរកឃើញថាខណៈដែលក្របខ័ណ្ឌគតិយុត្តក្នុងស្រុក និងតំបន់ពុំទាន់មានគ្រប់គ្រាន់ RAs អាចធ្វើការដោយមានការត្រួតពិនិត្យតិចតួច ហើយជនរងគ្រោះនៃអំពើកេងប្រវ័ញ្ច ជួបការលំបាកក្នុងការផ្តន្ទាទោសជនល្មើស ។

## ២. ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករ (RAs)




២.១.១. ដំណើរការនៃការអនុញ្ញាតអោយធ្វើចំណាកស្រុកដើម្បីការងារចេញពីប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) និងត្រូវបានចែងនៅក្នុងអនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥) ។ ក្រុមហ៊ុនទាំងអស់ដែលនាំពលករខ្មែរចេញទៅក្រៅប្រទេស ត្រូវតែស្នើសុំអាជ្ញាប័ណ្ណពី MOLVT និងត្រូវគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដែលបង្កើតនូវទំនាក់ទំនងឧបកិច្ចសន្យារវាង MOLVT ("ភាគីផ្តល់អាជ្ញាប័ណ្ណ") និង RAs ("ភាគីទទួលអាជ្ញាប័ណ្ណ")[៧] ។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១០ MOLVT បានផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករចំនួន ៣២[៨] ។

២.១.២. ដើម្បីទទួលបានអាជ្ញាប័ណ្ណពី MOLVT ទីភ្នាក់ងារជ្រើសរើសពលករ (RA) ត្រូវតែដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ ។ ពាក្យស្នើសុំនេះត្រូវមានព័ត៌មានលម្អិតអំពីការងារ ដែលពួកគេជ្រើសរើសពលករឱ្យធ្វើ ទីកន្លែង

---

[៧] RAs ក៏ត្រូវបានតម្រូវឱ្យចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មផងដែរ ។

[៨] បញ្ជីទីភ្នាក់ងារជ្រើសរើសពលករដែលមានអាជ្ញាប័ណ្ណសម្រាប់ប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និង/ឬអារ៉ាប៊ី/គូវ៉ែត/លីប៊ី ដែលចេញដោយនាយកដ្ឋានការងារ និងពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ឆ្នាំ២០១០) ។

ការងារ ចំនួនពលករដែលត្រូវការ ប្រាក់ខែ និងការរៀបចំធ្វើដំណើរ[៩] ។ MOLVT ផ្តល់ការអនុញ្ញាតដល់ RA ដោយផ្អែកលើព័ត៌មានដែលបានផ្តល់ឱ្យ ឬសុំឱ្យមានការពិភាក្សាបញ្ហានេះបន្ថែមទៀត ។ នៅពេលណាដែល MOLVT បានចេញលិខិតអនុញ្ញាតជាផ្លូវការឱ្យទៅ RA រួចហើយ RA មានរយៈពេល ៧ថ្ងៃ ដើម្បីដាក់តម្កល់ប្រាក់ធានាចំនួន ១០០.០០០ដុល្លារ នៅឯ MOLVT ដែលនឹងត្រូវប្រើប្រាស់ក្នុងករណីដែលបុគ្គលិក-និយោជិតមានបណ្តឹងស្របច្បាប់ដើម្បីទាមទារសំណង[១០] ។

២.១.៣. បន្ទាប់មក RAs ត្រូវទទួលខុសត្រូវជាឯកតោភាគីចំពោះពលករ ចាប់តាំងពីការជ្រើសរើសរហូតដល់ការចាប់ផ្តើមការងាររបស់ពួកគេ ដែលរួមបញ្ចូលទាំងការដឹកជញ្ជូនពលករទៅធ្វើការបណ្តុះបណ្តាលនៅមុនពេលចេញដំណើរ និងទៅក្រៅប្រទេស ព្រមទាំងផ្តល់ម្ហូបអាហារ និងការស្នាក់អាស្រ័យនៅក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល ។ ជាការពិតណាស់ RAs គឺជាក្រុមហ៊ុនរកប្រាក់កម្រៃ ដែលមានតម្រូវការដើម្បីរកប្រាក់ឱ្យបានភ្លាមៗសម្រាប់ការចំណាយទៅលើប្រាក់ធានា ។ ដូច្នេះហើយ ក្រុមហ៊ុនទាំងនេះត្រូវគិតផលប្រយោជន៍របស់ខ្លួន ដោយធានាថា ការចំណាយលើការដឹកជញ្ជូន ការបណ្តុះបណ្តាល និងការស្នាក់អាស្រ័យមានកម្រិតទាបតាមដែលអាចធ្វើទៅបាន ដើម្បីបង្កើនប្រាក់ចំណេញឱ្យបានកាន់តែច្រើន ។ ជាងនេះទៅទៀត វិស័យនៃឧស្សាហកម្មមួយនេះនៅក្នុងប្រទេសកម្ពុជា ពុំត្រូវបានត្រួតពិនិត្យ ឬគ្រប់គ្រងឡើយ ហើយចន្លោះដែលមាននៅក្នុងប្រព័ន្ធនេះសម្រាប់ការអនុវត្តដែលមានលក្ខណៈកេងប្រវ័ញ្ច មានទំហំធំ ។

២.១.៤. អនុក្រឹត្យចែងថា ជនណាដែលត្រូវបានរកឃើញថា បញ្ជូនពលករខ្មែរទៅក្រៅប្រទេសដោយផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យ អាចត្រូវផ្តន្ទាទោសតាមច្បាប់ ។[១១] MOLVT មានសិទ្ធិអំណាច ដើម្បីដកហូតអាជ្ញាប័ណ្ណក្នុងករណីដែល RA ប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។ ប៉ុន្តែ ទោះជាយ៉ាងណា ពុំមានការចែងច្បាស់លាស់អំពីប្រភេទនៃសកម្មភាព ដែលនឹងត្រូវចាត់ទុកជាមូលហេតុគ្រប់គ្រាន់ដើម្បីដកហូតអាជ្ញាប័ណ្ណពី RAs ឡើយ ។ ការមិនបង់ប្រាក់ធានា ១០០.០០០ដុល្លារសហរដ្ឋអាមេរិក ត្រូវបានចាត់ទុកជាមូលហេតុគ្រប់គ្រាន់សម្រាប់ការដកហូតអាជ្ញាប័ណ្ណ ដូចដែលត្រូវបានឃើញនៅក្នុងឆ្នាំ២០០៦ នៅពេលដែល MoLVT បានដកហូតអាជ្ញាប័ណ្ណចំនួន ៣០ ដោយផ្អែកលើមូលដ្ឋាននេះ[១២] ។ នៅក្នុងឆ្នាំ២០១០ ក្រុមហ៊ុន VC Manpower ត្រូវបានហាមឃាត់ជាបណ្តោះអាសន្នមិនឱ្យធ្វើការជ្រើសរើសពលករ បន្ទាប់ពីគេបានរកឃើញថា ក្មេងស្រី ២៤នាក់ ក្នុងចំណោមក្មេងស្រីដែលក្រុមហ៊ុននេះបានជ្រើសរើស គឺជាអនីតិជន ។ វិធានការនេះត្រូវបានធ្វើឡើងនៅក្រោយការឆ្មក់ចូលមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុន VC Manpower និង Champa Manpower ដែលកន្លែង

---

[៩] មាត្រា ៥ អនុក្រឹត្យលេខ ៥៧ ។

[១០] មាត្រា ៧ អនុក្រឹត្យលេខ ៥៧ ។

[១១] មាត្រា ២០ អនុក្រឹត្យលេខ ៥៧ ។

[១២] Chen Chen Lee, "ការជ្រើសរើសពលករដែលមានលក្ខណៈកេងប្រវ័ញ្ចនៅកម្ពុជា : តួនាទី និងការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសពលករឯកជន" (ឆ្នាំ២០០៧ ILO IPEC-TICW) ។

ស្នាក់នៅរបស់ក្រុមហ៊ុន Champa Manpower ត្រូវបានប្រៀបប្រដូចទៅនឹង *"ទ្រុងមាន់ ឬទ្រុងទា"* ។[១៣] ការហាមប្រាមនេះ ត្រូវបានលុបចោលទៅវិញ បន្ទាប់ពីក្រុមហ៊ុននេះបានរែកញែកហេតុផលថា ក្មេងស្រីទាំងនោះបានផ្តល់ឯកសារអត្តសញ្ញាណក្លែងបន្លំ[១៤] ។ កន្លងមក ពុំទាន់មានឧទាហរណ៍នៃការដកហូតអាជ្ញាប័ណ្ណដោយ MOLVT ដោយសារការអនុវត្តដែលមានលក្ខណៈកេងប្រវ័ញ្ច ឬលក្ខខណ្ឌបណ្តុះបណ្តាលដែលមិនស្របតាម

### រឿងទី១ របស់ សុភាព

***សុភាព អាយុ ១៤ឆ្នាំ*** ។ នាងរស់នៅក្នុងភូមិតូចមួយ ជាមួយម្តាយ ឪពុក និងបងប្អូនបង្កើត ៣នាក់ ។ បងស្រីរបស់នាងរស់នៅភូមិជាមួយគ្នា នាងមានអាយុ ១៨ឆ្នាំ ហើយមានប្តី និង កូនរួចហើយ ។ គ្រួសាររបស់ សុភាព ប្រឹងប្រែងយ៉ាងលំបាកដើម្បីរកប្រាក់ផ្គត់ផ្គង់ជីវភាព ហើយកូនៗចាំបាច់ត្រូវតែចាប់ផ្តើមជួយរកប្រាក់ ។

ស្ត្រីម្នាក់ដែលត្រូវបានគេស្គាល់នៅក្នុងភូមិថា ធ្វើការឱ្យក្រុមហ៊ុនជ្រើសរើសពលករ ឈ្មោះ Malabour Recruitment Group Ltd. បានទៅជួបគ្រួសាររបស់ សុភាព ។ ស្ត្រីនោះ គឺជាភ្នាក់ងារជ្រើសរើសពលករក្នុងមូលដ្ឋាន ដែលទទួលបានប្រាក់ ៥០ដុល្លារសម្រាប់ក្មេងស្រីម្នាក់ៗដែលខ្លួនជ្រើសរើសបាន ។ ភ្នាក់ងារនោះប្រាប់ឪពុកម្តាយរបស់ សុភាព ថា ***សុភាព នឹងអាចរកប្រាក់បានប្រហែល ២.០០០ ទៅ ៣.០០០ដុល្លារក្នុងរយៈពេលពីរឆ្នាំ ដោយ ធ្វើការជាអ្នកបម្រើតាមផ្ទះនៅក្នុងប្រទេសម៉ាឡេស៊ី*** ។ ក្រុមហ៊ុន Malabour នឹងរ៉ាប់រងរាល់ថ្លៃចំណាយលើការធ្វើដំណើរ និងការបណ្តុះបណ្តាលទាំងអស់ ដែលនឹងត្រូវកាត់យកពីប្រាក់ខែ ៦ខែដំបូងរបស់ សុភាព ។ ពួកគេក៏នឹងផ្តល់អង្ករ និងប្រាក់កម្ចីដល់គ្រួសាររបស់ សុភាព ផងដែរ ។ សុភាព ទើបតែអាយុ ១៤ឆ្នាំ ដូច្នេះ នាងក្មេងពេកមិនអាចជ្រើសរើសបានឡើយ ប៉ុន្តែ តាមការឱ្យយោបល់របស់ភ្នាក់ងារ ***ម្តាយរបស់ សុភាព យល់ព្រមថា សុភាព គួរតែប្រើប្រាស់សំបុត្រកំណើតរបស់បងស្រីនាង ដើម្បីចុះឈ្មោះ*** ។

បទដ្ឋានឡើយ ។

២.១.៥. ក្រមសីលធម៌របស់ ACRA (ឆ្នាំ២០០៩) ចែងអំពីលក្ខខណ្ឌតម្រូវអប្បបរមាជាក់លាក់នៅក្នុងសកម្មភាពរបស់ RAs ក្នុងនោះរាប់បញ្ចូលទាំងចំណុច ៣.៤ ដែលតម្រូវឱ្យនិយោជិតទាំងអស់ត្រូវមានកិច្ចសន្យាការងារត្រឹមត្រូវ ។

---

[១៣] "អាណាព្យាបាលទទួលយកប្រាក់ពីទីភ្នាក់ងារជ្រើសរើសពលករ" ឌឹ *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០) ដែលអាចបើកមើលនៅលើ : http://cambodia.world.countries.net/archives/25000 ។

[១៤] "សិក្ខាកាមរងរបួស ខណៈរត់គេចចេញពីក្រុមហ៊ុនជ្រើសរើសពលករ" កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០) ដែលមាននៅលើ : http://www.cam111.com/photonews/2010/09/06/46333.html បើកមើលនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ប៉ុន្តែ នេះមិនមែនជាវិធីត្រួតពិនិត្យផ្លូវការឡើយ គឺគ្រាន់តែជាបញ្ជីនៃលក្ខខណ្ឌតម្រូវដែលកំណត់ដោយ ACRA និងត្រួតពិនិត្យដោយខ្លួនឯង ។

២.១.៦. គោលនយោបាយស្តីពីចំណាកស្រុកដើម្បីការងារ បានចែងអំពីតម្រូវការចាំបាច់នៃការត្រួតពិនិត្យការជ្រើសរើសពលករ តាមរយៈប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ដែលកំណត់ច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ទីភ្នាក់ងារជ្រើសរើស និងទោសទណ្ឌចំពោះការរំលោភច្បាប់ និងកិច្ចធានាចំពោះការអនុវត្តកិច្ចសន្យា[១៥] ។

**មេខ្យល់**

២.១.៧. ខណៈដែលច្បាប់តម្រូវឱ្យ RAs មានអាជ្ញាប័ណ្ណ ជារឿយៗ មិនមែន RAs ដោយផ្ទាល់ទេ ដែលចុះទៅជ្រើសរើសពលករនៅតាមខេត្តនោះ ។ ជារឿយៗ RAs ប្រើប្រាស់មេខ្យល់ដែលមានមូលដ្ឋាននៅតាមខេត្ត ហើយដែលទទួលប្រាក់ក្នុងចំនួនកំណត់មួយ សម្រាប់មនុស្សម្នាក់ៗដែលជ្រើសរើសបាន ។ ឋានៈផ្លូវច្បាប់នៃមេខ្យល់ទាំងនេះមិនច្បាស់លាស់ឡើយ ។ ជារឿយៗ ពុំមានទំនាក់ទំនងកិច្ចសន្យាជាលាយលក្ខណ៍អក្សរផ្លូវការរវាងមេខ្យល់ និងអ្នកដែលត្រូវបានជ្រើសរើសនោះទេ ហើយមេខ្យល់បំពេញតួនាទីជាតំណាងរបស់ RA ដោយគ្មានការចុះបញ្ជី ឬអាជ្ញាប័ណ្ណដាច់ដោយឡែកពី MOLVT ឡើយ ។

២.១.៨. ក្នុងករណីដែលមេខ្យល់អះអាងថាជាតំណាងរបស់ RA មួយដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ (នៅក្រោមកិច្ចសន្យាដោយប្រយោល) ជាការសមហេតុផល ដែល RA ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់មេខ្យល់នោះ ហើយមេខ្យល់នោះ ត្រូវធ្វើសកម្មភាពនៅក្នុងក្របខ័ណ្ឌលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ។ ក្នុងករណីដែលសកម្មភាពរបស់មេខ្យល់បង្កឱ្យមានមូលហេតុសម្រាប់បណ្តឹងរដ្ឋប្បវេណី (ឧទាហរណ៍ ដោយបំភ្លៃលក្ខខណ្ឌនៃកិច្ចសន្យា) បណ្តឹងរដ្ឋប្បវេណីនេះគួរតែធ្វើឡើងប្រឆាំងនឹង RA ។ ប៉ុន្តែ ប្រសិនបើមេខ្យល់ប្រព្រឹត្តអំពើឧក្រិដ្ឋ ទាំងមេខ្យល់ និងទាំង RA អាចត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ដូចគ្នា[១៦] ។

២.១.៩. ក្នុងកាលៈទេសៈដែលមេខ្យល់ចុះកិច្ចសន្យាជាមួយពលករ ដោយថ្លែងថា ខ្លួនជាតំណាងរបស់ RA មេខ្យល់អាចត្រូវបានកំណត់អត្តសញ្ញាណតាមផ្លូវច្បាប់ថាជាភ្នាក់ងាររបស់ RA ។ ក្រមរដ្ឋប្បវេណីថ្មី រួមបញ្ចូលផ្នែកមួយស្តីពីវិធាននៃទីភ្នាក់ងារ[១៧] ។ វិន័យនៃទីភ្នាក់ងារចែងថា គោលការណ៍ (ក្នុងករណីនេះ គឺ RA) ត្រូវបានភ្ជាប់កាតព្វកិច្ចដោយកិច្ចសន្យាដែលធ្វើឡើងដោយទីភ្នាក់ងារ ឬថា ក្នុងករណីដែលភ្នាក់ងារធ្វើសកម្មភាពនៅក្រៅសិទ្ធិអំណាចរបស់ខ្លួន ភ្នាក់ងារនោះត្រូវមានកាតព្វកិច្ចបំពេញកិច្ចសន្យា ឬបង់សំណងក្នុងករណីដែលភ្នាក់ងារមិនអាចបំពេញកិច្ចសន្យាបានទេនោះ ។

---

[១៥] ព្រះរាជាណាចក្រកម្ពុជា *គោលនយោបាយស្តីពីចំណាកស្រុកដើម្បីការងារសម្រាប់កម្ពុជា* (ខែមិថុនា ឆ្នាំ២០១០) ។

[១៦] មាត្រា ៤២ ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ។

[១៧] ផ្នែកទី៤ ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ការបកប្រែជាភាសាអង់គ្លេសបណ្តោះអាសន្ន (ខែតុលា ឆ្នាំ២០០៨) ចូលជាធរមាននៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១ នៅក្រោយការអនុម័តដោយរដ្ឋសភា ដូចដែលរាយការណ៍ដោយកាសែត *ឌឹ ភែមបូឌា ដេលី* ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១ ។

២.១.១០. ប៉ុន្តែ ប្រសិនបើមេខ្យល់ធ្វើសកម្មភាពដោយឯករាជ្យ ឬឱ្យ RA ដែលគ្មានអាជ្ញាប័ណ្ណ MOLVT គួរតែត្រូវបានជូនដំណឹង ។ ខណៈដែល MOLVT អាចចាត់វិធានការប្រឆាំងនឹង RA/មេខ្យល់ដែលគ្មានអាជ្ញាប័ណ្ណ ចរិតនៃឋានៈមិនផ្លូវការរបស់ RA/មេខ្យល់ដែលគ្មានអាជ្ញាប័ណ្ណទាំងនេះ អាចបង្កការលំបាកក្នុងការតាមដានពួកគេ ។

២.១.១១. ក្នុងករណីដែលគ្មានឋានៈផ្លូវការ និងស្របច្បាប់នៅក្នុងដំណើរការជ្រើសរើស ជារឿយៗ មេខ្យល់អាចត្រូវបានប្រើប្រាស់ជាទំនាក់ទំនងទន់ខ្សោយនៅក្នុងខ្សែសង្វាក់នៃការជ្រើសរើស ។ RAs អាចទម្លាក់កំហុសលើមេខ្យល់ និងភ្ជាប់កំហុសនៃការអនុវត្តមិនស្របច្បាប់ទៅលើពួកគេ ។ ដូច្នេះហើយ ជាការចាំបាច់ដែលត្រូវបញ្ចូលមេខ្យល់ទៅក្នុងក្របខ័ណ្ឌផ្តល់អាជ្ញាប័ណ្ណដើម្បីធានាថា ពួកគេ/RAs ទទួលខុសត្រូវពេញលេញចំពោះសកម្មភាពរបស់មេខ្យល់ ។

## ៣. ការចុះកិច្ចសន្យាជាមួយពលករ/ការជ្រើសរើសពលករ




### ៣.១. រឿងរបស់ សុភាព

**ការជ្រើសរើស**

៣.១.១. មាត្រា ៣ នៃអនុក្រឹត្យលេខ៥៧ ចែងថា RAs ត្រូវតែជ្រើសរើសពលករដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ។ នៅក្នុងការជ្រើសរើស សុភាព មេខ្យល់រំលោភលើកិច្ចព្រមព្រៀងរវាង RAs និង MOLVT ។ បញ្ហានេះ គួរតែដាក់ជូន MOLVT ហើយប្រសិនបើមានភ័ស្តុតាងបញ្ជាក់ បញ្ហានេះត្រូវប៉ះពាល់ដល់សុពលភាពនៃអាជ្ញាប័ណ្ណរបស់ RAs ។ ប៉ុន្តែ ការដែលឪពុកម្តាយរបស់ សុភាព ជាប់ពាក់ព័ន្ធនៅក្នុងការកែអាយុរបស់ សុភាព អាចបង្កជាបញ្ហាទាក់ទងនឹងភ័ស្តុតាង ប្រសិនបើមានការចោទប្រកាន់ដោយផ្អែកលើមូលហេតុនេះ ។ RA អាចនឹងទាញហេតុផលថា សុភាព អះអាងថាមានអាយុ ១៨ឆ្នាំ នៅពេលដែលមេខ្យល់បានទៅជួបគ្រួសាររបស់នាង ។ លក្ខណៈស្រពេចស្រពិលនៃអនុក្រឹត្យលេខ ៥៧ មិនបានចែងអំពីការណែនាំណាមួយនៅក្នុងសេណារីយ៉ូនេះឡើយ ។ ប៉ុន្តែ ប្រសិនបើអានតាមពាក្យពេចន៍ អនុក្រឹត្យនេះចែងថា RAs ជ្រើសរើសតែពលករ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅប៉ុណ្ណោះ ។ ដោយសារតែនេះជាកាតព្វកិច្ចផ្លូវច្បាប់របស់ RAs ការបញ្ជាក់ដោយប្រយោល គឺថា RAs ជាអ្នកដែលមានកាតព្វកិច្ចត្រូវធានាថា ខ្លួនគោរពតាមលក្ខខណ្ឌតម្រូវនៃច្បាប់ ដោយធ្វើការត្រួតពិនិត្យ

សាវតារឱ្យបានសមស្រប ។ ក្នុងករណីដែល RA (ឬមេខ្យល់ដែលដើរតួជាភ្នាក់ងាររបស់ RA) ជ្រើសរើសជនណាម្នាក់អាយុក្រោម ១៨ឆ្នាំ ដោយមិនបានធ្វើការត្រួតពិនិត្យសមហេតុផលដើម្បីផ្ទៀងផ្ទាត់អាយុ ពួកគេត្រូវទទួលខុសត្រូវចំពោះការល្មើសនឹងអនុក្រឹត្យលេខ ៥៧ ។

៣.១.២. សៀវភៅគ្រួសារ គឺជាធនធានដ៏ល្អសម្រាប់មេខ្យល់ និង RAs ដើម្បីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់សមាជិកគ្រួសារ ជាមួយនឹងអត្តសញ្ញាណប័ណ្ណ និងសំបុត្រកំណើត ។ ទោះបីជាការពិតដែលថា ការក្លែងបន្លំអត្តសញ្ញាណជាច្រើនត្រូវបានផ្តួចផ្តើមគំនិតដោយមេខ្យល់ក្តី ក៏ RAs មានលេសតិចតួចក្នុងការទទួលយកមនុស្សអាយុ ១៤ ឆ្នាំថាជា ១៨ឆ្នាំ ដោយផ្អែកលើឯកសារអត្តសញ្ញាណរបស់បងប្អូនបង្កើតម្នាក់ ពីព្រោះថា គ្រាន់តែការស៊ើបអង្កេតបន្តិចបន្តួច ទំនងជាធ្វើឱ្យគេអាចដឹងអំពីអាយុពិតប្រាកដរបស់នាងទៅហើយ ។

៣.១.៣. អាស្រ័យលើកាលៈទេសៈនៃការជ្រើសរើស សកម្មភាពរបស់មេខ្យល់នៅដំណាក់កាលនេះ អាចចាត់ទុកជាអំពើឧក្រិដ្ឋ ។ មាត្រា ៣២៧ នៃក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ចែងអំពីបទឧក្រិដ្ឋ"នាំយកអនីតិជនចេញ" ថាជាអំពើនៃការនាំយកអនីតិជនចេញដោយខុសច្បាប់ពីមនុស្សម្នាក់ដែលមានការថែទាំស្របច្បាប់[១៨] ។ ដើម្បីកសាងសំណុំរឿងនេះ ជាការចាំបាច់ដែលត្រូវបង្ហាញភ័ស្តុតាងបញ្ជាក់ថា មេខ្យល់បានដឹងអំពីអាយុពិតប្រាកដរបស់ សុភាព (ការបង្ហាញថា មេខ្យល់គួរតែបានដឹងអំពីអាយុពិតរបស់នាង អាចជាការគ្រប់គ្រាន់ ) ។ មេខ្យល់ក៏អាចត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (LSHTSE) ផងដែរ[១៩] ។ ការផ្តន្ទាទោសករណីនេះប្រកបដោយជោគជ័យ អាស្រ័យលើកម្រិតនៃការបន្លំបោកប្រាស់ដែលធ្វើឡើងដោយមេខ្យល់ និងកម្រិតនៃការកេងប្រវ័ញ្ច ដែល សុភាព នឹងជួបប្រទះនៅឯគោលដៅចុងក្រោយ ។ របាយការណ៍នេះពិភាក្សាអំពីភាពខុសគ្នារវាងការជ្រើសរើសដោយស្របច្បាប់ និងការជួញដូរ នៅក្នុង*កថាខណ្ឌ ៣.២* ខាងក្រោម ។ ក្នុងករណីដែលការប្រគល់និងទទួល សុភាព ត្រូវបានចាត់ទុកជាការប្រគល់ដោយខុសច្បាប់ "*នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ... ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង*" មេខ្យល់ និងឪពុកម្តាយអាចត្រូវជាប់ទោសពីបទព្រហ្មទណ្ឌនៅក្រោមមាត្រា ១៤ នៃ LSHTSE ដែលផ្តន្ទាទោសអំពើលក់-ដូរមនុស្ស[២០] ។

**ការកែអាយុរបស់ សុភាព**

---

[១៨] ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ដល់ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ។

[១៩] ឧទាហរណ៍ មាត្រា ១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់ការកេងប្រវ័ញ្ច ។

[២០] មាត្រា ១៤ LSHTSE (ឆ្នាំ២០០៨) ។

៣.១.៤. ទង្វើនៃការដំឡើងអាយុរបស់អនីតិជនដើម្បីអាចមានសិទ្ធិធ្វើការងារ បានរីករាលដាលរហូតដល់បញ្ហានេះត្រូវបានលើកឡើងនៅក្នុងផែនការសកម្មភាពជាតិស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមាររបស់កម្ពុជា ដែលចុះហត្ថលេខា

### រឿងទី២ របស់ សុភាព

ឪពុកម្តាយរបស់ សុភាព បានយល់ព្រមផ្តិតស្នាមមេដៃនៅលើកិច្ចសន្យាចំនួន២ : ***(១) លិខិតយល់ព្រម និងធានា*** ដែលចែងថា សុភាព នឹងត្រូវបណ្តុះបណ្តាលរយៈពេល ៣ខែ នៅក្នុងមជ្ឈមណ្ឌលមួយកន្លែងក្នុងរាជធានីភ្នំពេញ នាងនឹងមិនត្រូវបានអនុញ្ញាតឱ្យចេញក្រៅឡើយ ហើយឪពុកម្តាយរបស់នាងអាចទៅសួរសុខទុក្ខនាងបានតែម្តងប៉ុណ្ណោះក្នុងមួយសប្តាហ៍ ។ កិច្ចព្រមព្រៀងនេះ ក៏ចែងផងដែរថា ***ឪពុកម្តាយរបស់ សុភាព នឹងត្រូវទទួលខុសត្រូវសងវិញនូវរាល់ថ្លៃចំណាយទាំងអស់ដែលទាក់ទងនឹងការជ្រើសរើស សុភាព*** ប្រសិនបើនាងមិនបានបញ្ចប់ការបណ្តុះបណ្តាល ឬមិនបានបំពេញកិច្ចសន្យាការងារ នៅមុនពេលសងប្រាក់ក្រុមហ៊ុន Malabour រួចរាល់ទៅនោះ ***(២) កិច្ចព្រមព្រៀងខ្ចីប្រាក់*** ដែលឪពុកម្តាយរបស់ សុភាព ព្រមព្រៀងសងប្រាក់កម្ចីទាំងស្រុង រួមជាមួយនឹងការប្រាក់ ទៅឱ្យក្រុមហ៊ុនវិញ ក្នុងករណីដែល សុភាព មិនបំពេញតាមកិច្ចសន្យា ។ សុភាព ផ្តិតស្នាមមេដៃលើឯកសារទី៣ ***(៣) កិច្ចសន្យាការងារ*** ដែលនាងយល់ព្រមទទួលយកលក្ខខណ្ឌការងារនៅក្នុងប្រទេសម៉ាឡេស៊ី ដោយព្រមព្រៀងសងថ្លៃចំណាយទាំងអស់ឱ្យក្រុមហ៊ុន Malabour វិញ ទោះជានាងបញ្ចប់ ឬមិនទាន់បញ្ចប់កិច្ចសន្យាការងារក្តី ។ ***ឪពុកម្តាយរបស់ សុភាព ត្រូវបានផ្តល់ប្រាក់ ១៥០ដុល្លារ និងអង្ករ ៥០គីឡូក្រាម*** ជាមួយនឹងការសន្យាថា នឹងផ្តល់ឱ្យ ១៥០ដុល្លារ និងអង្ករ ៥០គីឡូក្រាមទៀត នៅពេលដែល សុភាព បញ្ចប់ការបណ្តុះបណ្តាលរបស់នាង ។

ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន និងដែលចែងថា ការកែអត្តសញ្ញាណរបស់កុមារដើម្បីដំឡើងអាយុរបស់ពួកគេ គឺជាការរំលោភលើផែនការសកម្មភាព និងគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា[២១] ។

៣.១.៥. អនុក្រឹត្យលេខ ៣៨ (និងសេចក្តីបកប្រែក្រៅផ្លូវការនៃក្រមរដ្ឋប្បវេណីថ្មី) ចែងថា កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ ក្នុងករណីដែលកិច្ចសន្យានោះ *"ផ្ទុយនឹងច្បាប់ និងមិនស្របតាមសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ"*[២២] ។ មាត្រា ៣ នៃ អនុក្រឹត្យលេខ ៥៧ បញ្ជាក់ថា ពលករត្រូវមានអាយុ ១៨ឆ្នាំឡើងទៅ ដើម្បីក្លាយជាបេក្ខជនសម្រាប់ដាក់ពាក្យសុំទៅធ្វើការងារនៅក្រៅប្រទេស ។ ដូច្នេះ កិច្ចសន្យាណាមួយសម្រាប់ការងារនៅក្រៅ

[២១] ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

[២២] មាត្រា ៥ អនុក្រឹត្យលេខ ៣៨ មាត្រា ៣៥៤ ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ។

ប្រទេស ដែលការងារនោះត្រូវបានបំពេញដោយជនដែលមានអាយុក្រោម ១៨ឆ្នាំ គួរតែចាត់ទុកថា ខុសច្បាប់ ពីព្រោះវាផ្ទុយនឹងអនុក្រឹត្យលេខ ៥៧ ។ ផលប្រយោជន៍នៃការប្រើប្រាស់ហេតុផលនេះ មានពីរយ៉ាង :

៣.១.៥.១. កិច្ចសន្យាដែលផ្ទុយនឹងច្បាប់ត្រូវចាត់ទុកជាមោឃៈ ដែលខុសពីអាចធ្វើមោឃភាពបាន ។ ភាពខុសគ្នានេះ មានន័យថា សុពលភាពនៃកិច្ចសន្យាមិនត្រូវបានកំណត់ដោយចេតនា (ឬសកម្មភាពរបស់ភាគី) ឡើយ ។ ក្នុងករណីដែលកិច្ចសន្យាមួយអាចធ្វើមោឃភាពបាន ភាគីម្ខាង ឬភាគីទាំងសងខាង ត្រូវតែស្វះស្វែងសកម្មមុនដើម្បីធ្វើមោឃភាពកិច្ចសន្យានោះ ។ ប៉ុន្តែ ក្នុងករណីដែលកិច្ចសន្យា ត្រូវបានចាត់ទុកជាមោឃៈ មានន័យដូចគ្នានឹងថា កិច្ចសន្យាមិនដែលត្រូវបានធ្វើឡើងឡើយ ។

៣.១.៥.២. ជាការមិនគ្រប់គ្រាន់នោះទេ ដែលភាគីមួយទាញហេតុផលថា កិច្ចសន្យាមិនត្រូវចាត់ទុកជាមោឃៈ ដោយផ្អែកលើមូលដ្ឋានដែលគេមានហេតុផលចាត់ទុកថា ពលករមានអាយុ១៨ឆ្នាំ (ដោយផ្អែកតាមឯកសារអត្តសញ្ញាណក្លែងបន្លំនោះ) ។ ការដែលភាគីមួយចាត់ទុកថា ពលករមានអាយុ១៨ឆ្នាំ មិនផ្លាស់ប្តូរការពិតដែលពលករនោះមានអាយុក្រោម ១៨ឆ្នាំឡើយ ហើយក៏មិនផ្លាស់ប្តូរការពិតដែលថា ការជួលពលករអាយុក្រោម ១៨ឆ្នាំឱ្យទៅធ្វើការនៅក្រៅប្រទេស គឺជាការខុសច្បាប់នោះដែរ ។

៣.១.៦. មាត្រា ៧ នៃអនុក្រឹត្យលេខ ៣៨ ចែងថា ប្រសិនបើកិច្ចសន្យាមួយធ្វើឡើងដោយសារកំហុស ការបង្ខិតបង្ខំ ឬការក្លែងបន្លំ (ដោយរាប់បញ្ចូលទាំងការផ្តល់ព័ត៌មានមិនពិត ព្រោះបើសិនជាគ្មានអំពើបែបនេះទេ ភាគីម្ខាងទៀតនឹងមិនចុះកិច្ចសន្យាជាមួយឡើយ) កិច្ចសន្យានោះពុំមានសុពលភាពទេ ។ មាត្រា ១០ ចែងបន្តថា ការក្លែងបន្លំ គឺជាមូលហេតុសម្រាប់ការធ្វើមោឃភាពកិច្ចសន្យា នៅពេលមានអំពើបោកបន្លំ ភាពមិនស្មោះត្រង់ ឬការផ្តល់ព័ត៌មានក្លែងបន្លំ ដែលប្រព្រឹត្តដោយភាគីមួយនៃកិច្ចសន្យា ដែលប្រសិនបើគ្មានអំពើបែបនេះទេ ភាគីម្ខាងទៀតនឹងមិនចុះកិច្ចសន្យាជាមួយឡើយ ។ ក្នុងករណីរបស់ សុភាព ភាគីទាំងពីរបានដឹង និងផ្សំគំនិតគ្នានៅក្នុងការកែអាយុរបស់សុភាព ។ ជាការពិត ក្នុងករណីដែលគ្រួសារព្យាយាមធ្វើមោឃភាពកិច្ចសន្យាដោយផ្អែកលើមូលដ្ឋាននៃការក្លែងបន្លំ ពួកគេអាចនឹងយល់ឃើញថា RA មានជំហររឹងមាំជាងក្នុងន័យថា RA អាចទាញហេតុផលថា ខ្លួនមិនបានដឹងអំពីការកែអាយុទេ ហើយពឹងផ្អែកតាមឯកសារដែលផ្តល់ដោយគ្រួសារ ។ ជាងនេះទៅទៀត ដើម្បីធ្វើមោឃភាពកិច្ចសន្យាដោយសារហេតុផលនៃការបន្លំ ភាគីដែលចង់ធ្វើមោឃភាពត្រូវធ្វើបែបនេះភ្លាមៗនៅពេលដែលខ្លួនរកឃើញការបន្លំនេះ — ការពន្យារពេលណាមួយនឹងបង្កើនលទ្ធភាពដែលថា ភាគីទាំងសងខាងត្រូវបានចាត់ទុកថាបានផ្តល់ការយល់ព្រមចំពោះកាតព្វកិច្ចនៃកិច្ចសន្យារបស់ខ្លួន ដោយបន្តធ្វើសកម្មភាពនៅក្រោមកិច្ចសន្យានេះទាំងដឹងអំពីការបន្លំ ។

**កិច្ចសន្យាការងារ**

៣.១.៧. អនុក្រឹត្យលេខ ៥៧ ចែងនៅត្រង់មាត្រា ៩ អំពីការតម្រូវឱ្យមានកិច្ចសន្យាការងាររវាង RA និងពលករ ។ លក្ខខណ្ឌតម្រូវទាំងនេះ ត្រូវបានរៀបរាប់នៅក្នុងប្រអប់ខាងស្តាំដៃ ។ ក្នុងករណីដែលកិច្ចសន្យាការងារមិនមានគ្រប់លក្ខខណ្ឌទាំងអស់ដែលតម្រូវដោយអនុក្រឹត្យនេះទេនោះ គេគួរតែជូនដំណឹងអំពី RA នេះទៅ MOLVT ហើយអាជ្ញាប័ណ្ណរបស់ RA នោះ គួរតែពិចារណាឡើងវិញ ។

៤.១.៨. ដូចដែលបានពិភាក្សានៅខាងលើ មានហេតុផលល្អមួយដែលថា ការដែលសុភាព មានអាយុក្រោម ១៨ឆ្នាំ ធ្វើឱ្យកិច្ចសន្យាក្លាយជាមោឃៈ ដូចគ្នានឹងមិនដែលមានកិច្ចសន្យាដូច្នោះដែរ ។ ចំណុចនេះត្រូវបានលើកយកមកពិភាក្សានៅក្នុង*ផ្នែកទី ៨* ។

៤.១.៩. ហេតុផលមួយទៀតដែលមានសម្រាប់ករណីរបស់ សុភាព គឺថា ក្នុងនាមជាអនីតិជន នាងគ្មានសមត្ថភាពផ្លូវច្បាប់ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាទេ ។ មាត្រា ៦ នៃអនុក្រឹត្យលេខ ៣៨ ចែងថា កិច្ចសន្យាត្រូវចាត់ទុកថាអាចធ្វើមោឃភាពបាន នៅពេលដែលភាគីមួយពុំមានសមត្ថភាពផ្លូវច្បាប់ ។ ប៉ុន្តែមាត្រា ១៥ ចែងថា អនីតិជនអាយុក្រោម ១៨ឆ្នាំ អាចចុះកិច្ចសន្យាបានដោយមានការយល់ព្រមពីអាណាព្យាបាលស្របច្បាប់របស់ខ្លួន[២៣] ។ ឪពុកម្តាយរបស់ សុភាព បានយល់ព្រមឱ្យនាងចុះហត្ថលេខាលើកិច្ចសន្យា ប៉ុន្តែនាងគិតថា ចុះហត្ថលេខាក្នុងនាមជាជនដែលមានសមត្ថភាពផ្លូវច្បាប់ គឺគ្រប់អាយុ ១៨ឆ្នាំ ដូច្នេះ មិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយឡើយ ។ បែបនេះ គេអាចទាញហេតុផលថា កិច្ចសន្យាការងារដែលចុះហត្ថលេខាដោយ សុភាព អាចធ្វើមោឃភាពបាន ពីព្រោះកិច្ចសន្យានេះចុះហត្ថលេខាដោយអនីតិជន (ក្រោមអាយុ ១៨ឆ្នាំ) ។ ការទាញហេតុផលបែបនេះ គឺជាការពិបាក ដោយសារតែមានការយល់ព្រមពីឪពុកម្តាយចំពោះការបន្លំនេះ ។

**មាត្រា ៩ នៃអនុក្រឹត្យលេខ ៥៧ : លក្ខខណ្ឌតម្រូវ សម្រាប់កិច្ចសន្យាការងារ :**

- ឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់
- ទីកន្លែង និងប្រភេទនៃការងារ
- ជំនាញរបស់ពលករ
- ប្រាក់ខែ និងលាភការ
- ចំណែកនៃប្រាក់ខែ ដែលត្រូវផ្ញើមកឱ្យគ្រួសាររបស់ពលករ
- ម៉ោងធ្វើការ ការឈប់សម្រាកចុងសប្តាហ៍ និងការឈប់សម្រាកថ្ងៃបុណ្យ
- ការស្នាក់នៅ ម្ហូបអាហារ សម្លៀកបំពាក់ ការថែទាំសុខភាព
- ប្រាក់ធានារ៉ាប់រង សម្រាប់ពលករម្នាក់ៗ
- វិធីដឹកជញ្ជូនពលករទៅមកពីកន្លែងការងារ
- ការចំណាយ សម្រាប់ការធ្វើដំណើរទៅមក
- បញ្ញត្តិសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ពលករ ។

[២៣] ក្នុងករណីដែលគ្មានការចែងច្បាស់លាស់ថា ការយល់ព្រមបែបនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរទេនោះ ការយល់ព្រមដោយផ្ទាល់មាត់អាចជាការគ្រប់គ្រាន់ ។ នេះអាចបង្កឱ្យមានបញ្ហាភ័ស្តុតាង ប្រសិនបើមានជម្លោះនៅពេលក្រោយណាមួយ អំពីវត្តមានការយល់ព្រមបែបនេះ ។

**កិច្ចព្រមព្រៀងធានា**

៣.១.១០. ក្នុងករណីរបស់ សុភាព ឪពុកម្តាយរបស់នាងចុះហត្ថលេខាលើកិច្ចព្រមព្រៀងធានា ដែលភ្ជាប់កាតព្វកិច្ច សុភាព ឱ្យគោរពតាមលក្ខខណ្ឌនៃមជ្ឈមណ្ឌលបណ្តុះបណ្តាល និងដែលចែងថា ឪពុកម្តាយរបស់នាងទទួលខុសត្រូវសងនូវរាល់ការចំណាយរបស់ RA ក្នុងករណីដែល សុភាព មិនបញ្ចប់ការបណ្តុះបណ្តាលរបស់នាង ។ ចំពោះមុខកិច្ចសន្យានេះ ពុំច្បាស់ថា សុភាព យល់ព្រមជាមួយនឹងកិច្ចសន្យានោះទេ ពីព្រោះនាងមិនមែនជាភាគីនៃកិច្ចសន្យានេះឡើយ ប៉ុន្តែ រឿងនេះមិនចម្លែកអ្វីទេនៅក្នុងប្រទេសកម្ពុជា ដែលឪពុកម្តាយត្រូវកំណត់ដំណើរជីវិតរបស់កូនដោយមិនពិគ្រោះយោបល់ជាមួយកូននោះ[២៤] ។ ក្នុងករណីដែលនេះគឺជាកិច្ចសន្យាដែលទទួលស្គាល់អាយុពិតប្រាកដរបស់ សុភាព ជាការអាចធ្វើទៅបាន ដែលឪពុកម្តាយរបស់នាងធ្វើជាភាគីនៃកិច្ចសន្យានេះ មិនមែនរូបនាងទេ ។ ប៉ុន្តែ កិច្ចសន្យាធ្វើឡើងដោយផ្អែកមូលដ្ឋានលើការផ្តល់ព័ត៌មានក្លែងបន្លំថា សុភាព មានអាយុ ១៨ឆ្នាំ និងមានសមត្ថភាពផ្លូវច្បាប់ ។ ដូច្នេះ ពុំមានហេតុផលស្របច្បាប់ដើម្បីឱ្យឪពុកម្តាយរបស់នាងយល់ព្រមចំពោះលក្ខខណ្ឌនៃកិច្ចសន្យាឡើយ ។

៣.១.១១. មាត្រា ៣ នៃអនុក្រឹត្យលេខ៣៨ ចែងថា កិច្ចសន្យាមួយមានសុពលភាពទៅបាន លុះត្រាតែកិច្ចសន្យានោះមានកម្មវត្ថុមួយដែលជាក់លាក់ អាចអនុវត្តបាន ស្របច្បាប់ និងស្របតាមសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ។ មាត្រា ៥ ចែងបន្តដោយបញ្ជាក់ថា កិច្ចសន្យាមួយត្រូវមោឃៈ ក្នុងករណីដែលកម្មវត្ថុមិនអាចអនុវត្តបាន និង/ឬផ្ទុយនឹងផលប្រយោជន៍សង្គម ឬរំលោភសីលធម៌សង្គម ។ កិច្ចសន្យាមួយដែលចុះហត្ថលេខាដោយភាគីពីរដែលកំណត់កាតព្វកិច្ច និងលក្ខខណ្ឌការងាររបស់ភាគីទីបី (ដែលមិនមែនជាភាគីនៃកិច្ចសន្យា) អាចទាញហេតុផលថា ខ្វះនូវសមាសភាគនៃភាពជាក់លាក់ដែលបង្កើតជាកិច្ចសន្យាមានសុពលភាព ។ ជាងនេះទៅទៀត និងដូចដែលបានពិភាក្សានៅក្នុង *ផ្នែកទី៥* នៅក្នុងរបាយការណ៍នេះ ការបង្ខាំងខ្លួនដោយគ្មានសិទ្ធិអំណាចស្របច្បាប់គឺជាអំពើខុសច្បាប់ ដូច្នេះហើយ សមាសភាគនេះនៃកិច្ចសន្យានឹងត្រូវចាត់ទុកជាមោឃៈ (នៅក្រោមមាត្រា ៣ អនុក្រឹត្យលេខ ៣៨) ដោយសារតែកិច្ចសន្យានេះមានគោលបំណងបង្កើតកាតព្វកិច្ចសន្យាអោយគោរពតាមអំពើឧក្រិដ្ឋ[២៥] ។

**កិច្ចព្រមព្រៀងឱ្យខ្ចីប្រាក់**

៣.១.១២. កិច្ចសន្យានឹងត្រូវចាត់ទុកជាមោឃៈ នៅពេលដែលកិច្ចសន្យានោះផ្ទុយទៅនឹងផលប្រយោជន៍សង្គម និងរំលោភសីលធម៌សង្គម[២៦] ។ អាស្រ័យលើកាលៈទេសៈនីមួយៗ ជាការសមហេតុផលក្នុងការនិយាយថា ការភ្ជាប់កាតព្វកិច្ចឱ្យមនុស្សម្នាក់ធ្វើការងារដើម្បីសងបំណុលរបស់ជនដទៃ គឺផ្ទុយទៅនឹងផលប្រយោជន៍សង្គម និងរំលោភសីលធម៌មិ

---

[២៤] Kirst-Ashman, K *អន្តរាបថមនុស្ស សហគមន៍ អង្គការ និងក្រុម នៅក្នុងបរិយាកាសម៉ាក្រូសង្គម* (ឆ្នាំ២០០៨ Thomson, Learning Inc) ទំព័រ១៨៨។

[២៥] មាត្រា ២៥៣ ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ។

[២៦] មាត្រា ៥ អនុក្រឹត្យលេខ ៣៨ ។

សង្គម ។ ប្រសិនបើទង្វើបែបនេះត្រូវបានចាត់ទុកថាផ្ទុយទៅនឹងផលប្រយោជន៍សង្គម បញ្ហាថា តើបុគ្គលដែលពាក់ព័ន្ធនឹងកិច្ចសន្យា ជាភាគីស្ម័គ្រចិត្ត ឬអត់នៅពេលចាប់ផ្ដើមកិច្ចសន្យានោះ មិនមែនជាការសំខាន់ទេ ។

៣.១.១៣. អនុសញ្ញាអង្គការសហប្រជាជាតិ ស្ដីពីការលុបបំបាត់ទាសភាព បានឱ្យនិយមន័យការបញ្ចាំខ្លួនដោះបំណុលថាជា *"លក្ខខណ្ឌដែលកើតចេញពីការសន្យាមួយរបស់កូនបំណុល ដោយយកសេវាផ្ទាល់ខ្លួនរបស់ខ្លួន ឬសេវារបស់ជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ធ្វើជាកិច្ចធានាបំណុល ប្រសិនបើតម្លៃនៃសេវាទាំងនោះដែលវាយតម្លៃដោយសមហេតុផល មិនត្រូវបានប្រើប្រាស់ដើម្បីទូទាត់បំណុល ឬ រយៈពេលនៃសេវាទាំងនោះមិនត្រូវបានកំណត់ ហើយចរិតនៃសេវាទាំងនោះមិនត្រូវបានបញ្ជាក់"*[២៧] ។ មាត្រា ១(ឃ) តម្រូវឱ្យរដ្ឋភាគីហាមឃាត់ការអនុវត្តណាមួយ ដែលតាមរយៈការអនុវត្តនោះ កុមារអាយុក្រោម ១៨ឆ្នាំ ត្រូវបានប្រគល់ដើម្បីរង្វាន់ក្ដី ឬមិនមែនក្ដី សម្រាប់គោលបំណងកេងប្រវ័ញ្ចពលកម្មកុមារ ។ មាត្រា ២(១) នៃអនុសញ្ញា ILO លេខ២៩ ស្ដីពីពលកម្មដោយបង្ខំ ចែងថា ពលកម្មដោយបង្ខំគឺជាការងារ ឬសេវាណាមួយ ដែលទទួលបានពីជនណាម្នាក់នៅក្រោមការគំរាមកំហែងដោយទណ្ឌកម្មណាមួយ ហើយដែលជននោះមិនបានផ្ដល់ដោយស្ម័គ្រចិត្តដោយខ្លួនឯង[២៨] ។ បន្ថែមពីលើនេះ សេចក្ដីណែនាំស្ដីពីការជ្រើសរើស បណ្ដុះបណ្ដាល ផ្ញើរ និងគ្រប់គ្រងពលករខ្មែរដើម្បីទៅធ្វើការនៅក្រៅប្រទេស ចែងថា ពលកម្មដោយបង្ខំ និងការធ្វើការងារដើម្បីដោះបំណុល ត្រូវបានហាមឃាត់[២៩] ។

៣.១.១៤. ដូច្នេះហើយ ទោះបីជាកិច្ចព្រមព្រៀងឱ្យខ្ចីប្រាក់នេះជាភ័ស្តុតាងនៃការបញ្ចាំខ្លួនដោះបំណុល ឬការអនុវត្តធ្ងន់ធ្ងរតិចជាងនេះ ដែលមិនត្រូវបានគ្របដណ្ដប់ដោយអនុសញ្ញាអន្តរជាតិក្ដី ឬមិនមែនក្ដី ច្បាស់ណាស់ កិច្ចព្រមព្រៀងបែបនេះនៅតែជាការអនុវត្តមួយ ដែល MOLVT បានកំណត់ថា ត្រូវហាមឃាត់ ដូច្នេះ ការអនុវត្តបែបនេះផ្ទុយទៅនឹងផលប្រយោជន៍ និងសីលធម៌សង្គម ។ ដោយសារមូលហេតុនេះ គេអាចទាញហេតុផលដោយសមស្របថា កិច្ចព្រមព្រៀងបែបនេះអាចត្រូវចាត់ទុកជាមោឃៈ ។

**ការធ្វេសប្រហែស**

---

[២៧] មាត្រា ១(ក) អនុសញ្ញាបំពេញបន្ថែមនៃអង្គការសហប្រជាជាតិ ស្ដីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ ព្រមទាំងស្ថាប័ន និងការអនុវត្តដែលស្រដៀងទៅនឹងទាសភាព ។

[២៨] អនុសញ្ញាលេខ ២៩ របស់ ILO ស្ដីពីពលកម្មដោយបង្ខំ (ឆ្នាំ១៩៣០) ។

[២៩] កថាខណ្ឌ ៦ : សេង សក្តា "របាយការណ៍នៃកិច្ចប្រជុំដែលធ្វើឡើងនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ នៅឯសាលប្រជុំនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីសេចក្ដីណែនាំស្ដីពីការជ្រើសរើសពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស" (ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០) ។

៣.១.១៥. ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧)[៣០] ដែលចូលជាធរមាននាពេលថ្មីៗ កន្លងទៅនេះ រួមមានសមាសភាគដែលអាច ប្រើប្រាស់ប្រឆាំងនឹង RAs ។ ឧទាហរណ៍មួយ គឺបទល្មើសនៃសេចក្តីធ្វេសប្រហែស ។ មាត្រា ៧៤២ ចែងថា ការធ្វេសប្រហែសត្រូវបានបង្កឡើង នៅពេលដែលជនណាម្នាក់ប្រព្រឹត្តអំពើមួយ ដែលទាក់ទងនឹង *"(១) ជនម្នាក់ ដែលមានវិជ្ជាជីវៈ ឬបទពិសោធន៍ ដូចគ្នានឹងអ្នកប្រព្រឹត្ត អាចបានដឹងមុនថា លទ្ធផលជាក់លាក់មួយនឹងកើតចេញពីអំពើនោះ ប៉ុន្តែ អ្នកប្រព្រឹត្តមិនបានដឹងមុនពីលទ្ធផលដោយសារតែការខ្វះការប្រុងប្រយ័ត្ន និង (២) អ្នកប្រព្រឹត្តមានកាតព្វកិច្ចត្រូវបញ្ចៀសការកើតឡើងនូវលទ្ធផលបែបនេះ ប៉ុន្តែ ធ្វេសប្រហែសមិនបានបំពេញកាតព្វកិច្ចនោះ"* ។ បទល្មើសធ្វេសប្រហែស មានន័យថា បន្ថែមពីលើដំណោះស្រាយតាមច្បាប់ព្រហ្មទណ្ឌ និងតាមកិច្ចសន្យាប្រឆាំងនឹង RAs ក្នុងករណីដែល RA ប្រព្រឹត្តដោយមិនសមហេតុផលនៅក្នុងដំណើរការជ្រើសរើស ហើយគេអាចដឹងមុនថា ការប្រព្រឹត្តមិនសមហេតុផលរបស់ RA នោះ នឹងបង្កឱ្យមានគ្រោះថ្នាក់ RA ត្រូវទទួលខុសត្រូវបង់សំណងជំងឺចិត្តដែលកើតចេញពីគ្រោះថ្នាក់នោះ ។ នេះអាចរាប់បញ្ចូលទាំងទង្វើធ្វេសប្រហែស នៃការជ្រើសរើសជនណាម្នាក់ ដែលមិនអាចយល់អំពីអ្វីដែលខ្លួនបានព្រមព្រៀង នៅក្រោមកិច្ចសន្យា ។

**ការសន្និដ្ឋាន**

៣.១.១៦. ក្នុងករណីដែលគេអាចបង្ហាញថា មេខ្យល់កំពុងកេងប្រយោជន៍ពីកង្វះការអប់រំ/អនក្ខរភាពរបស់គ្រួសារ សុភាព អំពើនេះអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្រោមមាត្រា ៣៨៣ នៃក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) "ការកេងប្រយោជន៍ពីភាពទន់ខ្សោយ" ។ ដូចគ្នានេះដែរ ក្រមរដ្ឋប្បវេណី រួមបញ្ចូលនូវបទប្បញ្ញត្តិមួយនៅត្រង់មាត្រា ៣៤៩ អំពីការបំពានកាលៈទេសៈ ដែលចែងថា ក្នុងករណីដែលភាគីមួយប្រើប្រាស់ស្ថានភាពសេដ្ឋកិច្ច ឬឋានៈសង្គមរបស់ខ្លួន ដើម្បីឱ្យ

[៣០] ច្បាប់អនុវត្តសម្រាប់ក្រមរដ្ឋប្បវេណី ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០ ហើយក្រមរដ្ឋប្បវេណីនេះចូលជាធរមាននៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១ (សូមមើលកំណត់សម្គាល់លេខ ១៧ ខាងលើ) ។

រឿងទី១ របស់ សំនៀង

សំនៀង អាយុ ២១ឆ្នាំ ។ គាត់ធ្វើការជាកម្មករ ហើយរកប្រាក់បាន១,៥ ដុល្លារក្នុងមួយថ្ងៃ ។ គាត់ត្រូវបានមិត្តភក្តិម្នាក់ ណែនាំឱ្យជួបជាមួយមេខ្យល់ ដែលនិយាយថា គេអាចរកការងារឱ្យ សំនៀង ធ្វើនៅក្នុងរោងចក្រកែច្នៃត្រីមួយ នៅក្នុងប្រទេសថៃ ដែល សំនៀង អាចរកប្រាក់បានដល់ទៅ ២៥០ដុល្លារ ក្នុងមួយខែ ។ សំនៀង ពុំមានលិខិតឆ្លងដែនទេ ប៉ុន្តែមេខ្យល់បានប្រាប់គាត់ ថា គាត់មិនចាំបាច់មានលិខិតឆ្លងដែនឡើយ ។ សំនៀង ធ្វើដំណើរទៅដល់ក្រុងមួយនៅជាប់ព្រំដែនថៃ ហើយស្នាក់នៅក្នុងផ្ទះសំណាក់មួយ ជាមួយនឹងបុរស ៨នាក់ទៀត ដែលមេខ្យល់រូបនេះបានជ្រើសរើស ។ ព្រឹកឡើង គាត់ប្រគល់ប្រាក់ ១០០ដុល្លារ ឱ្យទៅមេខ្យល់ ហើយជិះម៉ូតូឌុប ទៅដល់ព្រំដែនថៃ រួចហើយក៏ឆ្លងកាត់ព្រំដែន ដោយធ្វើរជើង ។ នៅទីនោះ រថយន្តមួយគ្រឿងបានរង់ចាំគាត់ ហើយដឹកគាត់ទៅកាន់ផ្ទះសំណាក់មួយ នៅក្នុងក្រុងដែលនៅជិតនោះ ។

ភាគីម្ខាងទៀតមិនអាចជំទាស់ទៅនឹងរូបមន្តកិច្ចសន្យា ភាគីម្ខាងទៀតនេះ អាចលុបចោលកិច្ចសន្យានោះបាន ។ ចំណុចទាំងនេះ ត្រូវបានពិភាក្សា នៅក្នុង*ផ្នែកទី៩* ។

## ៣.២. រឿងរបស់ សំនៀង

### ការជ្រើសរើស

៣.២.១. ភាពស្របច្បាប់នៅក្នុងការជ្រើសរើសពលករសម្រាប់ការងារកសិកម្ម នៅក្នុងប្រទេសថៃ មានកម្រិតខុសៗគ្នា ។ RAs មួយចំនួន ត្រូវបានផ្តល់អាជ្ញាប័ណ្ណពេញលេញ និងអនុវត្តគ្រប់ជ្រុងជ្រោយទៅតាមលក្ខខណ្ឌតម្រូវ សម្រាប់ការបណ្តុះបណ្តាល ការដឹកជញ្ជូនដោយស្របច្បាប់ និងលក្ខខណ្ឌតម្រូវសម្រាប់ទិដ្ឋាការចូលប្រទេសថៃ ។ ប៉ុន្តែ រឿងរបស់ សំនៀង ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីភាពខុសច្បាប់នៃអំពើកេងប្រវ័ញ្ច ដែលអនុវត្តដោយអ្នកជ្រើសរើសពលករខុសច្បាប់ ។

៣.២.២. រឿងរបស់សំនៀង បង្ហាញអំពីការប្រែក្លាយយ៉ាងរហ័សពីចំណាកស្រុកទៅជាបទល្មើសព្រហ្មទណ្ឌនៃការជួញដូរមនុស្ស ។ ពិធីសារអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសអំពើជួញដូរស្ត្រី និងកុមារ (ឆ្នាំ២០០០) ("ពិធីសារ Palermo") ចែងថា រដ្ឋភាគីត្រូវផ្តន្ទាទោសអំពើជ្រើសរើស និងដឹកជញ្ជូន ដោយមធ្យោបាយបោកបញ្ឆោតសម្រាប់គោលដៅកេងប្រវ័ញ្ច ។ ប្រទេសកម្ពុជាបានដាក់បញ្ចូលលក្ខខណ្ឌតម្រូវនេះ នៅក្នុង LSHTSE ដែលផ្តន្ទាទោសអំពើជួញដូរមនុស្ស (សូមមើលប្រអប់នៅខាងស្តាំ) ។

៣.២.៣. ប៉ុន្តែ ការរៀបចំបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងអំពើជួញដូរ ក្នុងកាលៈទេសៈបែបនេះ មានការលំបាក ។ ការលំបាកចម្បង គឺថា មនុស្សជាច្រើន ដែលពាក់ព័ន្ធនៅក្នុងការធ្វើចំណាកស្រុកមិនប្រក្រតីដើម្បីការងារ រវាងប្រទេសកម្ពុជា និងប្រទេសថៃ គឺមានមូលដ្ឋានស្ថិតនៅក្នុងប្រទេសថៃ ។ អ្នកដែលត្រូវគេជ្រើសរើស នឹងជួបប្រាស្រ័យទាក់ទងជាមួយមនុស្សតែម្នាក់ ឬ ពីរនាក់ប៉ុណ្ណោះ ដែលអាចនាំខ្លួនមកផ្តន្ទាទោសនៅក្នុងយុត្តាធិការរបស់ប្រទេសកម្ពុជាបាន[៣១] ។ បញ្ហានេះពុំត្រូវបានជួយដោយ MoU ជាមួយប្រទេសថៃ

**LSHTSE ឆ្នាំ២០០៨ :**

មាត្រា ៨ : និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់ : *ការធ្វើឱ្យមនុស្សម្នាក់ ផ្លាស់ទីពីកន្លែងដែលគេកំពុងរស់នៅ ទៅកាន់ទីកន្លែងដទៃ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន តាមមធ្យោបាយបង្ខិតបង្ខំ គំរាមកំហែង បោកបញ្ឆោត បំពានអំណាច ឬល្បួងលោម ។*

មាត្រា ១១ : ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន : *ក្នុងគោលដៅប្រគល់ ឬនាំយកជននោះទៅក្រៅព្រះរាជាណាចក្រកម្ពុជា ។*

មាត្រា ១២ : ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់ការកេងប្រវ័ញ្ច : *ការបញ្ចុះបញ្ចូល ការជួល ឬការឱ្យជនណាម្នាក់បម្រើការ ក្រោមទម្រង់ជាការកេងប្រវ័ញ្ចផ្សេងទៀត តាមមធ្យោបាយបោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគំរាមកំហែង ឬមធ្យោបាយបង្ខិតបង្ខំផ្សេងទៀត ។*

មាត្រា១៣/១៤ : អំពើលក់-ដូរមនុស្ស: *ការប្រគល់ឱ្យដោយខុស នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ។*

មាត្រា ១៥/១៦ : អំពើលក់-ដូរមនុស្សដោយមានគោលដៅ/សម្រាប់នាំឆ្លងដែន

មាត្រា ១៧/១៨ : ការដឹកជញ្ជូនដោយមានគោលដៅ/អំពើនាំឆ្លងដែន

---

[៣១] មានសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីបត្យាប័ន (ឆ្នាំ១៩៩៨) ។

ឡើយ ពីព្រោះកិច្ចព្រមព្រៀងនេះអនុវត្តចំពោះតែអំពើជួញដូរស្ត្រី និង កុមារប៉ុណ្ណោះ[៣២] ។ ដូច្នេះ នៅពេលដែលបុរសដែលត្រូវបានជួញដូរវិលត្រឡប់មកដល់កម្ពុជាវិញ លទ្ធភាពដែលគាត់អាចតាមដានរកមុខសញ្ញាមេខ្យល់ ឬមេខ្យល់ដែលជ្រើសរើសគាត់ គឺមានតិចតួចណាស់ ។

៣.២.៤. ការលំបាកមួយទៀតក្នុងការរៀបចំពាក្យបណ្តឹងព្រហ្មទណ្ឌបែបនេះ គឺពាក្យពេចន៍នៃមាត្រានានានៅក្នុងច្បាប់ LSHTSE ។ ដើម្បីបញ្ជាក់អំពីបទល្មើសជួញដូរ គ្រប់មាត្រាសំខាន់ៗទាំងអស់តម្រូវឱ្យមានសមាសភាគខ្លះៗនៃឥរិយាបថមិនស្របច្បាប់ - ការជ្រើសរើសដោយមិនស្របច្បាប់ ការនាំយកចេញដោយមិនស្របច្បាប់ និង/ឬការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ទៅអោយជនដទៃដោយមិនស្របច្បាប់ ។ នៅក្នុងនិយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់នៅត្រង់មាត្រា ៨ នៃច្បាប់ LSHTSE លក្ខខណ្ឌតម្រូវ គឺថា ការនាំយកចេញត្រូវធ្វើឡើងដោយមធ្យោបាយ *"បង្ខិតបង្ខំ គំរាមកំហែង បោកបញ្ឆោត បំពានអំណាច ឬល្បួងលោម"* ។ សមាសភាគទាំងនេះហើយ ដែលធ្វើឱ្យសកម្មភាពមួយខុសច្បាប់សម្រាប់គោលបំណងរបស់ LSHTSE ។ ប៉ុន្តែ ចំពោះរឿងរបស់ សំនៀង រហូតដល់ចំណុចដែលគាត់ត្រូវបានដាក់ថ្នាំសណ្តំនៅក្នុងប្រទេសថៃ (សូមមើលរឿងទី២ របស់សំនៀង នៅទំព័រទី ៣៣) គាត់បាននិងកំពុងស្វះស្វែងធ្វើចំណាកស្រុកដោយមិនស្របច្បាប់ដោយស្ម័គ្រចិត្ត ។ តើនៅចំណុចណា ដែលចំណាកស្រុកខុសច្បាប់ដោយស្ម័គ្រចិត្តប្រែក្លាយទៅជាបទល្មើសព្រហ្មទណ្ឌនៃការជួញដូរ ? Chen Chen Lee ធ្វើការបង្ហាញអំពីសំណួរនេះនៅក្នុងដ្យាក្រាមខាងក្រោមនេះ[៣៣] ។

| | | |
|---|---|---|
| | លទ្ធផលល្អនៃការរត់ពន្ធ/ជួញដូរ | ការកេងប្រវ័ញ្ចពលកម្ម ជនរងគ្រោះនៃអំពើជួញដូរ |
| ខុសច្បាប់ | ឯកសារក្លែងបន្លំ<br>អាចមានការបង្ខិតបង្ខំ/បោកបញ្ឆោត<br>ប្រាក់ឈ្នួលត្រូវបានផ្តល់ឱ្យ<br>ការងារ/ការរស់នៅសមរម្យ<br>សេរីភាពក្នុងការធ្វើដំណើរ | ឯកសារក្លែងបន្លំ/គ្មានឯកសារ<br>ការបង្ខិតបង្ខំ ឬបោកបញ្ឆោត<br>ពលកម្មដោយបង្ខំ |
| | ចំណាកស្រុកដែលមានសុវត្ថិភាព និងសណ្តាប់ធ្នាប់ | លទ្ធផលអាក្រក់នៃចំណាកស្រុកស្របច្បាប់<br>ការកេងប្រវ័ញ្ចពលកម្ម ជនរងគ្រោះនៃអំពើជួញដូរ |
| ស្របច្បាប់ | ឯកសារត្រឹមត្រូវ<br>ប្រាក់ឈ្នួលត្រូវបានផ្តល់ឱ្យ<br>ការងារ/ការរស់នៅសមរម្យ<br>សេរីភាពនៃការធ្វើដំណើរ | ឯកសារត្រឹមត្រូវ<br>អាចមានការបង្ខិតបង្ខំ<br>ពលកម្មដោយបង្ខំ |
| | **គ្មានគ្រោះថ្នាក់** | **គ្រោះថ្នាក់ (ការកេងប្រវ័ញ្ច)** |

[៣២] MoU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីសម្រាប់ការលុបបំបាត់អំពើជួញដូរស្ត្រី និងកុមារ និងការជួយជនរងគ្រោះនៃអំពើជួញដូរ (ឆ្នាំ២០០៣) ។

[៣៣] Commit "ការសិក្សាអំពីការអនុវត្តបែបកេងប្រវ័ញ្ចនៃជើងសារជ្រើសរើសពលករ នៅកម្ពុជា" (ខែមីនា ឆ្នាំ២០០៧) ។

៣.២.៥. រឿងរបស់ សំនៀង ស្ថិតនៅក្នុងប្រភេទ "មិនស្របច្បាប់" និង "កេងប្រវ័ញ្ច" ។ ពិតណាស់ថា គាត់ស្វែងរកការងារនៅក្នុងប្រទេសថៃដោយស្ម័គ្រចិត្ត ប៉ុន្តែ គាត់នឹងមិនទំនងជាបន្តធ្វើដូច្នេះទៀតឡើយ ប្រសិនបើគាត់ដឹងថា នៅទីបំផុត គាត់នឹងជាប់នៅលើទូកនេសាទធ្វើការដោយមិនបានទទួលប្រាក់ឈ្នួលនោះ ។ ក្នុងន័យនេះ ការបោកបញ្ឆោតអាចទាក់ទងទៅនឹងប្រភេទនៃការងារដែលនឹងត្រូវធ្វើ និងលក្ខខណ្ឌនៃការងារនោះ[៣៤] ។ សមាសភាគនៃការបោកបញ្ឆោតក្នុងនាមមេខ្យល់នេះហើយ ដែលប្រែក្លាយសកម្មភាពរបស់ពួកគេទៅជាបទល្មើសជួញដូរ ។ ដូច្នេះហើយ អំពើបោកបញ្ឆោតនេះ គឺគ្រប់គ្រាន់នៅក្នុងនិយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់ ដែលតម្រូវថា មនុស្សម្នាក់ត្រូវបាននាំយកចេញពីកន្លែងដែលគេកំពុងរស់នៅ តាមមធ្យោបាយបោកបញ្ឆោត (ក្នុងចំណោមមធ្យោបាយផ្សេងទៀត) និងដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកប្រព្រឹត្ត (ឬការគ្រប់គ្រងរបស់តតិយជន)[៣៥] ។ មាត្រា ១០ នៃ LSHTSE ផ្តន្ទាទោសអំពើបែបនេះឱ្យជាប់ពន្ធនាគារពី ៧ ដល់ ១៥ឆ្នាំ នៅពេលដែលបទល្មើសនេះត្រូវបានប្រព្រឹត្តក្នុងគោលដៅកេងប្រវ័ញ្ចលើជនរងគ្រោះ ។ ដូចគ្នានេះដែរ នៅក្នុងការផ្តល់ភ័ស្តុតាងអំពីអំពើបោកបញ្ឆោត សំនៀង នឹងអាចបញ្ជាក់អំពីបទល្មើសនៃការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ការនាំឆ្លងដែន[៣៦] ។ មាត្រាសមស្របជាងនេះមួយទៀត សម្រាប់ឧទាហរណ៍នេះ គឺមាត្រា ១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់ការកេងប្រវ័ញ្ច ដែលអាចបញ្ជាក់ដោយផ្តល់ភ័ស្តុតាងបង្ហាញថា ជនល្មើសបានជ្រើសរើសជនរងគ្រោះឱ្យចូលរួមនៅក្នុងការកេងប្រវ័ញ្ចតាមមធ្យោបាយបោកបញ្ឆោត ។

### រឿងទី៣ របស់ សុភាព

សុភាព ត្រូវបានភ្នាក់ងារនាំទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាលនៅក្នុងរាជធានីភ្នំពេញ ជាមួយក្មេងស្រីដទៃទៀត ដែលត្រូវបានជ្រើសរើស ។ នៅក្នុងមជ្ឈមណ្ឌល សុភាព ត្រូវបានបង្រៀនជំនាញនានាដែលនាងនឹងត្រូវការចាំបាច់សម្រាប់ការងារបម្រើក្នុងផ្ទះ ព្រមទាំងភាសាអង់គ្លេសខ្លះៗ ។ នាងត្រូវបានផ្តល់អាហារតិចតួច និងចាក់សោរទុកនៅក្នុងរោងមួយ ជាមួយនឹងក្មេងស្រី ៣០០នាក់ផ្សេងទៀត ។ ***នាងមិនត្រូវបានអនុញ្ញាតឱ្យចេញក្រៅឡើយ ហើយឪពុកម្តាយរបស់នាងមិនមកសួរសុខទុក្ខនាងទេ*** ។ នាងត្រូវបានគេប្រាប់ថា ឪពុកម្តាយរបស់នាងពុំមានប្រាក់ដើម្បីធ្វើដំណើរមករាជធានីភ្នំពេញទេ ។ គេមិនអនុញ្ញាតឱ្យនាងទូរស័ព្ទទៅឪពុកម្តាយរបស់នាងទេ ។ សុភាព ស្តាប់ឮរឿងរ៉ាវពីក្មេងស្រីដទៃទៀតថា លក្ខខណ្ឌនៅប្រទេសម៉ាឡេស៊ី អាក្រក់ណាស់ ។ នាងនិយាយជាមួយគ្រូរបស់នាង ដែលផ្តល់លេខទូរស័ព្ទរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីឱ្យនាង ហើយឱ្យនាងហៅទូរស័ព្ទទៅលេខនោះ ប្រសិនបើនាងត្រូវការជំនួយ ។ គ្រូមិនបានត្រឡប់មកធ្វើការទៀតឡើយ ។ សុភាព ឃើញថា បន្ទាប់ពីការបណ្តុះបណ្តាលរយៈពេល៣ខែ ក្មេងស្រីខ្លះទៅធ្វើការនៅក្នុងផ្ទះរបស់គ្រូ ។ នាងស្តាប់ឮរឿងថា ក្មេងស្រីដទៃទៀតត្រូវធ្វើការជាស្រីពេស្យារហូតដល់ពេលដែលពួកនាងមានការងារធ្វើនៅក្នុងប្រទេសម៉ាឡេស៊ី ។ ***សុភាព ចង់ចាកចេញ ប៉ុន្តែ ត្រូវគេប្រាប់ថា ឪពុកម្តាយនាងត្រូវតែសងប្រាក់ ៥០០ដុល្លារឱ្យទៅភ្នាក់ងារវិញ ប្រសិនបើនាងចាកចេញ*** ។ សុភាព ដឹងថា ឪពុកម្តាយរបស់នាងនឹងគ្មានលទ្ធភាពសងប្រាក់វិញឡើយ ។

[៣៤] Lara Fergus របាយការណ៍ ACSSA លេខ៥ "ការជួញដូរស្ត្រីសម្រាប់ការធ្វើអាជីវកម្មផ្លូវភេទ" (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៥) ទំព័រ ៦ ។

[៣៥] មាត្រា ៨ LSHTSE (ឆ្នាំ២០០៨) ។

[៣៦] មាត្រា ១១ LSHTSE (ឆ្នាំ២០០៨) ។

## ៤. ការបណ្តុះបណ្តាល/ការស្នាក់អាស្រ័យ/ការដឹកជញ្ជូន




### ៤.១. រឿងរបស់ សុភាព

**ការបង្ខាំងខ្លួនក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល**

៤.១.១. សុភាព ស្ថិតនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលរយៈពេល ៣ខែ ដោយមិនត្រូវបានអនុញ្ញាតឱ្យចេញក្រៅឡើយ ។ ជារឿយៗ RAs/មជ្ឈមណ្ឌលបណ្តុះបណ្តាល នឹងទាញហេតុផលថា ការអនុញ្ញាតឱ្យក្មេងស្រីចេញក្រៅទៅណាមកណាដោយខ្លួនឯង គឺជារឿងដែលគ្រោះថ្នាក់ ពីព្រោះពួកគេទើបតែមកទីក្រុងជាលើកដំបូង ហើយមិនស្គាល់ភ្នំពេញទេ ។ RAs ក៏អាចយោងទៅលើលក្ខខណ្ឌនៃកិច្ចសន្យា ដែលចែងថា ពលករិនីនឹងមិនត្រូវបានអនុញ្ញាតឱ្យចេញពីមជ្ឈមណ្ឌលឡើយ ។ ប៉ុន្តែ ការសន្និដ្ឋានដោយផ្អែកតាមព័ត៌មានគ្រប់គ្រាន់ គឺថា មូលហេតុចម្បងសម្រាប់ការបង្ខាំងក្មេងស្រីនៅក្នុងមជ្ឈមណ្ឌលគឺដើម្បី RAs អាចការពារវិនិយោគទុនរបស់ខ្លួន ។ ប្រសិនបើក្មេងស្រីត្រូវបានអនុញ្ញាតឱ្យចាកចេញ ពួកគេអាចនឹងមិនត្រឡប់មកវិញ ហើយ RAs នឹងខាតបង់ប្រាក់ដែលបានចំណាយទៅលើការបណ្តុះបណ្តាល ការស្នាក់អាស្រ័យ និងបែបបទឯកសារសម្រាប់ការធ្វើចំណាកស្រុក រហូតមកទល់នឹងចំណុចនោះ ។

៤.១.២. មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[៣៧] ធានាថា *"ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ... គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបាន*

[៣៧] កតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឆ្នាំ១៩៩៦) ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅក្នុងខែឧសភា ឆ្នាំ១៩៩២ ។

*ឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"* ។ ប្រការនេះត្រូវបានចែងជាថ្មីម្តងទៀតនៅក្នុងមាត្រា ១៦(៤) នៃអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីការការពារសិទ្ធិពលករចំណាកស្រុកគ្រប់រូប និងសមាជិកគ្រួសារ (CMW) ដែលចែងថា ពលករចំណាកស្រុកមិនត្រូវបានដកហូតសេរីភាពឡើយ[៣៨] ។ បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងនេះ ត្រូវបានសរសេរចូលទៅក្នុងច្បាប់ជាតិ ក្នុងមាត្រា ២១ នៃ LSHTSE ។ ចាប់តាំងពីការប្រកាសឱ្យប្រើប្រាស់ក្រមព្រហ្មទណ្ឌមក បទល្មើសបង្ខាំងមនុស្ស ត្រូវផ្តន្ទាទោសទៅតាមមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ ។ មាត្រានេះ ចែងថា *"ជនណាម្នាក់ដែលចាប់ឃុំឃាំង ឬ បង្ខាំងជនដទៃដោយគ្មានបញ្ជាពីអាជ្ញាធរដែលមានអំណាចតាមផ្លូវច្បាប់ ឬលើកលែងតែក្នុងករណីដែលមានចែងដោយច្បាប់"* នឹងត្រូវផ្តន្ទាទោស ។ នៅក្នុងក្រមព្រហ្មទណ្ឌ ឬពាក្យពេចន៍នៃមាត្រានេះ ពុំមានត្រង់ណា ដែលគួសបញ្ជាក់ថា លក្ខខណ្ឌកិច្ចសន្យាមួយអាចចាត់ទុកជា *"អំណាចតាមផ្លូវច្បាប់"* ឬ *"ចែងដោយច្បាប់"* ឬថា លក្ខខណ្ឌនៃកិច្ចសន្យា គឺជាភ័ស្តុតាងដោះបន្ទុកគ្រប់គ្រាន់សម្រាប់បទល្មើសនេះនោះឡើយ ។ ដូច្នេះ ភាគីមួយដែលមានសមត្ថភាពតាមផ្លូវច្បាប់ដែលស្ម័គ្រចិត្តចុះកិច្ចសន្យាមួយ ដែលចែងអំពីរយៈពេលនៃការបង្ខាំងខ្លួន មិនអាចចងភ្ជាប់កាតព្វកិច្ចដោយលក្ខខណ្ឌនោះបានឡើយ ពីព្រោះការបង្ខាំងខ្លួនគឺជាអំពើមិនស្របច្បាប់ ដូច្នេះ លក្ខខណ្ឌនៃកិច្ចសន្យាដែលចែងអំពីការបង្ខាំងខ្លួន គឺគ្មានសុពលភាពឡើយ[៣៩] ។

៤.១.៣. ទោះបីជាថា កាតព្វកិច្ចអន្តរជាតិនេះត្រូវបានសរសេរចូលនៅក្នុងច្បាប់ជាតិរបស់ប្រទេសកម្ពុជាក្តី គេគួរកត់សម្គាល់ថា សន្ធិសញ្ញាអន្តរជាតិដែលត្រូវបានផ្តល់សច្ចាប័នរួចអាចអនុវត្តដោយផ្ទាល់ និងពឹងផ្អែកបាននៅក្នុងតុលាការកម្ពុជាដោយមិនចាំបាច់ត្រូវតែមានច្បាប់ជាតិដែលទាក់ទងនោះឡើយ ។ ដូច្នេះ ក្នុងករណីដែលសន្ធិសញ្ញាអន្តរជាតិមួយត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជា ការរំលោភលើមាត្រាណាមួយនៃសន្ធិសញ្ញានោះ អាចឱ្យជនរងគ្រោះនៃការរំលោភបែបនោះ ប្រើប្រាស់ជាមូលដ្ឋានច្បាប់បាន[៤០] ។

៤.១.៤. នៅក្នុងការពិចារណាទៅលើការបង្ខាំងខ្លួនពលករក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល ជាការសំខាន់ គឺត្រូវញែកឱ្យដាច់ពីគ្នារវាងកាតព្វកិច្ចកិច្ចសន្យា និងអំពើឧក្រិដ្ឋ ។ ពុំមានហេតុផលដោះបន្ទុកចំពោះការបង្ខាំងខ្លួនក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលសម្រាប់ការងារនៅក្រៅប្រទេសឡើយ ។ សិក្ខាកាមគ្រប់រូបមានសិទ្ធិមានសេរីភាព ។ ក្នុង

[៣៨] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារសិទ្ធិពលករចំណាកស្រុកគ្រប់រូប និងសមាជិកគ្រួសារ (ឆ្នាំ១៩៩០) ដែលចុះហត្ថលេខាដោយកម្ពុជានៅក្នុងខែកញ្ញា ឆ្នាំ២០០៤ ។

[៣៩] មាត្រា ៣ អនុក្រឹត្យលេខ ៣៨ (ឆ្នាំ១៩៩៨) ។

[៤០] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា *សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧* (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ។

ករណីដែលសិក្ខាកាមមានបំណងចាកចេញពីមជ្ឈមណ្ឌលបណ្តុះបណ្តាល (ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍) ពួកគេគួរតែមានសេរីភាពធ្វើដូច្នេះបាន ។ ប្រសិនបើនៅពេលចាកចេញ សិក្ខាកាមរំលោភកិច្ចសន្យារបស់ខ្លួន ជាមួយនឹង RA នោះ RA មានសិទ្ធិប្តឹងទាមទារតាមកិច្ចសន្យាប្រឆាំងនឹងសិក្ខាកាម ។ ប៉ុន្តែ RA មិនអាចបង្ខាំងខ្លួនសិក្ខាកាមដោយខុសច្បាប់ ដើម្បីទប់ស្កាត់ការរំលោភកិច្ចសន្យាបានឡើយ[៤១] ។

៤.១.៥. ដោយសារ សុភាព ជាអនីតិជន RA និងជនដែលបង្ខាំងខ្លួននាងនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល ក៏អាចនឹងប្រឈមមុខផងដែរ ចំពោះការផ្តន្ទាទោសនៅក្រោមមាត្រា ៣៣៧ នៃក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ដោយសារបានប្រព្រឹត្ត"អំពើបង្អត់អាហារ និងការថែទាំសម្រាប់អនីតិជនអាយុក្រោម ១៥ឆ្នាំ" ។ ដើម្បីដាក់បន្ទុកបទល្មើសនេះ សុខភាពរបស់ សុភាព នឹងចាំបាច់ត្រូវធ្វើឱ្យមានគ្រោះថ្នាក់ដោយសារស្ថានភាពរបស់នាង ។ ពុំមានច្បាប់សមមូលនៅក្នុងសៀវភៅច្បាប់ជាធរមាន ដែលអនុវត្តចំពោះការប្រព្រឹត្តចំពោះមនុស្សពេញវ័យឡើយ ។ ដូច្នេះ សិក្ខាកាមដែលប្រឈមមុខនឹងប្រព្រឹត្តកម្មអមនុស្សធម៌ អាចស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ប្រឆាំងនឹង RA ដោយប្រើច្បាប់អន្តរជាតិ ឧ. ICCPR ដែលចែងថា *"គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាបឡើយ"*[៤២] ។

៤.១.៦. ក្នុងកាលៈទេសៈដែលមជ្ឈមណ្ឌលបណ្តុះបណ្តាលមិនមែនគ្រប់គ្រងនិងដំណើរការដោយ RA ប៉ុន្តែ ត្រូវបានចុះកិច្ចសន្យាម៉ៅការបន្ត (ជាផ្លូវការនិងជាលាយលក្ខណ៍អក្សរក្តី ឬផ្សេងពីនេះក្តី) ទៅឱ្យបុគ្គលម្នាក់ទៀត ឬសហគ្រាសមួយផ្សេងទៀត ករណីបែបនេះ ការផ្តន្ទាទោសបទល្មើសនឹងត្រូវអនុវត្តប្រឆាំងនឹងអ្នកដែលគ្រប់គ្រង និងដំណើរការមជ្ឈមណ្ឌលបណ្តុះបណ្តាល មិនមែន RA ឡើយ ។ នេះគឺជាមូលហេតុមួយទៀត ដែលជនរងគ្រោះនៃការធ្វើចំណាកស្រុកមិនប្រក្រតីនឹងទទួលបានផលប្រយោជន៍ពីការពង្រឹងច្បាប់ស្តីពីទីភ្នាក់ងារ និងការផ្តល់អាជ្ញាប័ណ្ណដល់ភាគីទីបីដែលពាក់ព័ន្ធនៅក្នុងការជ្រើសរើស ។

**ការបណ្តុះបណ្តាល**

៤.១.៧. បច្ចុប្បន្ន ពុំមានបទដ្ឋានអប្បបរមាសម្រាប់ឱ្យមជ្ឈមណ្ឌលបណ្តុះបណ្តាលត្រូវគោរពតាមឡើយ ។ ជាពិសេស ពុំមានកម្មវិធីបទដ្ឋានដែលគ្រប់គ្រងខ្លឹមសារនៃការបណ្តុះបណ្តាលទេ ហើយបទដ្ឋានសម្រាប់លក្ខខណ្ឌនៃមជ្ឈមណ្ឌលបណ្តុះបណ្តាល ក៏ពុំមានដែរ ។ មានតែបទប្បញ្ញត្តិនៅក្នុងអនុក្រឹត្យលេខ ៥៧ និងប្រកាសលេខ ១០៨ ដែលចែងថា RA

---

[៤១] មាត្រា ២០ អនុសញ្ញាអន្តរជាតិនៃអង្គការសហប្រជាជាតិ ស្តីពីការការពារសិទ្ធិពលករចំណាកស្រុកគ្រប់រូប និងសមាជិកគ្រួសារ : *"គ្មានពលករចំណាកស្រុកណាម្នាក់ ត្រូវជាប់ពន្ធនាគារដោយសារតែហេតុផលនៃការខកខានមិនបានបំពេញកាតព្វកិច្ចនៃកិច្ចសន្យាឡើយ"* ។

[៤២] មាត្រា ៧ ICCPR (ឆ្នាំ១៩៩៦) ។

ត្រូវទទួលខុសត្រូវចំពោះការបណ្តុះបណ្តាលពលករអំពីប្រព័ន្ធការងារ ទំនៀមទម្លាប់ប្រពៃណី និងច្បាប់ជាមូលដ្ឋានរបស់ប្រទេសដែលពលករនឹងទៅបម្រើការងារ[៤៣] និងថា ពលករត្រូវទទួលការបណ្តុះបណ្តាលអំពីបញ្ហាសុខភាពចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិការងារ[៤៤] ។ អនុក្រឹត្យលេខ៥៧ ចែងថា ទាំង MoLVT និង RA ត្រូវទទួលខុសត្រូវចំពោះការបណ្តុះបណ្តាលពលករ[៤៥] ។ ប៉ុន្តែជាការអនុវត្តជាក់ស្តែង RA ទទួលខុសត្រូវលើការបណ្តុះបណ្តាល ហើយ MoLVT ធ្វើអធិការកិច្ចម្តងម្កាល ។ ចំណុចនេះក៏មានចែងនៅក្នុងមាត្រា ៥ នៃប្រកាសលេខ ១០៨ ផងដែរ ដែលចែងថា មន្ត្រីអធិការកិច្ចមកពីនាយកដ្ឋានហត្ថពលិក និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀតរបស់ MoLVT នឹងចុះធ្វើអធិការកិច្ច ដើម្បីធានាថា RAs គោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការបណ្តុះបណ្តាល ។

៤.១.៨. ប៉ុន្តែ ការរកឃើញនៃរបាយការណ៍នេះបង្ហាញថា មន្ត្រីអធិការកិច្ចនឹងផ្តល់ការជូនដំណឹងដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលអំពីការចុះត្រួតពិនិត្យដែលគ្រោងទុករបស់ខ្លួន ដូច្នេះ វាមិនច្បាស់លាស់ទេថា តើការបណ្តុះបណ្តាលដែលពិនិត្យឃើញដោយមន្ត្រីអធិការកិច្ច គឺជាការបណ្តុះបណ្តាលដែលអនុវត្តប្រចាំថ្ងៃ ឬអត់នោះឡើយ ។ ប្រកាស ១០៨ ទោះជាលិខិតបទដ្ឋានដែលមានលក្ខណៈលម្អិតជាង ស្តីពីការបណ្តុះបណ្តាលពលករដែលទៅធ្វើការនៅក្រៅប្រទេសក្តី ពុំបានធ្វើការភ្ជាប់ទំនាក់ទំនងរវាងការផ្តល់អាជ្ញាប័ណ្ណដល់ RAs ជាមួយនឹង លក្ខខណ្ឌតម្រូវនៃការបណ្តុះបណ្តាលឡើយ ។ អនុក្រឹត្យលេខ៥៧ គ្រាន់តែចែងយោងថា ជនទាំងឡាយដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយរំលោភអនុក្រឹត្យនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ដែលមានស្រាប់[៤៦] ។ ដូច្នេះ ពុំមានភាពច្បាស់លាស់ទេថា តើនៅពេលណាទើបសកម្មភាព/បទដ្ឋាននៃការបណ្តុះបណ្តាលរបស់ RA នឹងត្រូវចាត់ទុកថា មានកម្រិតទាបជាងលក្ខខណ្ឌតម្រូវនៃប្រកាស ឬអនុក្រឹត្យនេះ ហើយក៏ពុំមានការចែងច្បាស់លាស់អំពីទោសទណ្ឌ ដែល RA នឹងប្រឈមមុខក្នុងករណីដែលការបណ្តុះបណ្តាលរបស់ខ្លួនត្រូវបានរកឃើញថា មានកម្រិតទាបជាងលក្ខខណ្ឌតម្រូវរបស់ប្រកាស (ការពិន័យ ការព្យួរអាជ្ញាប័ណ្ណ ការរឹតត្បិតអាជ្ញាប័ណ្ណ) ឬអំពីវិធានការអ្វីដែលគេងនឹងចាំបាច់ត្រូវអនុវត្តដើម្បីដោះស្រាយបញ្ហាខ្វះចន្លោះណាមួយដែលគេរកឃើញ ។

---

[៤៣] មាត្រា ១៤ អនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥) ។

[៤៤] មាត្រា ៣ ប្រកាសលេខ ១០៨ (ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦) ។

[៤៥] មាត្រា ១៤ អនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥)

[៤៦] មាត្រា ២០ អនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥)

## ៤.២. រឿងរបស់ សំនៀង

### ការស្នាក់អាស្រ័យនៅក្នុងផ្ទះសំណាក់

៤.២.១. រួមជាមួយនឹងមេខ្យល់ មានចារីផ្សេងទៀតដែលអាចត្រូវមានទោសពីបទល្មើសព្រហ្មទណ្ឌនៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយ សំនៀង ។ មាត្រា ១៩ LSHTSE ចែងថា ជនណាដែលផ្តល់ជម្រកដល់ជនណាមួយដែលបានមកពីអំពើនាំយកចេញ ឬដឹកជញ្ជូនដោយមិនស្របច្បាប់ ក្នុងគោលដៅដើម្បីកេងប្រវ័ញ្ច ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី ៧ ដល់ ១៥ឆ្នាំ ។ មាត្រានេះ អាចអនុវត្តចំពោះជនដែលគ្រប់គ្រងផ្ទះសំណាក់នៅលើព្រំដែនកម្ពុជា ។ ប៉ុន្តែ ដើម្បីដាក់បន្ទុកទៅលើបទល្មើសនេះ ភ័ស្តុតាងនឹងត្រូវការចាំបាច់ដើម្បីបង្ហាញថា ជនដែលគ្រប់គ្រងផ្ទះសំណាក់បានដឹងអំពីអំពើកេងប្រវ័ញ្ចដែលគ្រោងទុក ។ ការបញ្ជាក់ថាពួកគេបានដឹងអំពីចេតនារបស់ សំនៀង ក្នុងការឆ្លងដែនទៅរកការងារ គឺពុំគ្រប់គ្រាន់ឡើយ ។

### ការដឹកជញ្ជូនទៅកាន់ព្រំដែន

៤.២.២. ការពិត គោលដៅចុងក្រោយបង្អស់សម្រាប់ សំនៀង គឺធ្លាក់ទៅក្នុងទាសភាពនៅលើទូកនេសាទថៃ ។ ដូច្នេះ អំពើនេះ ត្រូវបានគ្របដណ្តប់ដោយអនុសញ្ញាបំពេញបន្ថែមរបស់អង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់ទាសភាព[៤៧] ដែលចែងថា រដ្ឋភាគីត្រូវផ្តន្ទាទោសអំពើដឹកនាំទាសករពីប្រទេសមួយទៅប្រទេសមួយទៀត ដោយមធ្យោបាយដឹកជញ្ជូន ឬអំពើជាអ្នកសមគំនិតក្នុងការប្រព្រឹត្តបទល្មើសនេះ ។

៤.២.៣. លើសពីនេះទៅទៀត ពិធីសារអង្គការសហប្រជាជាតិប្រឆាំងការរត់ពន្ធជនចំណាកស្រុកតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស (ឆ្នាំ២០០០)[៤៨] តម្រូវឱ្យរដ្ឋភាគីផ្តន្ទាទោសបទឧក្រិដ្ឋ នៃការរត់ពន្ធជនចំណាកស្រុកដែលត្រូវបានកំណត់ និយមន័យថាជា *"ការនាំមកឱ្យនូវការចូលដោយ*

**រឿងទី២ របស់ សំនៀង**

សំនៀង ត្រូវបានដាក់ថ្នាំសណ្តំនៅក្នុងផ្ទះសំណាក់ក្នុងទឹកដីថៃ ហើយភ្ញាក់ឡើងនៅលើទូកនេសាទរបស់ថៃ នៅក្នុងសមុទ្រ ។ គាត់ត្រូវបានបង្ខំឱ្យធ្វើការ ២១ម៉ោង ក្នុងមួយថ្ងៃ និងប្រាប់ថាគេនឹងសម្លាប់គាត់ចោល ប្រសិនបើគាត់មិនធ្វើតាមទេនោះ ។ នៅលើទូកនេសាទនោះ គាត់ធ្វើការជាមួយបុរសខ្មែរ ៤០នាក់ផ្សេងទៀត ដែលត្រូវបានជ្រើសរើស តាមវិធីដូចគ្នានឹងគាត់ដែរ ។ សំនៀង គ្មានឯកសារ ហើយ គ្មានប្រាក់ទេ ។ នៅពេលដែលទូកចូលចតនៅកំពង់ផែ បុរសទាំងនេះត្រូវបានចាក់សោរឃុំទុក នៅក្នុងឃ្លុបនៅបាតទូក ។ ពួកគេបរិភោគបាយជាមួយនឹងសម្លតិចតួច ដែលសុទ្ធតែទឹក ។ បុរសម្នាក់ក្នុងចំណោមបុរសទាំងនេះធ្លាក់ខ្លួនឈឺ ។ នៅពេលដែលគេដឹងច្បាស់ថា បុរសនោះមិនជាសះស្បើយទេនោះ គេបានបោះគាត់ចោលក្នុងទឹកទាំងកណ្តាលយប់ ។ ជម្រើសតែមួយគត់សម្រាប់ សំនៀង គឺត្រូវតែ លួចរត់ចេញ ។

---

[៤៧] អនុសញ្ញាបំពេញបន្ថែមរបស់អង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ និងស្ថាប័ន និងការអនុវត្តស្រដៀងទៅនឹងទាសភាព ។

[៤៨] ត្រូវបានផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា នៅខែធ្នូ ឆ្នាំ២០០៥ ។

*ខុសច្បាប់របស់ជនម្នាក់ទៅក្នុងរដ្ឋភាគីមួយ ដែលជននោះមិនមែនជាពលរដ្ឋ ឬអ្នកមានលំនៅអចិន្ត្រៃយ៍ ដើម្បីទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍ជាសម្ភារៈដទៃទៀត ដោយផ្ទាល់ ឬដោយប្រយោល*" ។

៤.២.៤. ក្រៅពីសមាសភាគនៃការរត់ពន្ធ និងទាសភាព មាត្រា ១៧ នៃ LSHTSE "ការដឹកជញ្ជូនដោយមានគោលដៅ" ផ្តន្ទាទោសជនណាដែលដឹកជញ្ជូនជនដទៃ ដោយដឹងថាជននោះត្រូវបាននាំយកចេញ ឬដឹកជញ្ជូនដោយមិនស្របច្បាប់ សម្រាប់គោលដៅកេងប្រវ័ញ្ច ។ ក្នុងករណីដែលមានភ័ស្តុតាងបញ្ជាក់ថា អ្នកបើកម៉ូតូឌុបបានដឹងអំពីការបោកបញ្ឆោត និងការកេងប្រវ័ញ្ចដែលគ្រោងទុកទៅលើ សំនៀង គេអាចស្វែងរកការផ្តន្ទាទោសពីបទព្រហ្មទណ្ឌនៅក្រោមមាត្រានេះបាន ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង គេបានឃើញនៅក្នុងករណីជាច្រើនដែលថា ភ័ស្តុតាងនៃអំពើដឹកជញ្ជូនតែមួយមុខ ជាការគ្រប់គ្រាន់ក្នុងការទទួលបានការផ្តន្ទាទោសតាមមាត្រានេះ ។ នេះមិនមែនជាលទ្ធផលដែលគេចង់បាននៅក្នុងករណីជាច្រើនឡើយ ពីព្រោះថា ការផ្តន្ទាទោសអ្នកបើកម៉ូតូឌុប អាចត្រូវបានគេប្រើប្រាស់ជារង្វាន់លួងចិត្តសម្រាប់កង្វះនៃការផ្តន្ទាទោសតួអង្គសំខាន់ជាងនេះច្រើនទៀត នៅក្នុងករណីជួញដូរ ។

## ៥. ការឆ្លងកាត់/ការមកដល់ក្នុងប្រទេសទទួល




### ៥.១. រឿងរបស់ សុភាព

**ការក្លែងបន្លំឯកសារដើម្បីដំឡើងអាយុរបស់ សុភាព ទៅជា ២១ឆ្នាំ**

៥.១.១. នៅកម្ពុជា ដើម្បីមានសិទ្ធិត្រូវគេជ្រើសរើសទៅធ្វើការនៅក្រៅប្រទេស ពលករត្រូវតែមានអាយុ ១៨ឆ្នាំ[៤៩] ។ ប៉ុន្តែដើម្បីធ្វើការជាអ្នកបម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ពលករត្រូវតែមានអាយុ២១ឆ្នាំឡើងទៅ[៥០] ។ ដូច្នេះ ប្រសិនបើ សុភាព គ្រប់អាយុដែលអាចត្រូវគេជ្រើសរើសនៅក្នុងប្រទេសកម្ពុជា ឧ. ១៨ឆ្នាំ នាងនៅតែមិនមានសិទ្ធិធ្វើការងារនៅក្នុងប្រទេសម៉ាឡេស៊ីដដែល ។ តាមរយៈករណីសិក្សាមួយចំនួនដែលប្រមូលបានដោយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅក្នុងប្រទេសកម្ពុជា គេបានរកឃើញថា នៅពេលផ្តល់ឱ្យនូវក្មេងស្រីអាយុក្រោម ២១ឆ្នាំ ការឆ្លើយតបរបស់ RAs គឺក្លែងបន្លំឯកសារអត្តសញ្ញាណរបស់ពួកគេ និងធ្វើលិខិតឆ្លងដែន និងសុំទិដ្ឋាការដោយផ្អែកតាមព័ត៌មានក្លែងក្លាយនោះ ។

---

[៤៩] អនុក្រឹត្យលេខ ៥៧ (១៩៩៥) ។

[៥០] លក្ខខណ្ឌតម្រូវនៃច្បាប់អន្តោប្រវេសន៍របស់ប្រទេសម៉ាឡេស៊ី ។

៥.១.២. ពិធីសារ Palermo ដាក់លក្ខខណ្ឌតម្រូវឱ្យរដ្ឋភាគីធានាថា ឯកសារធ្វើដំណើរ និងអត្តសញ្ញាណត្រូវមានគុណភាពល្អ ដែលមិនអាចប្រើប្រាស់ខុស ឬក្លែងបន្លំបានឡើយ[៥១] ។ នៅក្នុងករណីសិក្សាដែលវិភាគដោយរបាយការណ៍នេះ ជារឿយៗ គេរកឃើញថា ឯកសារអត្តសញ្ញាណសំខាន់ចាំបាច់ត្រូវបានក្លែងបន្លំដើម្បីទទួលបានលិខិតឆ្លងដែន និងទិដ្ឋាការដោយស្របច្បាប់ ។ ដូច្នេះ លិខិតឆ្លងដែន និងទិដ្ឋាការ គឺស្របច្បាប់ ។ ក្នុងករណីដែលពលករ ឬគ្រួសាររបស់នាងមិនបានដឹងអំពីការផ្លាស់ប្តូរនៅក្នុងឯកសារអត្តសញ្ញាណ និងលិខិតឆ្លងដែនរបស់នាងទេនោះ RAs អាច

**ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ការបោកប្រាស់/ក្លែងបន្លំ**

- មាត្រា ៣៧៧ : និយមន័យនៃការបោកប្រាស់

*ការបោកប្រាស់ គឺជាអំពើបោកបញ្ឆោតរូបវន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់ ដោយប្រើប្រាស់ឈ្មោះក្លែងក្លាយ ដោយការអះអាងអំពីឋានៈក្លែងក្លាយ ឬដោយការប្រើប្រាស់បំពានឋានៈពិតប្រាកដ ។*

- មាត្រា ៦២៦ : ធាតុផ្សំនៃអំពើក្លែងបន្លំ

*ការក្លែងបន្លំ គឺជាអំពើដោយចេតនាដើម្បីធ្វើឱ្យខូចការពិត ដែលស្តែងឡើងតាមរយៈអក្សរ ឬតាមមធ្យោបាយសម្តែងមតិផ្សេងទៀត ប្រសិនបើលក្ខខណ្ឌដូចតទៅនេះត្រូវបានបំពេញ : ការបង្ខូចនោះ មានកម្មវត្ថុ ឬអាចនឹងមានអំណាចជាភ័ស្តុតាងនៃសិទ្ធិ ឬអំពើមួយ ដែលមានផលវិបាកតាមផ្លូវតុលាការ ឬការបង្ខូចនោះ អាចនឹងបង្កការខូចខាត ។*

- មាត្រា ៦២៨ : ការប្រើប្រាស់ឯកសារក្លែងបន្លំ
- មាត្រា ៦២៩ : ការក្លែងបន្លំឯកសារសាធារណៈ
- មាត្រា ៦៣០ : ការប្រើប្រាស់ឯកសារសាធារណៈក្លែងបន្លំ
- មាត្រា ៦៣១ : ការផ្តល់ឯកសារដោយក្លែងបន្លំ

*អំពើនៃការផ្តល់ឯកសារដល់ជនដទៃ ដោយក្លែងបន្លំ ។*

- មាត្រា ៦៣៦ : ការប្រើប្រាស់លិខិតបញ្ជាក់ក្លែងក្លាយ ឬក្លែងបន្លំ
- មាត្រា ៦៣៧ : សំណូកដែលទទួលយកដោយជនដែលមានសិទ្ធិចេញឯកសារក្លែងបន្លំ ។
- មាត្រា ៦៣៨ : សំណូកដែលផ្តល់ដល់ជនដែលមានសិទ្ធិចេញឯកសារក្លែងបន្លំ ។

[៥១] មាត្រា ១២ ពិធីសារ Palermo (ឆ្នាំ២០០០) ។

ប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ តាមមាត្រាដែលមានចែងនៅក្នុងប្រអប់ខាងក្រោមនេះ ។ បន្ថែមលើនេះ ច្បាប់ប្រឆាំងអំពើពុករលួយថ្មីនឹងចែងអំពីមាត្រានានាដែលបំពេញបន្ថែមលើមាត្រាទាំងឡាយនៅក្នុងក្រមព្រហ្មទណ្ឌ ឧ. មាត្រា ៣៤ ស្តីពីការសូកប៉ាន់មន្ត្រីសាធារណៈ មាត្រា ៤៣ អំពើពុករលួយកម្រិតស្រាល មាត្រា ៤៥ ទោសទណ្ឌបន្ថែមដែលអាចអនុវត្តចំពោះបទល្មើសពុករលួយ ។ ប៉ុន្តែ បញ្ហាកើតមាននៅពេលដែលពលករ និង/ឬ គ្រួសាររបស់នាង ដឹងនិង/ឬបានជាប់ពាក់ព័ន្ធដោយលក្ខណៈណាមួយ នៅក្នុងការផ្លាស់ប្តូរនោះ ។ ការពិតរបាយការណ៍នេះបានរកឃើញថា នៅក្នុងករណីភាគច្រើន RAs ធ្វើយ៉ាងណាឱ្យប្រាកដថា ពលករ និង/ឬគ្រួសាររបស់ពួកគេដឹងអំពីការបន្លំ/ការក្លែងបន្លំនេះ ដើម្បីបង្ហាញថា ពួកគេក៏មានការជាប់ពាក់ព័ន្ធដែរ ក្នុងករណីមានការផ្តន្ទាទោសតាមច្បាប់ណាមួយ ។ ជម្រើសដែលមានសម្រាប់ពលករ/គ្រួសារ នៅក្នុងស្ថានភាពនេះ ត្រូវបានពិភាក្សានៅក្នុង*ផ្នែកទី៨ បណ្តឹង : នីតិវិធី/ដំណោះស្រាយតាមផ្លូវច្បាប់* ខាងក្រោម ។

**លិខិតឆ្លងដែន និងទិដ្ឋាការ**

៥.១.៣. អនុក្រឹត្យលេខ ៣៩ (ឆ្នាំ២០០៩) ចែងថា ថ្លៃធ្វើលិខិតឆ្លងដែនសម្រាប់ពលករចំណាកស្រុកត្រូវបន្ថយត្រឹម ២០ ដុល្លារ និងថា ការចេញលិខិតឆ្លងដែនត្រូវពន្លឿនក្នុងរយៈពេល ២០ថ្ងៃ[៥២] ។ ប៉ុន្តែ ជាក់ស្តែង គឺមានមន្ត្រីប្រហែលជា ៧៥នាក់តែប៉ុណ្ណោះដែលធ្វើការនៅក្នុងការិយាល័យលិខិតឆ្លងដែន នៅក្រោមនាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែន ដូច្នេះ ភាពជាក់ស្តែងនៃការចេញលិខិតឆ្លងដែនឱ្យក្នុងរយៈពេល ២០ថ្ងៃ ក្នុងតម្លៃ ២០ដុល្លារសម្រាប់លិខិតឆ្លងដែនមួយនោះ គឺមិនទំនងជាធ្វើបានឡើយ ។ ដូច្នេះ RAs ភាគច្រើនបង់ប្រាក់បន្ថែមទៅឱ្យការិយាល័យនេះ ដើម្បីទទួលបានលិខិតឆ្លងដែនឆាប់រហ័ស (ជារឿយៗ បង់ថ្លៃដល់ទៅ ១៥០ដុល្លារ) ។ នៅទីបំផុត ថ្លៃចំណាយនេះធ្លាក់ទៅលើពលករ ក្នុងរូបភាពជាប្រាក់ជំពាក់ដែលពួកគេត្រូវសងទៅឱ្យ RA វិញ ។

**ការឆ្លងកាត់ចូលប្រទេសម៉ាឡេស៊ី**

៥.១.៤. មាត្រា ១១ នៃពិធីសារ Palermo ចែងថា រដ្ឋភាគីត្រូវពង្រឹងការត្រួតពិនិត្យព្រំដែនដើម្បីទប់ស្កាត់អំពើជួញដូរ ។ បច្ចុប្បន្ន អាជ្ញាធរប្រទេសម៉ាឡេស៊ីបាននិងកំពុងថ្លែងការពារការចូលនៃអនិតិជនដោយផ្អែកលើលិខិតឆ្លងដែនក្លែងបន្លំ ដោយនិយាយថា ពួកគេមិនអាចទទួលខុសត្រូវឡើយ ពីព្រោះលិខិតឆ្លងដែនមានភាពត្រឹមត្រូវតាមច្បាប់ ។ ដោយគ្មាន MoU ឬកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា និងម៉ាឡេស៊ី ការដាក់កាតព្វកិច្ចអន្តរជាតិដែលបានទទួលយល់ព្រម ទៅលើពួកគេ គឺជាការលំបាក ។ ប៉ុន្តែ ចំណុចនេះនឹងជាចំណុចសមស្របសម្រាប់ដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងបែបនេះ ពីព្រោះរបាយការណ៍ពីអង្គការក្រៅរដ្ឋាភិបាលគូសបញ្ជាក់ថា ក្មេងស្រីវ័យជាង១០ឆ្នាំ ក្នុង

[៥២] អនុក្រឹត្យលេខ ៣៩ ដែលកែប្រែអនុក្រឹត្យលេខ ១៩៥ (ឆ្នាំ២០០៨) ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាដល់ពលករកម្ពុជាដែលទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ (ឆ្នាំ២០០៩) ។

ចំនួនកាន់តែច្រើនឡើង កំពុងឆ្លងកាត់ច្រកអន្តោប្រវេសន៍ម៉ាឡេស៊ីប្រកបដោយជោគជ័យ ដោយផ្អែកលើលិខិតឆ្លងដែនក្លែងបន្លំ ដែលដាក់អាយុពួកគេ ២១ឆ្នាំ ឬលើសពីនេះ ។

៥.១.៥. មាត្រា ២.៤ នៃនីតិវិធីសម្រាប់ពលរដ្ឋកម្ពុជាធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី (ឆ្នាំ១៩៩៩) ចែងថា និយោជក (នៅក្នុងប្រទេសម៉ាឡេស៊ី) ចេញថ្លៃសំបុត្រធ្វើដំណើររបស់ពលករពីច្រកចេញនៅក្នុងប្រទេសកម្ពុជា ទៅដល់ច្រកចូលនៅក្នុងប្រទេសម៉ាឡេស៊ី និងថា និយោជកសងថ្លៃចំណាយលើការធ្វើដំណើររបស់ពលករពីទីកន្លែងដើមទៅចំណុចច្រកចេញ ។ ប៉ុន្តែ ឯកសារនេះមិនអនុវត្តចំពោះអ្នកបម្រើការតាមផ្ទះ ដែលភាគច្រើនជាពលករចំណាកស្រុកនៅក្នុងប្រទេសម៉ាឡេស៊ីឡើយ ។

## ៥.២. រឿងរបស់ សំនៀង

## ការធ្វើចំណាកស្រុកដោយស្របច្បាប់ទៅប្រទេសថៃ

៥.២.១. មូលហេតុចម្បងមួយក្នុងចំណោមមូលហេតុចម្បងនានាដែលថា មានលទ្ធភាពបែបនេះសម្រាប់ការជួញដូរ និងរត់ពន្ធមនុស្សឆ្លងដែនទៅកាន់ប្រទេសថៃ គឺថា ផ្លូវស្របច្បាប់នៃការធ្វើចំណាកស្រុកដើម្បីការងារពោរពេញទៅដោយការលំបាក និងចំណាយប្រាក់អស់ច្រើន ។

៥.២.២. ដើម្បីធ្វើការនៅក្នុងប្រទេសថៃ ពលករត្រូវតែមានលិខិតឆ្លងដែន និងទិដ្ឋាការ ។ ថ្លៃចំណាយជាមធ្យមសម្រាប់ការបញ្ជូនពលករចំណាកស្រុកទៅធ្វើការនៅប្រទេសថៃតាមរយៈមធ្យោបាយស្របច្បាប់ គឺប្រហែល ៧០០ដុល្លារ បើប្រៀបធៀបទៅនឹងថ្លៃចំណាយប្រហែល ១០០ដុល្លារសម្រាប់ការធ្វើចំណាកស្រុកខុសច្បាប់[៥៣] ។ ជាងនេះទៅទៀត ការអនុវត្តជាក់ស្តែងនៅតាមព្រំដែនមានភាពមិនស៊ីសង្វាក់គ្នាទេ ហើយមានកន្លែងផ្សេងៗ ដែលអាចប្រើប្រាស់ជាច្រកឆ្លងកាត់ដោយខុសច្បាប់បាន ។ នេះមានន័យថា ពលករជាច្រើនសម្រេចចិត្តបង់ប្រាក់ ១០០ដុល្លារ ដើម្បីធ្វើចំណាកស្រុកតាមផ្លូវមិនស្របច្បាប់ ជាជាងចំណាយប្រាក់ឈ្នួលរបស់ពួកគេដោយធ្វើចំណាកស្រុកតាមផ្លូវដែលចំណាយប្រាក់អស់ច្រើន ។

[៥៣] ច័ន្ទ សុផល ការិយាល័យ ILO ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក *របាយការណ៍ស្តីពីគោលនយោបាយគ្រប់គ្រងចំណាកស្រុកដើម្បីការងារ និងក្របខ័ណ្ឌគតិយុត្តិនៅក្នុងប្រទេសកម្ពុជា* (ខែឧសភា ឆ្នាំ២០០៩) ។

៥.២.៣. ជាមួយគ្នានេះ ក៏មានការរិះគន់ថា លិខិតឆ្លងដែនដែលចេញឱ្យពលករចំណាកស្រុកមានចំនួនទំព័រតិចណាស់ ដែលនាំឱ្យពលករចាំបាច់ត្រូវធ្វើលិខិតឆ្លងដែនថ្មីកាន់តែច្រើនដង ។ ប្រការនេះ គឺជាបញ្ហា ជាពិសេសចំពោះពលករដែលទៅធ្វើការនៅប្រទេសថៃ ដែលតម្រូវឱ្យបន្តទិដ្ឋាការរយៈពេល ៦ខែម្តង[៥៤] ។

## ៥.៣. សេចក្តីសន្និដ្ឋាន

៥.៣.១. ជនចំណាកស្រុកដែលធ្វើដំណើរតាមច្រកមិនប្រក្រតី និង/ឬពលករចំណាកស្រុកដែលមានឯកសារមិនស្របច្បាប់ នឹងត្រូវប្រឈមនឹងការផ្តន្ទាទោសជាជនអន្តោប្រវេសន៍ខុសច្បាប់ តាមច្បាប់អន្តោប្រវេសន៍នៃប្រទេសទទួល ។ នៅក្នុងប្រទេសថៃ ច្បាប់ដែលពាក់ព័ន្ធ គឺច្បាប់អន្តោប្រវេសន៍ ព.ស. ២៥២២ ហើយនៅក្នុងប្រទេសម៉ាឡេស៊ី គឺច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៥៩/៦៣ ដែលច្បាប់ទាំងពីរនេះហាមឃាត់ការចូលក្នុងប្រទេសទាំងនេះដោយគ្មានសិទ្ធិអំណាចស្របច្បាប់ ។ ការចាប់ខ្លួននៅក្រោមច្បាប់ទាំងនេះ អាចនាំទៅដល់ការឃុំខ្លួន ការផ្តន្ទាទោស (ក្នុងនោះរាប់បញ្ចូលទាំងការវាយនឹងរំពាត់ នៅក្នុងប្រទេសម៉ាឡេស៊ី) និងការនិរទេស នៅទីបំផុត (ជារឿយៗ ភាគីដែលត្រូវបានចាប់ខ្លួន ត្រូវចេញសោហ៊ុយចំណាយ) ។

---

[៥៤] អនាមិក "លិខិតឆ្លងដែនកម្ពុជាដ៏តូចតឿត្បៀតបង្កទុក្ខលំបាកដល់ពលករចំណាកស្រុកខ្មែរដែលធ្វើការនៅប្រទេសថៃ" (ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០) អាចរកមើលនៅឯ : http://ki-media.blogspot.com/2010/11/skimpy-cambodian-passport-caused-grief.html ដែលបើកមើលនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

## ៦. លក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល




### ៦.១. ទូទៅ

៦.១.១. បទដ្ឋានអប្បបរមាអន្តរជាតិស្តីពីកិច្ចសន្យាការងារសម្រាប់ពលករចំណាកស្រុក ពុំទាន់មាននៅឡើយ ហើយខណៈដែលប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីពលករចំណាកស្រុក ប្រទេសថៃ និងម៉ាឡេស៊ី ពុំបានចុះហត្ថលេខាលើអនុសញ្ញានេះឡើយ[៥៥] ។ អនុសញ្ញា ILO ស្តីពីចំណាកស្រុកដើម្បីការងារ (វិសោធនកម្ម) អនុសញ្ញា (ឆ្នាំ១៩៤៩) អនុសញ្ញា (បំពេញបន្ថែម) ស្តីពីពលករចំណាកស្រុក (ឆ្នាំ១៩៧៥) និងអនុសាសន៍ស្តីពីពលករចំណាកស្រុក (ឆ្នាំ១៩៧៥) ផ្តល់អនុសាសន៍អំពីលក្ខខណ្ឌការងារ ។ ប៉ុន្តែ គ្មានអនុសញ្ញាណាមួយក្នុងចំណោមអនុសញ្ញាទាំងនេះ ត្រូវបានចុះហត្ថលេខាដោយប្រទេសកម្ពុជា ឬប្រទេសទទួលសំខាន់ទាំងពីរនេះឡើយ ។ ដូច្នេះហើយ ពលករត្រូវបានភ្ជាប់កាតព្វកិច្ចដោយលក្ខខណ្ឌនៃកិច្ចសន្យារបស់ពួកគេ និងច្បាប់ការងារនៅក្នុងប្រទេសទទួល ។

---

[៥៥] ប្រសិនបើបានធ្វើដូច្នេះរួចហើយនោះ ប្រទេសទាំងនេះនឹងត្រូវមានកាតព្វកិច្ចនៅក្រោមមាត្រា ២៥ CMW ដើម្បីធានាថា ពលករចំណាកស្រុកទទួលបានលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌដែលអនុវត្តចំពោះពលរដ្ឋរបស់ប្រទេសនេះផងដែរ ។

៦.១.២. អនុក្រឹត្យលេខ ៥៧ ចែងថា កិច្ចសន្យាការងារមិនត្រូវលើសពី ២ឆ្នាំទេ[៥៦] ចែងថា ពលករត្រូវមានសិទ្ធិទទួលបានថ្ងៃឈប់សម្រាកដែលទទួលបានប្រាក់ឈ្នួលពី RAs ១ថ្ងៃកន្លះក្នុងមួយខែ[៥៧] និងចែងអំពីលក្ខខណ្ឌជាក់លាក់សម្រាប់កិច្ចសន្យាការងារ[៥៨] ។ ប៉ុន្តែ នេះគឺជាដែនកំណត់នៃច្បាប់កម្ពុជា ទាក់ទងនឹងកិច្ចសន្យាសម្រាប់ពលករចំណាកស្រុក ។ ជាងនេះទៅទៀត ក្នុងករណីដែល RA ខកខានមិនបានផ្តល់កិច្ចសន្យា ដែលអនុលោមតាមអនុក្រឹត្យលេខ ៥៧នេះ ទេនោះ ពុំមានការចែងច្បាស់លាស់អំពីថា តើទោសទណ្ឌអ្វី (ប្រសិនបើមាន) ដែល RA ត្រូវទទួលពី MOLVT ។ ជាមួយគ្នានេះ ក៏មិនច្បាស់លាស់ដូចគ្នាថា តើការឈប់សម្រាកប្រចាំខែនេះត្រូវពង្រឹងការអនុវត្តយ៉ាងដូចម្តេច ។

៦.១.៣. ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ CMW ប៉ុន្តែ អនុសញ្ញានេះជួយជាចម្បងដល់ជនដែលធ្វើចំណាកស្រុកចូលមកប្រទេសកម្ពុជា ជាជាងដល់ពលរដ្ឋកម្ពុជាដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ។ ប៉ុន្តែ មាត្រា ៣៧ ដាក់កាតព្វកិច្ចឱ្យប្រទេសប្រភពផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយដល់ពលករចំណាកស្រុក អំពីលក្ខខណ្ឌនៃការធ្វើចំណាកស្រុករបស់ពួកគេ និងលក្ខខណ្ឌតម្រូវដែលពួកគេត្រូវតែបំពេញនៅក្នុងប្រទេសដែលពួកគេធ្វើការងារ ។ អនុសញ្ញានេះ មិនដាក់កាតព្វកិច្ចឱ្យប្រទេសប្រភពកំណត់បទដ្ឋានអប្បបរមា ឬតាមដានពលករចំណាកស្រុករបស់ខ្លួនដែលធ្វើការនៅក្រៅប្រទេសឡើយ ។

---

[៥៦] មាត្រា ១១ អនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥) ។

[៥៧] មាត្រា ១០ អនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥) ។

[៥៨] មាត្រា ៩ អនុក្រឹត្យលេខ ៥៧ (ឆ្នាំ១៩៩៥) ។

៦.១.៤. ក្នុងករណីដែលលក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល ខុសពី (មានបទដ្ឋានទាបជាង)លក្ខខណ្ឌដែលបានអះអាងដោយ RA ហើយមានភ័ស្តុតាងបញ្ជាក់ថា RA បានដឹងថា លក្ខខណ្ឌនឹងខុសគ្នា ពលករអាចប្តឹង RA ដើម្បីលុបចោលកិច្ចសន្យា ដោយឈរលើមូលដ្ឋាននៃការអះអាងផ្ទុយពីការពិត (និងអាចជាការឆបោក) នៅក្រោមមាត្រា ៧ និង/ឬមាត្រា ១០ នៃអនុក្រឹត្យលេខ ៣៨[៥៩] ។ មាត្រា ៧ ចែងថា កិច្ចព្រមព្រៀងមួយដែលជាលទ្ធផលនៃកំហុស ការបង្ខិតបង្ខំ ឬការបោកបញ្ឆោត មិនមែនជាកិច្ចព្រមព្រៀងដែលមានសុពលភាពឡើយ ។ មាត្រា ១០

### រឿងទី៤ របស់ សុភាព

បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលរយៈពេល ៣ខែ ***សុភាព ត្រូវបានជូនឡើងយន្តហោះធ្វើដំណើរទៅកាន់ប្រទេសម៉ាឡេស៊ី ។ គេបានឱ្យលិខិតឆ្លងដែនទៅនាង ហើយប្រាប់ឱ្យនាង និយាយថា នាងមានអាយុ ២១ឆ្នាំ*** ។ បងស្រីរបស់នាងអាយុ ១៨ឆ្នាំ នាងមិនដឹងថា ហេតុដូចម្តេចបានជាលិខិតឆ្លងដែនរបស់នាងដាក់ថា នាងអាយុ ២១ឆ្នាំនោះទេ ។ នាងទៅធ្វើការជាអ្នកបម្រើឱ្យប្តីប្រពន្ធមួយគូ ។ នាងធ្វើការបានរយៈពេល ៥ខែ ហើយពុំបានទទួលប្រាក់ខែឡើយ ។ ***គេមិនអនុញ្ញាតឱ្យនាងទុកលិខិតឆ្លងដែននៅនឹងខ្លួនទេ មិនឱ្យចេញក្រៅ ហើយថែមទាំងគ្មានទូរស័ព្ទទៀត*** ។ជាញឹកញាប់ នាងធ្វើការ ២១ម៉ោងក្នុងមួយថ្ងៃ និងគ្មានថ្ងៃឈប់សម្រាកទេ ។ ឪពុករបស់ សុភាព ទូរស័ព្ទទៅក្រុមហ៊ុន Malabour គាត់បានឮរឿងមិនល្អអំពីលក្ខខណ្ឌការងារនៅប្រទេសម៉ាឡេស៊ី ហើយចង់ឱ្យកូនស្រីរបស់គាត់ត្រឡប់មកផ្ទះវិញ ។ ពីរសប្តាហ៍នៅក្រោយការទូរស័ព្ទរបស់គាត់ ***ក្រុមហ៊ុន Malabour ផ្តល់ឯកសារមួយ ដែលចុះហត្ថលេខាដោយ សុភាព ដែលនិយាយថា នាងសុខសប្បាយជាទេ និងថា លក្ខខណ្ឌការងារគឺល្អធម្មតា*** ព្រមទាំងថា ***ឪពុករបស់ សុភាព ត្រូវតែសងប្រាក់សរុប ៨០០ដុល្លារ ឱ្យទៅក្រុមហ៊ុន Malabour ប្រសិនបើគាត់ចង់ឱ្យសុភាពត្រឡប់មកផ្ទះវិញ*** ។ គាត់គ្មានប្រាក់សងទេ ។

បន្តចែងទៀតថា ការបោកបញ្ឆោតគឺជាមូលហេតុសម្រាប់ការធ្វើមោឃភាពកិច្ចសន្យា ក្នុងករណីដែលមានអំពើបោកបញ្ឆោត ភាពមិនស្មោះត្រង់ ឬការអះអាងផ្ទុយពីការពិត ដែលប្រព្រឹត្តដោយភាគីមួយ ដែលប្រសិនបើគ្មានអំពើទាំងនេះទេ ភាគីម្ខាងទៀតនឹងមិនចុះកិច្ចសន្យាឡើយ ។ ដូច្នេះ ប្រសិនបើមានភ័ស្តុតាងបញ្ជាក់ថា RA បាននិយាយកុហកអំពីលក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល ពលករអាចប្តឹងលុបចោលកិច្ចសន្យានៅក្រោមមាត្រានេះបាន ។ អាចជាការលំបាកក្នុងការបង្ហាញភ័ស្តុតាងបញ្ជាក់ការដឹងឮរបស់ RA អំពីលក្ខខណ្ឌជាក់លាក់នៅក្នុងប្រទេសទទួល ។ ប៉ុន្តែ នៅពេលពិចារណាលើលក្ខខណ្ឌកិច្ចសន្យាជាស្តង់ដារដែលគេបានដឹងមួយ (ឧទាហរណ៍ ម៉ោងធ្វើការក្នុងមួយ

[៥៩] អនុក្រឹត្យលេខ ៣៨ ។

ថ្ងៃ) ជាការសមហេតុផលដែលបញ្ជាក់ថា RA នឹងដឹងអំពីលក្ខខណ្ឌស្តង់ដារនៅក្នុងប្រទេសទទួល ។ ដូច្នេះ ការដឹងឮដោយប្រយោលនេះ អាចផ្តល់មូលហេតុគ្រប់គ្រាន់សម្រាប់ការធ្វើបណ្តឹងទាក់ទងនឹងកិច្ចសន្យា ប្រសិនបើលក្ខខណ្ឌការងារនៅក្នុងប្រទេសទទួលខុសគ្នាខ្លាំងពីកិច្ចសន្យារបស់ពលករ ។

៦.១.៥. ក្នុងករណីដែលពលករអាចប្តឹងដើម្បីលុបចោលកិច្ចសន្យារបស់ខ្លួនជាមួយ RA ពួកគេទំនងជានឹងនៅតែស្ថិតក្រោមកិច្ចសន្យាដាច់ដោយឡែកមួយទៀត ជាមួយនឹងនិយោជកនៅក្នុងប្រទេសទទួល ។ ការធ្វើមោឃភាពកិច្ចសន្យាមួយនឹងមិនមានន័យថា កិច្ចសន្យាដែលធ្វើតាមក្រោយកិច្ចសន្យាមួយនោះ ត្រូវចាត់ទុកជាមោឃៈនោះឡើយ ។ ប៉ុន្តែប្រសិនបើពលករមានហេតុផលរឹងមាំដើម្បីលុបចោលកិច្ចសន្យារបស់ខ្លួនជាមួយនឹង RA (ដែល RA ពឹងផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យានេះ ដើម្បីទាមទារមកវិញនូវការចំណាយណាមួយដែលបានធ្វើរួច) នេះអាចជាឥទ្ធិពលដែលចាំបាច់ដើម្បីបញ្ចុះបញ្ចូល RA ឱ្យជួយដល់ពលករនៅក្នុងការកែលម្អលក្ខខណ្ឌការងាររបស់ពួកគេ ឬផ្លាស់ប្តូរនិយោជក ។ ឧទាហរណ៍ ការវែកញែកហេតុផលបែបនេះអាចអនុវត្តនៅក្នុងករណីដែល RA ព្រមព្រៀងផ្តល់ប្រាក់ឈ្នួលដែលទាបជាងប្រាក់ឈ្នួលស្តង់ដារសម្រាប់ការងារនោះនៅក្នុងប្រទេសទទួល ។

៦.១.៦. លើសពីនេះទៅទៀត ក្នុងករណីដែលគេអាចបញ្ជាក់ភ័ស្តុតាងថា មេខ្យល់/ RAs បានដឹងថា លក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល នឹងមិនអាចទទួលយកបាន ហើយប៉ះពាល់ដល់សុខភាពរបស់ពលករ មេខ្យល់/ RAs អាចប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌនៅក្រោមក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ។ មាត្រា ៣៣៩ ផ្តន្ទាទោសអំពើនៃការដាក់អនីតិជននៅក្នុងលក្ខខណ្ឌការងារ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពរបស់អនីតិជននោះ ហើយមាត្រា ២៧៤ ផ្តន្ទាទោសអំពើនៃការដាក់ជនណាម្នាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌការងារ ដែលផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ ដើម្បីទាញហេតុផលដាក់បន្ទុកបទល្មើសទីពីរនេះ គេត្រូវរកភ័ស្តុតាងបញ្ជាក់ថា ជនម្នាក់ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌការងារដែលផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ ពុំមានការពន្យល់បន្ថែមទៀតអំពីនិយមន័យនៃ"សេចក្តីថ្លៃថ្នូររបស់មនុស្ស"ឡើយ ។ ក្នុងករណីដែលមេខ្យល់/RA បានដឹងថា ពលករម្នាក់នឹងត្រូវប្រឈមមុខនឹងការបំពានរាងកាយ ឬការបំពានផ្លូវចិត្តនៅក្នុងប្រទេសទទួល ជាការសមហេតុផលដែលនិយាយថាទង្វើនេះស្ថិតនៅក្នុងប្រភេទនៃការ ផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ឬប៉ះពាល់ដល់សុខភាពរបស់ពលករ ។ ដូចគ្នានេះដែរ ចំពោះពលករដែលមានអាយុក្រោម ១៨ឆ្នាំ អវត្តមាននៃលទ្ធភាពទទួលបានការអប់រំក្នុងប្រព័ន្ធ អាចចាត់ទុកជាកត្តាមួយ នៅក្នុងការស្វែងរកការផ្តន្ទាទោសក្នុងន័យនេះ ។

៦.១.៧. MoU សម្រាប់មហាអនុតំបន់ទន្លេមេគង្គ នៅត្រង់ផ្នែកទី៥ កថាខណ្ឌទី២៦ លើកទឹកចិត្តឱ្យប្រទេសគោលដៅអនុវត្ត ច្បាប់ការងារឱ្យមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយការទទួលយកនូវការកេងប្រវ័ញ្ច ។ នៅក្នុងប្រទេសម៉ាឡេស៊ី ច្បាប់ដែលពាក់ព័ន្ធ គឺច្បាប់ការងារ ឆ្នាំ១៩៥៥ នៅក្នុងប្រទេសថៃ គឺច្បាប់ការពារការងារ ព.ស. ២៥៤១ គ.ស. ១៩៩៨ ។

៦.១.៨. ចំពោះពលករចំណាកស្រុកទៅប្រទេសកូរ៉េ ពួកគេត្រូវបានចុះបញ្ជីនៅក្រោមប្រព័ន្ធផ្តល់លិខិតអនុញ្ញាតការងារ (EPS) ។ បន្ទាប់មក ពលករដែលចុះបញ្ជីនៅក្រោមប្រព័ន្ធ EPS ទទួលបាននូវសិទ្ធិដូចគ្នានឹងពលករជាតិដែរ ដូចជា ប្រាក់ឈ្នួល ផលប្រយោជន៍ និងសិទ្ធិការងារស្មើគ្នា[៦០] ។ ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធនេះ ត្រូវបានចាត់ទុកជាទូទៅថា ជាមូលហេតុដែលធ្វើឱ្យការធ្វើចំណាកស្រុកទៅប្រទេសកូរ៉េពុំមានបញ្ហា ដូចគ្នានឹងការធ្វើចំណាកស្រុកទៅប្រទេស ម៉ាឡេស៊ី ឬប្រទេសថៃ ។

## ៦.២. ម៉ាឡេស៊ី

៦.២.១. ប្រទេសម៉ាឡេស៊ីត្រូវបានគេដឹងជាសាធារណៈថា មានលក្ខខណ្ឌការងារមិនសូវល្អ ជាពិសេសសម្រាប់ពលករចំណាក ស្រុក ។ ប្រទេសឥណ្ឌូនេស៊ី គឺជាប្រទេសនាំពលករទៅប្រទេសម៉ាឡេស៊ីដ៏ធំអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ប៉ុន្តែ នៅក្រោយពេលកើតមានករណីរំលោភបំពានដ៏លេចធ្លោមួយចំនួនមក ប្រទេសឥណ្ឌូនេស៊ីបានផ្អាកការបញ្ជូន ពលករទៅប្រទេសម៉ាឡេស៊ី ។ ខណៈដែលប្រទេសឥណ្ឌូនេស៊ីបានព្យាយាមឱ្យមានកិច្ចព្រមព្រៀងទ្វេភាគី ជាមួយ នឹងប្រទេសម៉ាឡេស៊ី ស្តីពីសិទ្ធិពលករចំណាកស្រុក ជាជាងធ្វើការឆ្ពោះទៅរកការកែលម្អលក្ខខណ្ឌការងារនោះ ប្រទេសម៉ាឡេស៊ីបានចាប់ផ្តើមជ្រើសរើសពលករពីទីកន្លែងផ្សេងទៀត — ភាគច្រើនពីប្រទេសកម្ពុជា ។

[៦០] អនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃសាធារណរដ្ឋ កូរ៉េ ស្តីពីការបញ្ជូនពលករទៅធ្វើការនៅសាធារណរដ្ឋកូរ៉េនៅក្រោមប្រព័ន្ធ EPS ។

៦.២.២. ការដែលលក្ខខណ្ឌការងារសម្រាប់ពលករចំណាកស្រុកនៅក្នុងប្រទេសម៉ាឡេស៊ី មិនបានប្រសើរឡើង មានន័យថា ក្រុមសិទ្ធិមនុស្ស និងអង្គការក្រៅរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្ន កំពុងទទួលបានរបាយការណ៍កាន់តែច្រើនឡើង អំពីការរំលោភបំពាន ។ គ្រាន់តែអង្គការ អាដហុក តែមួយ បានបញ្ជាក់ថា នៅក្នុងរយៈពេល ១០ខែដំបូងនៃឆ្នាំ២០១០ ខ្លួនបានទទួលពាក្យបណ្ដឹងចំនួន២៨ករណីពីស្ត្រីដែលអះអាងថា ត្រូវបានរំលោភបំពាន ខណៈដែលកំពុងធ្វើការជាអ្នកបម្រើតាមផ្ទះ ដែលភាគច្រើនបំផុតនៃស្ត្រីទាំងនោះធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី[៦១] ។

៦.២.៣. នៅក្នុងការសិក្សាមួយ ដែលធ្វើឡើងដោយអង្គការសម្របសម្រួលសកម្មភាពស្រាវជ្រាវអំពីជំងឺអេដស៍ និងបម្លាស់ទីលំនៅ ហៅកាត់ថា (CARAM) ប្រចាំកម្ពុជា (ជាអង្គការមួយដែលផ្ដល់ការបណ្ដុះបណ្ដាលនៅមុនការចេញដំណើរសម្រាប់ពលការិនីចំណាកស្រុកទៅប្រទេសម៉ាឡេស៊ី) បញ្ហាទូទៅដែលស្ត្រីប្រឈមមុខ រួមមាន បញ្ហាប្រាស្រ័យទាក់ទងជាមួយនិយោជក ធ្វើការច្រើនម៉ោងដោយមានម៉ោងសម្រាកតិច បរិយាកាសរើសអើង គ្មានថ្ងៃសម្រាកចុងសប្ដាហ៍/សម្រាកប្រចាំឆ្នាំដែលអត់កាត់ប្រាក់ឈ្នួល និងភាពឯកោ និងការនឹកផ្ទះ[៦២] ។

៦.២.៤. ដូចគ្នានឹងច្បាប់ការងាររបស់ប្រទេសកម្ពុជា (ឆ្នាំ១៩៩៧) ច្បាប់ការងារដែលសំខាន់ជាងគេនៅក្នុងប្រទេសម៉ាឡេស៊ី (ច្បាប់ការងារ ឆ្នាំ១៩៥៥) ពុំគ្របដណ្ដប់លើពលករបម្រើការងារតាមផ្ទះទេ ។ ដូច្នេះ ពលករបម្រើការងារតាមផ្ទះ នៅក្នុងប្រទេសម៉ាឡេស៊ីមិនទទួលបានផលប្រយោជន៍ពីបទប្បញ្ញត្តិដែលទាក់ទងនឹងលំហែមាតុភាព ថ្ងៃឈប់សម្រាក និងម៉ោងការងារឡើយ ។

***នីតិវិធីជ្រើសរើស សម្រាប់ពលរដ្ឋខ្មែរដែលធ្វើការងារនៅប្រទេសម៉ាឡេស៊ី (មិនអនុវត្តចំពោះពលករបម្រើការងារតាមផ្ទះទេ)***

*២.២. និយោជកមិនត្រូវបង់ថ្លៃជ្រើសរើសពលករណាមួយ ក្រៅពីថ្លៃដឹកជញ្ជូននោះទេ ។*

*២.៣. ប្រាក់ខែ គឺជាបុព្វសិទ្ធិរបស់និយោជក ។*

*២.៨. និយោជក ត្រូវផ្ដល់កន្លែងស្នាក់នៅសមរម្យ ។*

*២.១២. លក្ខខណ្ឌនៃកិច្ចសន្យា ត្រូវតែច្បាស់លាស់ និងពន្យល់ដល់ពលករ ក្នុងអំឡុងពេលនៃការជ្រើសរើស ។*

*២.១៣. សំណៅថតចម្លងមួយច្បាប់ នៃកិច្ចសន្យាការងារ ត្រូវផ្ដល់ឱ្យពលករ ។*

*២.១៧. និយោជកត្រូវទទួលខុសត្រូវ ក្នុងការរក្សាទុកលិខិតឆ្លងដែន របស់ពលករឱ្យមានសុវត្ថិភាព ។*

*២.១៨. ពលករមិនត្រូវនាំគ្រួសារ ឬរៀបការនៅក្នុងប្រទេសម៉ាឡេស៊ីទេ ។*

*២.១៩. ពលករត្រូវមានអាយុចន្លោះពី ២១ ដល់ ៤០ឆ្នាំ ។*

***កិច្ចសន្យា :***

*- រយៈពេលមិនលើសពី ៣ឆ្នាំ*

*- ការបរិយាយអំពីការងារ ត្រូវបញ្ជាក់ទាក់ទងនឹងការងារ និងបរិយាកាស (រោងចក្រ ដែលមានម៉ាស៊ីនត្រជាក់ ការងារដែលមានធូលី ធ្ងន់/កខ្វក់ ការងារនៅក្នុងកម្ដៅ ។ល។)*

*- ចែងច្បាស់លាស់អំពីប្រាក់ខែគោល ។*

[៦១] Brooke Lewis និង Mom Kunthear "បុគ្គលិកសម្រុកទៅកាន់ប្រទេសម៉ាឡេស៊ី" កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០) ដែលអាចរកមើលនៅឯ http://new.asiaviews.org/?content=153499ym32dddw4&headline=20101021150200&month=10&year=2010 បើកមើលនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[៦២] UNIFEM កម្មវិធីពង្រឹងអំណាចពលការិនីចំណាកស្រុកនៅក្នុងតំបន់អាស៊ី "ពលការិនីចំណាកស្រុកកម្ពុជា : ការរកឃើញពីការសិក្សាធ្វើផែនទីចំណាកស្រុក" (ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៦) ។

៦.២.៥. ជាងនេះទៅទៀត កិច្ចព្រមព្រៀងដែលធ្វើឡើងរវាងប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជា ស្តីពីបទដ្ឋានលក្ខខណ្ឌការងារសម្រាប់ពលករចំណាកស្រុក "នីតិវិធីជ្រើសរើសសម្រាប់ពលរដ្ឋកម្ពុជាដែលធ្វើការនៅប្រទេសម៉ាឡេស៊ី" (ដែលបានរៀបរាប់នៅក្នុងប្រអប់ខាងស្តាំ នៅទំព័រមុន) ក៏មិនអនុវត្តចំពោះពលករបម្រើការងារតាមផ្ទះដែរ ។

៦.២.៦. ដោយពុំត្រូវបានការពារដោយច្បាប់នៃប្រទេសម៉ាឡេស៊ី និងដោយគ្មានមធ្យោបាយពង្រឹងការអនុវត្តកិច្ចព្រមព្រៀង ដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ពលករចំណាកស្រុកដែលបម្រើការតាមផ្ទះ ប្រឈមមុខនឹងបញ្ហាធ្វើការងារច្រើនម៉ោង (ជារឿយៗ ធ្វើការប្រហែល ១៨ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍) ត្រូវបំពេញកិច្ចការប្រចាំថ្ងៃលំបាកៗដោយទទួលបានប្រាក់ឈ្នួលមិនស៊ីសង្វាក់គ្នា ។ ពួកគេកម្រត្រូវបានអនុញ្ញាតឱ្យចេញក្រៅផ្ទះណាស់ ហើយ ជាទូទៅ និយោជកតែងរក្សាទុកលិខិតឆ្លងដែនរបស់ពលករ ។ ការរឹតត្បិតសេរីភាពដើរហើរនេះ គឺផ្ទុយនឹងច្បាប់ជាតិ និងអន្តរជាតិ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ការរឹតត្បិតសេរីភាពនេះ នៅតែមិនអាចជាកម្មវត្ថុនៃបណ្តឹងរដ្ឋប្បវេណីពីប្រទេសកម្ពុជាដដែល ។

៦.២.៧. ជាការច្បាស់ណាស់ថា ពលករខ្មែរបម្រើការងារតាមផ្ទះទទួលបានប្រាក់ឈ្នួលតិចជាងពលករបម្រើការតាមផ្ទះដែលមកពីប្រទេសម៉ាឡេស៊ី ឬហ្វីលីពីន ។ បញ្ហានេះពិតជាយ៉ាងដូច្នេះមែន នៅពេលដែលពលករមកពីឥណ្ឌូនេស៊ីបំពេញតម្រូវការសម្រាប់បុគ្គលិកបម្រើការងារតាមផ្ទះ របស់ប្រទេសម៉ាឡេស៊ី ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានរាយការណ៍ថា អ្នកបម្រើតាមផ្ទះជនជាតិឥណ្ឌូនេស៊ីទទួលបានប្រាក់ឈ្នួលជាមធ្យម ១៣៣ដុល្លារសហរដ្ឋអាមេរិក/ខែ ខណៈដែលអ្នកបម្រើតាមផ្ទះជនជាតិហ្វីលីពីនទទួលបានប្រាក់ឈ្នួល ៤០០ដុល្លារសហរដ្ឋអាមេរិក/ខែ[៦៣] ។ គម្លាតនេះនៅតែមាននៅឡើយ ទោះបីជាឥឡូវនេះ អ្នកបម្រើតាមផ្ទះជនជាតិឥណ្ឌូនេស៊ី ត្រូវបានជំនួសដោយពលករខ្មែរក្តី ដោយពលករខ្មែរទទួលបានប្រាក់ឈ្នួលមធ្យមប្រចាំខែ ពី១៥០-១៨០ដុល្លារ

[៦៣] HRW "ឥណ្ឌូនេស៊ី/ម៉ាឡេស៊ី : បញ្ចប់ការកេងប្រវ័ញ្ចប្រាក់ឈ្នួលពលករបម្រើតាមផ្ទះ" (ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០) ដែលអាចបើកមើលនៅលើ : http://www.hrw.org/en/news/2010/05/10/indonesiamalaysia-end-wage-exploitation-domestic-workers

## រឿងទី៣ របស់ សំនៀង

យប់មួយ នៅពេលដែលទូកចតនៅឯសមុទ្រ សំនៀង និងបុរស ៣នាក់ទៀត លួចរត់ចេញពីបន្ទប់ចាក់សោរ ហើយលោតចេញពីទូក ។ នៅពេលទៅដល់ច្រាំង គាត់ជួបជាមួយនឹងបុរសម្នាក់ ដែលនិយាយភាសាថៃ ប្រាប់ថា ពួកគេកំពុងស្ថិតនៅក្នុងប្រទេសម៉ាឡេស៊ី ។ បុរសនោះឱ្យសំនៀង និងបុរសផ្សេងទៀត ធ្វើការនៅក្នុងទីក្រុងជិតខាងមួយ ហើយពន្យល់ថា ធ្វើដូច្នេះ គឺជាមធ្យោបាយតែមួយគត់ ដែលពួកគេនឹងអាចរកប្រាក់បាន ដើម្បីទិញសំបុត្រយន្តហោះត្រឡប់ទៅប្រទេសកម្ពុជាវិញ ។ បុរសផ្សេងទៀត យល់ព្រមទៅជាមួយគាត់ ប៉ុន្តែ សំនៀង បដិសេធ ហើយបន្តដំណើរដោយថ្មើរជើង ឆ្លងកាត់ព្រៃ ។ បីថ្ងៃក្រោយមក គាត់ត្រូវបាននគរបាលម៉ាឡេស៊ីចាប់ខ្លួន ។ គាត់ត្រូវបានបញ្ជូនខ្លួនទៅឃុំ នៅឯមណ្ឌលឃុំឃាំងអន្តោប្រវេសន៍ ដែលនៅទីនោះ គេបានពន្យល់គាត់ថា គាត់ត្រូវបានចាប់ខ្លួន ដោយសារគាត់ជាពលករចំណាកស្រុកដែលគ្មានឯកសារត្រឹមត្រូវ ។

សហរដ្ឋអាមេរិក នៅក្នុងប្រទេសម៉ាឡេស៊ី[៦៤] ។ ការអនុវត្តនេះហាក់ដូចជាមានការរើសអើង និងអាចដោះស្រាយនៅក្នុង MoU រវាងប្រទេសទាំងពីរ ។

៦.២.៨. ដោយគ្មានច្បាប់ជាតិ ដើម្បីត្រួតពិនិត្យលក្ខខណ្ឌការងាររបស់ពលករចំណាកស្រុកដែលបម្រើការងារតាមផ្ទះ នៅក្នុងប្រទេសម៉ាឡេស៊ី គេត្រូវតែពិចារណាទៅលើកិច្ចព្រមព្រៀងតំបន់ និងអន្តរជាតិ ។ ប្រទេសម៉ាឡេស៊ី គឺជាសមាជិកអាស៊ាន និងជាហត្ថលេខីនៃប្រកាសអាស៊ានស្តីពីការការពារនិងលើកកម្ពស់សិទ្ធិពលករចំណាកស្រុក (ឆ្នាំ២០០៧) ។ ដូច្នេះ ប្រទេសម៉ាឡេស៊ីបានព្រមព្រៀងអនុវត្តវិធានការដើម្បីការពារ និងលើកកម្ពស់សិទ្ធិពលករចំណាកស្រុក ក្នុងនោះរាប់បញ្ចូលទាំងការកែលម្អការត្រួតពិនិត្យការជ្រើសរើស និងការបណ្តុះបណ្តាល ។

៦.២.៩. ទោះបីមិនទាន់បានផ្តល់សច្ចាប័នលើ ICCPR ក្តី ប្រទេសម៉ាឡេស៊ីបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី (CEDAW)[៦៥] និងអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)[៦៦] ។ មាត្រា ១១ នៃ CEDAW ចែងថា ប្រទេសម៉ាឡេស៊ីត្រូវចាត់វិធានការសមស្របគ្រប់បែបយ៉ាង ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីនៅក្នុងវិស័យការងារ ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើភាពគ្នា និងសិទ្ធិទទួលបានការការពារសុខភាព និងសុវត្ថិភាពនៅក្នុងកន្លែងការងារ ។ មាត្រា ៣២ នៃ CRC ចែងថា ប្រទេសម៉ាឡេស៊ីមានកាតព្វកិច្ចទទួលស្គាល់សិទ្ធិកុមារ ដែលត្រូវការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច (កុមារត្រូវបានឱ្យនិយមន័យនៅក្នុងមាត្រា ១ ថាជាជនដែលមានអាយុក្រោម ១៨ឆ្នាំ) ។

២.២.១០. ដូច្នេះហើយ ទោះបីជាគ្មានច្បាប់ជាតិជាក់លាក់ណាមួយ ដើម្បីការពារពលករចំណាកស្រុកដែលបម្រើការងារតាមផ្ទះក្តី ប្រទេសម៉ាឡេស៊ីនៅតែមានកាតព្វកិច្ចនៅក្រោមច្បាប់អន្តរជាតិ ក្នុងការធានាការប្រព្រឹត្តចំពោះពលករទាំងនេះឱ្យបានសមរម្យ ។

## ៦.៣. ប្រទេសថៃ

៦.៣.១. រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃមានMoU ជាមួយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីពីកិច្ចសហប្រតិបត្តិការលើការងាររបស់ពលករ(ឆ្នាំ២០០៣) ប៉ុន្តែMoU នេះ ពុំបានបញ្ជាក់អំពីលក្ខខណ្ឌការងារអប្បបរមាសម្រាប់ពលករឡើយ ។ ដូច្នេះហើយ ពលករនៅក្នុងប្រទេសថៃត្រូវស្ថិតក្រោមច្បាប់ការងាររបស់ប្រទេសថៃ[៦៧] ។ ប៉ុន្តែ ជាក់ស្តែងពលករភាគច្រើនបំផុតមិនអាចទទួលបានព័ត៌មានអំពីសិទ្ធិការងាររបស់ពួកគេឡើយ ហើយក៏មិនដឹងអំពីលក្ខខណ្ឌជាមូលដ្ឋានដែលនិយោជករបស់ខ្លួនត្រូវមានកាតព្វកិច្ចផ្តល់ឱ្យដែរ ។

---

[៦៤] "ពលរដ្ឋឥណ្ឌូនេស៊ីចេញ ពលរដ្ឋខ្មែរចូល" (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០) ដែលអាចបើកមើលនៅលើ : http://www.mmail.com.my/content/24542-indonesians-out-cambodians

[៦៥] អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី (ឆ្នាំ១៩៧៩) ។

[៦៦] អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ (ឆ្នាំ១៩៨៩) ។

[៦៧] ច្បាប់ស្តីពីការការពារការងារ ព.ស. ២៥៤១ គ.ស. ១៩៩៨ ។

៦.៣.២. ជាងនេះទៅទៀត មានការតាមដានជាលក្ខណៈប្រព័ន្ធតិចតួចទៅលើលក្ខខណ្ឌការងាររបស់ពលករចំណាកស្រុកខ្មែរ ដែលធ្វើការនៅក្នុងប្រទេសថៃ (ពីសំណាក់រដ្ឋាភិបាលថៃក្តី ឬរដ្ឋាភិបាលកម្ពុជាក្តី) ដែលមានន័យថា រដ្ឋាភិបាលនៃប្រទេសទាំងពីរពឹងផ្អែកទៅលើ RAs ដើម្បីតាមដានបទដ្ឋាននៃលក្ខខណ្ឌការងារទាំងនេះ[៦៨] ។

[៦៨] ច័ន្ទ សុផល "របាយការណ៍ស្តីពីការគ្រប់គ្រង គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិសម្រាប់ចំណាកស្រុកដើម្បីការងារ នៅក្នុងប្រទេសកម្ពុជា" ឯកសារការងាររបស់ការិយាល័យ ILO ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក (ខែឧសភា ឆ្នាំ២០០៩ ILO ជប៉ុន) ។

## ៧. ការធ្វើមាតុភូមិនិវត្តន៍មកកម្ពុជា




### ៧.១. រឿងរបស់ សុភាព

៧.១.១. ក្នុងករណីរបស់ សុភាព នាងធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ីក្រោមកិច្ចសន្យាដែលធ្វើឡើងតាមមធ្យោបាយប្រក្រតី ដោយត្រូវបានបញ្ជូនដោយ RA ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ។ ដូច្នេះ RA ត្រូវមានកាតព្វកិច្ចជូនដំណឹងដល់ MoLVT ក្នុងរយៈពេល ៤៥ថ្ងៃ នៅមុនពេលដែលនាងត្រូវបញ្ជូនមកដល់កម្ពុជាវិញ[៦៩] ។ ក្នុងសេណារីយ៉ូដែលពលករវិលត្រឡប់មកវិញស្របតាមលក្ខខណ្ឌ (ឬនៅចុងបញ្ចប់) នៃកិច្ចសន្យា ថ្លៃចំណាយសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ទំនងជានឹងត្រូវរ៉ាប់រងដោយនិយោជក ឬ RA (ទោះបីជាថា ថ្លៃចំណាយនេះ អាចនឹងរាប់បញ្ចូលនៅក្នុងចំណាយដែលត្រូវកាត់ពីប្រាក់ឈ្នួលរបស់ពលករវិញក៏ដោយ) ។

៧.១.២. ប្រសិនបើ សុភាព អាចផ្តល់ភ័ស្តុតាងបញ្ជាក់អំពីការរំលោភកិច្ចសន្យាដោយភាគី RA ឬការអះអាងដោយក្លែងបន្លំអំពីលក្ខខណ្ឌនៃកិច្ចសន្យា (សូមមើលកថាខណ្ឌ ៦.១.៤ ខាងលើ) សុភាព អាចទាមទារថ្លៃចំណាយសម្រាប់ការធ្វើមាតុភូមិនិវត្តន៍មកកម្ពុជា ពី RA នៅក្នុងសំណង/ដំងឺចិត្តណាមួយ ។ ប៉ុន្តែ ការទាមទារជំងឺចិត្តបែបនេះ នៅមុនពេលដែល សុភាព ចាកចេញពីប្រទេសម៉ាឡេស៊ី គឺមិនអាចធ្វើទៅបានឡើយ ។ ដូច្នេះ ទោះបីជា សុភាព មានមូលដ្ឋានត្រឹមត្រូវដែលអះអាងថា RA បានរំលោភលក្ខខណ្ឌកិច្ចសន្យា ឬបានអះអាងផ្ទុយពីការពិតនូវលក្ខខណ្ឌ

[៦៩] មាត្រា ១៨ អនុក្រឹត្យលេខ ៥៧ ។

ណាមួយក្តី នាងមិនទំនងជាមានអំណាចគ្រប់គ្រាន់ ដើម្បីប្តឹងករណីនេះនៅក្នុងប្រទេសម៉ាឡេស៊ីឡើយ ។ នេះមានន័យថា នាងនឹងត្រូវតែស្ថិតនៅក្នុងប្រទេសម៉ាឡេស៊ី បើមិនដូច្នោះទេ នាងនឹងរំលោភលើកិច្ចសន្យាការងាររបស់នាងផ្ទាល់ ដោយចាកចេញពីនិយោជករបស់នាង ។

៧.១.៣. សុភាព នឹងមិនត្រឹមតែប្រឈមមុខនឹងលទ្ធភាពនៃបណ្តឹងពីបទល្មើសនឹងកិច្ចសន្យា ប្រសិនបើនាងចាកចេញពីការងាររបស់ខ្លួនមុនពេលកំណត់ប៉ុណ្ណោះនោះទេ ច្បាប់អន្តោប្រវេសន៍របស់ម៉ាឡេស៊ី ក៏ផ្តល់សិទ្ធិឱ្យនិយោជកដាក់ពាក្យស្នើសុំបញ្ចប់ និងលុបចោលលិខិតអនុញ្ញាតការងារ[៧០] ផងដែរ ។ នេះមានន័យថា ពលករត្រូវមានទោសពីបទស្នាក់នៅក្នុងប្រទេសនេះដោយគ្មានការអនុញ្ញាត ជាបទល្មើសមួយដែលប្រទេសម៉ាឡេស៊ីផ្តន្ទាទោសតាមវិធានការទណ្ឌកម្ម ក្នុងនោះរាប់បញ្ចូលទាំងការវាយនឹងរំពាត់ និងជាប់ពន្ធនាគារដល់ទៅ ៥ឆ្នាំ[៧១] ។ គ្រាន់តែនៅក្នុងខែកក្កដា ឆ្នាំ២០០៧ តែមួយ ជនចំណាកស្រុកដែលគ្មានឯកសារ ១០.០០០នាក់ ត្រូវបានចាប់ខ្លួននៅក្នុងប្រទេសម៉ាឡេស៊ី ដោយមានការផ្តោតការយកចិត្តទុកដាក់តិចតួចទៅលើថា តើជនចំណាកស្រុកទាំងនោះត្រូវការការការពារជាអន្តរជាតិ ឬអត់[៧២] ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានធ្វើការសន្និដ្ឋានថា ការចាប់និងឃុំខ្លួនពលករដែលគ្មានឯកសារដែលកើតឡើងកាន់តែញឹកញាប់ (ដោយមិនគិតអំពីហេតុផលនៃឋានៈគ្មានឯកសាររបស់ពួកគេ) មានន័យថា ពលករចំណាកស្រុកដែលស្ថិតនៅក្នុងស្ថានភាពរំលោភបំពាន មិនទំនងជាព្យាយាមរត់គេចចេញឡើយ[៧៣] ។ ប្រការនេះបង្កើតនូវសេណារីយ៉ូមួយ ដែលពលករដែលស្ថិតនៅក្នុងលក្ខខណ្ឌកេងប្រវ័ញ្ច និងរំលោភបំពាន ត្រូវបានរារាំងមិនឱ្យរត់គេចចេញ ដោយសារតែខ្លាចត្រូវចាប់ខ្លួន និង/ឬក្លាយជាជនរងគ្រោះជាថ្មីម្តងទៀត ។

---

[៧០] មាត្រា១៤(៣) ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៥៩/៦៣ ចែងថា ជនអន្តោប្រវេសន៍ណាម្នាក់ដែលស្ថិតក្នុងប្រភេទ "ហាមឃាត់" នៅក្នុងអំឡុងពេលសុពលភាពនៃលិខិតអនុញ្ញាតការងាររបស់ខ្លួន អាចត្រូវលុបចោលនូវលិខិតអនុញ្ញាតការងារនោះវិញ ។ មាត្រា ៨(៣) ចែងថា ជនណាម្នាក់ដែលមិនអាចចិញ្ចឹមខ្លួនឯងបាន ឧ. គ្មានការងារធ្វើ និងគ្មានប្រាក់ ត្រូវបានចាត់ទុកថាជា "ជនអន្តោប្រវេសន៍ដែលហាមឃាត់" ។

[៧១] HRW របាយការណ៍ពិភពលោក (ឆ្នាំ២០០៨) ។

[៧២] ibid ។

[៧៣] HRW "ត្រូវការជំនួយ : ការរំលោភបំពានលើពលកាវិនីចំណាកស្រុកដែលបម្រើការងារតាមផ្ទះនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី" (ខែកក្កដា ឆ្នាំ២០០៤ ឆ្នាំទី១៦ ច្បាប់ចេញផ្សាយលេខ ៩(ខ)) ។

៧.១.៤. ទោះបីជាដូចអ្វីដែលបានរៀបរាប់ខាងលើនេះក្តី ច្បាប់ម៉ាឡេស៊ីក៏ចែងផងដែរថា ជនណាម្នាក់ដែលរស់នៅក្នុងប្រទេសម៉ាឡេស៊ី ដែលមិនមែនជាពលរដ្ឋម៉ាឡេស៊ី អាចដាក់ពាក្យស្នើសុំឱ្យគេធ្វើមាតុភូមិនិវត្តន៍ខ្លួនទៅប្រទេសរបស់ខ្លួនវិញ ដោយសារមូលហេតុមិនអាចបង់ថ្លៃចំណាយធ្វើដំណើរត្រឡប់ទៅវិញដោយខ្លួនឯងបាន[៧៤] ។ ការស្រាវជ្រាវ ដែលបានធ្វើឡើងដើម្បីរៀបចំរបាយការណ៍នេះ ពុំបានរកឃើញករណីដែលពលករត្រូវបានបញ្ជូនត្រឡប់មកវិញ តាមការស្នើសុំនៅក្រោមមាត្រានៃច្បាប់នេះទេ ។ ជាក់ស្តែង ភាគច្រើននៃការធ្វើមាតុភូមិនិវត្តន៍ពលករមកកាន់ប្រទេសកម្ពុជាវិញ ត្រូវបានផ្តល់មូលនិធិដោយឯកជន គឺជារឿយៗដោយក្រុមគ្រួសារ និង/ឬអង្គការក្រៅរដ្ឋាភិបាល ។

៧.១.៥. ចំពោះពលរដ្ឋខ្មែរដែលមិនមែនធ្វើការនៅតាមផ្ទះ នៅក្នុងប្រទេសម៉ាឡេស៊ី នីតិវិធីជ្រើសរើសសម្រាប់ពលរដ្ឋខ្មែរ ដែលធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី (ឆ្នាំ១៩៩៥) ចែងបទប្បញ្ញត្តិជាក់លាក់អំពីអ្នកដែលត្រូវរ៉ាប់រងថ្លៃចំណាយ សម្រាប់ការធ្វើមាតុភូមិនិវត្តន៍នៅក្នុងសេណារីយ៉ូខុសៗគ្នា ។ ក្នុងករណីដែលពលករទទួលមរណភាព និយោជកត្រូវមានកាតព្វកិច្ចបង់សោហ៊ុយចំណាយ សម្រាប់ការធ្វើមាតុភូមិនិវត្តន៍អដ្ឋិធាតុ ។ ក្នុងករណីដែលកិច្ចសន្យាការងារបានចប់ជាស្ថាពរ ឬប្រសិនបើនិយោជកបញ្ចប់កិច្ចសន្យា (ដោយគ្មានហេតុផលតាមកិច្ចសន្យា) និយោជកត្រូវទទួលខុសត្រូវ ចំពោះថ្លៃចំណាយសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ប៉ុន្តែ ថ្លៃចំណាយទាំងនេះត្រូវតែរ៉ាប់រងដោយកម្មករ-និយោជិត ក្នុងករណីដែលពួកគេលាឈប់ពីការងារ ឬ ប្រសិនបើមានភស្តុតាងបញ្ជាក់អំពីកំហុស ។

### រឿងទី៤ របស់ សំនៀង

សំនៀង ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ៣ខែ ។ គាត់តែងតែត្រូវឆ្មាំគុកវាយដំ និងវាយនឹងរំពាត់ ។ នៅក្នុងមណ្ឌលឃុំឃាំង សំនៀង ត្រូវបានណែនាំ ឱ្យជួបជាមួយបុរសម្នាក់ដែលព្រមជួយឱ្យគាត់ បានត្រឡប់ទៅប្រទេសកម្ពុជាវិញ ។ ដើម្បីធ្វើដូច្នេះ បុរសនោះ នឹងទំនាក់ទំនងទៅគ្រួសាររបស់ សំនៀង ហើយឱ្យពួកគេបង់ប្រាក់ ៣០០ ដុល្លារ ដើម្បីឱ្យ សំនៀង អាចត្រឡប់ទៅផ្ទះវិញបាន ។ សំនៀង ដឹងថា គ្រួសាររបស់គាត់គ្មានប្រាក់ទេ និងថា បើឱ្យគ្រួសារគាត់ធ្វើដូច្នេះ នឹងនាំឱ្យជីវភាពកាន់តែដុនដាប ។ គាត់ទាក់ទងទៅស្ថានទូតកម្ពុជា ។ ពួកគេអាចជួយធ្វើឯកសារឱ្យគាត់ ប៉ុន្តែ ពុំមានមូលនិធិដើម្បីឱ្យគាត់ជិះយន្តហោះ ត្រឡប់មកស្រុកវិញឡើយ ។ សំនៀង ទទួលបានឈ្មោះអង្គការក្រៅរដ្ឋាភិបាលមួយ ដែលអាចជួយគាត់បាន ។ ប៉ុន្តែ អង្គការនោះ មិនត្រូវបានអនុញ្ញាតឱ្យចូលមន្ទីរឃុំឃាំងនោះឡើយ ។

[៧៤] មាត្រា ៥៦(១)(គ) ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៥៩/៦៣ ។

## ៧.២. រឿងរបស់ សំនៀង

៧.២.១. ករណីរបស់ សំនៀង បញ្ចប់ដោយគាត់ក្លាយខ្លួនទៅជាជនអន្តោប្រវេសន៍គ្មានឯកសារ គ្មានការងារធ្វើ និងខុសច្បាប់នៅក្នុងប្រទេសម៉ាឡេស៊ី ។ រឿងរបស់គាត់អាចនឹងបញ្ចប់នៅក្នុងប្រទេសថៃ ដោយគាត់ធ្លាក់ក្នុងស្ថានភាពដូចគ្នានេះដែរ ។ ប៉ុន្តែ ខណៈដែលច្បាប់ជាតិរបស់ប្រទេសទទួល ជារឿយៗ ធ្វើចំណាត់ការចំពោះជនអន្តោប្រវេសន៍ខុសច្បាប់តាមរយៈប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់ខ្លួនក្តី កិច្ចព្រមព្រៀងទ្វេភាគី និងកិច្ចព្រមព្រៀងថ្នាក់តំបន់មួយចំនួន ត្រូវបានចុះហត្ថលេខា (និងកំពុងចរចា) ក្នុងគោលបំណងដើម្បីដាក់កាតព្វកិច្ចឱ្យរដ្ឋហត្ថលេខី ធ្វើការកំណត់អត្តសញ្ញាណ និងការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ។ ការប្តេជ្ញាចិត្តនាពេលថ្មីៗបំផុតរបស់ប្រទេសកម្ពុជា ដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើឡើងនៅក្នុងអនុក្រឹត្យលេខ ១៦២ ដែលបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ។ ប៉ុន្តែ ដូចគ្នានឹង MoU រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃដែរ ការប្តេជ្ញាចិត្តដែលបានធ្វើឡើង គឺផ្តោតទៅលើតែស្ត្រី និងកុមារ ដែលត្រូវបានចាត់ទុកថាជាជនរងគ្រោះ ដែលងាយរងគ្រោះបំផុត[៧៥] ។ ប៉ុន្តែ ការធ្វើវិសោធនកម្មនាពេលថ្មីៗទៅលើវិសាលភាពនៃ MoU រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម មានន័យថា បច្ចុប្បន្ននេះ បុរសក៏ត្រូវបានគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះដែរ ។ នេះគឺជាការវិវឌ្ឍវិជ្ជមានមួយ ទាក់ទងនឹងការដាក់បញ្ចូលបុរសស្ថិតក្រោមការទប់ស្កាត់ និងការការពារនៃកិច្ចព្រមព្រៀងទ្វេភាគី ។

៧.២.២. កិច្ចព្រមព្រៀងមួយ ដែលអាចជួយដល់ សំនៀង បាន គឺ MoU ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS)[៧៦] ។ MoU នេះ ត្រូវបានធ្វើឡើងជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយសកម្មភាពនៃអំពើជួញដូរមនុស្សនៅក្នុង GMS និងបង្កើតគម្រោងសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីប្រទេសតំបន់ទន្លេមេគង្គដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរ (COMMIT) ។ ជាផ្នែកនៃគម្រោងនេះ បណ្តាប្រទេសនានាដោយរាប់បញ្ចូលទាំងប្រទេសកម្ពុជា និងប្រទេសថៃ បានចុះហត្ថលេខាលើ MoU នេះ ដោយព្រមព្រៀងគ្នាដើម្បីធ្វើកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរ ក្នុងនោះរាប់ទាំងការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងដែន លើវិស័យអនុវត្តន៍ច្បាប់ប្រឆាំងអំពើជួញដូរ និងការពារជនរងគ្រោះនៃអំពើជួញដូរគ្រប់រូបដែលត្រូវបានកំណត់អត្តសញ្ញាណ ។ ផ្នែកទី៣ កថាខណ្ឌទី១៦ នៃ MoU នេះ ចែងថា រដ្ឋភាគីត្រូវធានាថា ជនដែលត្រូវបានកំណត់អត្តសញ្ញាណថា ត្រូវ

---

[៧៥] MoU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់អំពើជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះនៃអំពើជួញដូរ (ឆ្នាំ២០០៣) ។

[៧៦] MoU ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ("GMS") (ឆ្នាំ២០០៤) ។

គេជួញដូរ មិនត្រូវស្ថិតក្នុងការឃុំឃាំងឡើយ ។ កថាខណ្ឌទី១៩ បញ្ជាក់ថា រដ្ឋភាគីត្រូវពង្រឹងសមត្ថភាពនៃស្ថានទូតរបស់ខ្លួនដើម្បីធានាថា ស្ថានទូតទាំងនេះអាចជួយជនដែលត្រូវបានគេជួញដូរប្រកបដោយប្រសិទ្ធភាព ។ ជាងនេះទៅទៀត គោលការណ៍ណែនាំថ្នាក់តំបន់របស់ COMMIT ស្តីពីការការពារជនរងគ្រោះ ចែងថា បណ្តាប្រទេសនានាត្រូវគិតគូរដល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះ នៅពេលកំណត់អំពីការធ្វើសមាហរណកម្ម និងផ្តល់សេវាមាតុភូមិនិវត្តន៍ និងសមាហរណកម្ម[៧៧] ។ ប៉ុន្តែ ប្រទេសម៉ាឡេស៊ីមិនមែនជាភាគីនៃ GMS MoU ឬ COMMIT នោះទេ ដូច្នេះ គម្រោងនេះមិនជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅក្នុងប្រទេសម៉ាឡេស៊ីឡើយ ។

៧.២.៣. បច្ចុប្បន្ន ពុំទាន់មានកិច្ចព្រមព្រៀងទ្វេភាគីរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ស្តីពីពលករចំណាកស្រុក ឬការការពារ និងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះនៃអំពើជួញដូរមនុស្ស នៅឡើយទេ ។ MoU មួយ កំពុងស្ថិតក្នុងការចរចាគ្នា ។ ប៉ុន្តែ ដំណើរការនេះបាននិងកំពុងបន្តអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយពុំទាន់មានសញ្ញាណាមួយបង្ហាញថា ពេលណាទើបឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឡើយ ។

៧.២.៤. ទោះបីពលករបរទេសរួមវិភាគទានយ៉ាងច្រើនដល់សេដ្ឋកិច្ចរបស់ប្រទេសថៃក្តី ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសថៃបានចាត់វិធានការគួរឱ្យកត់សម្គាល់ដើម្បីពង្រឹងលទ្ធភាពរបស់ខ្លួន ក្នុងការកំណត់អត្តសញ្ញាណនិងនិរទេសពលករបរទេស ។ ដំណើរការបញ្ជាក់សញ្ជាតិ (ដែលអនុវត្តនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១០) តម្រូវឱ្យពលករបរទេសចុះបញ្ជីជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ បើមិនដូច្នោះទេ ត្រូវប្រឈមមុខនឹងការចាប់ និងនិរទេសខ្លួន ។ ប៉ុន្តែ ដើម្បីចុះបញ្ជីនៅក្នុងដំណើរការនេះ ជារឿយៗ ពលករត្រូវចំណាយអស់ប្រាក់ខែដល់ទៅពីរ ឬបីខែ ។ នៅក្នុងខែមិថុនា ឆ្នាំ២០១០ គោលនយោបាយថ្មីៗជាបន្តបន្ទាប់ ត្រូវបានអនុម័ត (ដោយចូលជាធរមាននៅខែតុលា ឆ្នាំ២០១០) ដោយបង្កើតមជ្ឈមណ្ឌលមួយ ដើម្បី "បង្ក្រាប ចាប់ខ្លួននិងផ្តន្ទាទោសពលករបរទេស"[៧៨] ។ មជ្ឈមណ្ឌលនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីដើរតួជាមជ្ឈមណ្ឌលរដ្ឋបាលសម្រាប់ដោះស្រាយបញ្ហាពលករបរទេសដែលធ្វើការដោយលួចលាក់នៅក្នុងប្រទេសថៃ ។ ខណៈដែលគេពុំទាន់អាចនិយាយបានថា តើគោលនយោបាយនេះ នឹងត្រូវអនុវត្តយ៉ាងដូចម្តេចនៅឡើយនោះ អ្វីដែលគេបារម្ភខ្លាច គឺថា អាជ្ញាធរនឹងមិនធ្វើការបែងចែកដាច់ពីគ្នារវាងពលករចំណាកស្រុកមិនប្រក្រតី និងខុសច្បាប់ និងជនរងគ្រោះនៃអំពើជួញដូរមនុស្ស នៅក្នុងការអនុវត្តរបស់ខ្លួនឡើយ ។

---

[៧៧] គោលការណ៍ណែនាំថ្នាក់តំបន់របស់ COMMIT ស្តីពីអំពើជួញដូរមនុស្ស (**ឆ្នាំ**) ។

[៧៨] បទបញ្ជាលេខ ២៨២/២៥៥៣ ដែលលុបចោល (ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០) បទបញ្ជារបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី លេខ២៦៩/២៥៥៣ ស្តីពីការបង្កើតមជ្ឈមណ្ឌលដើម្បីបង្ក្រាប ចាប់ខ្លួន និងផ្តន្ទាទោសពលករបរទេស ដែលធ្វើការដោយលួចលាក់ និងដំណើរការនៃការជួញដូរមនុស្ស ។

៧.២.៩. ពិធីសារអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ឆ្នាំ២០០០) ("ពិធីសារ Palermo") ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅខែកក្កដា ឆ្នាំ២០០៧ នៅត្រង់មាត្រា ៨ ចែងថា រដ្ឋដែលជាប្រទេសសញ្ជាតិរបស់ជនរងគ្រោះ ត្រូវសម្របសម្រួលការវិលត្រឡប់របស់ជនរងគ្រោះ ។ ក្នុងករណីគ្មានជំនួយណាមួយពីប្រទេសទទួល នៅក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះនៃអំពើជួញដូរទេនោះ បទប្បញ្ញត្តិនេះដាក់បន្ទុកទៅលើប្រទេសកម្ពុជា ដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាពរបស់ សំនៀង ពីប្រទេសម៉ាឡេស៊ី ។

## ៨. បណ្ដឹង : នីតិវិធី/ដំណោះស្រាយតាមផ្លូវច្បាប់




### ៨.១. បណ្ដឹងរដ្ឋប្បវេណី

**បណ្ដឹងទាមទារសំណងនៅក្រោមអនុក្រឹត្យលេខ ៥៧**

៨.១.១. ជាគោលការណ៍ ពលករអាចស្វែងរកការទាមទារសំណងតាមផ្លូវច្បាប់ នៅក្រោមមាត្រា ៧ នៃអនុក្រឹត្យលេខ ៥៧ ដែលគួសបញ្ជាក់ថា មូលនិធិធានាដែលដាក់តម្កល់ដោយ RA អាចប្រើប្រាស់ដើម្បីផ្ដល់សំណងដល់ពលករ ក្នុងករណីដែលទីភ្នាក់ងារជ្រើសរើសពលករ មិនព្រមអនុវត្តតាមលក្ខខណ្ឌណាមួយនៃកិច្ចសន្យាការងារ ។ ប៉ុន្តែ រហូតមកទល់ខែកញ្ញា ឆ្នាំ២០១០ មូលនិធិធានានេះ មិនដែលត្រូវបានប្រើប្រាស់ដើម្បីផ្ដល់សំណងដល់ពលករណាម្នាក់នៅឡើយទេ[៧៩] ។

៨.១.២. មាត្រា ២០ នៃអនុក្រឹត្យលេខ ៥៧ ចែងថា បុគ្គលណាម្នាក់ដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយរំលោភលើបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។ ប៉ុន្តែ គួរកត់សម្គាល់ថា មាត្រានេះទាក់ទងទៅនឹងបុគ្គល មិនមែន RA ទេ ។ ចំណុចនេះមានភាពមិនច្បាស់លាស់ ប៉ុន្តែ អាចនឹងមានន័យថា ការផ្ដន្ទាទោសអាចអនុវត្តប្រឆាំងនឹងម្ចាស់ RA ។

[៧៩] ការស្រាវជ្រាវរបស់ UNIAP អំពីទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ឆ្នាំ២០១០ ។

៨.១.៣. អនុក្រឹត្យនេះបន្តថែងទៀតថា កិច្ចសន្យាមួយអាចលុបចោលបានតាមមាត្រា ២១ ប្រសិនបើលក្ខខណ្ឌណាមួយនៅក្នុងកិច្ចសន្យានោះ ត្រូវបានរកឃើញថា ផ្ទុយនឹងអនុក្រឹត្យនេះ ។ ប៉ុន្តែ ដូចដែលបានពិភាក្សានៅខាងលើ លក្ខខណ្ឌតម្រូវសម្រាប់លក្ខខណ្ឌកិច្ចសន្យាមិនសូវលម្អិតឡើយ ដោយមានថែងអំពីលក្ខខណ្ឌអប្បបរមាដែលអាចកំណត់បានតែពីរប៉ុណ្ណោះ ។ ដូច្នេះ ជាការគួរឱ្យជឿជាក់បានថា កិច្ចសន្យាអាចនឹងគោរពតាមអនុក្រឹត្យនេះ ប៉ុន្តែមានកម្រិតក្រោមបទដ្ឋានការងារដែលអាចទទួលយកបាន ។

**កិច្ចសន្យាមោឃៈ/កិច្ចសន្យាដែលអាចធ្វើមោឃភាពបាន**

៨.១.៤. ក្នុងកាលៈទេសៈដែលកិច្ចសន្យាមួយត្រូវចាត់ទុកជាមោឃៈ ឬអាចធ្វើមោឃភាពបាន (ដែលក្នុងករណីនេះ ភាគីម្ខាងត្រូវលុបចោលកិច្ចសន្យាប្រកបដោយជោគជ័យ) កិច្ចសន្យានោះត្រូវចាត់ទុកថាមិនដែលបានធ្វើឡើងឡើយ ហើយគូភាគីត្រូវវិលត្រឡប់ទៅរកស្ថានភាព ដូចនៅមុនពេលដែលមិនទាន់ចុះកិច្ចសន្យាវិញ (នៅក្រោមកិច្ចសន្យាលក់ទំនិញ ទំនិញនឹងត្រូវប្រគល់ទៅឱ្យអ្នកលក់វិញ ហើយប្រាក់ត្រូវប្រគល់ទៅឱ្យអ្នកទិញវិញ) ។

៨.១.៥. ក្នុងករណីដែលគូភាគីមិនអាចវិលត្រឡប់ទៅរកស្ថានភាពដើមវិញបាន ដោយសារតែភាពស្មុគស្មាញនៃការរៀបចំកិច្ចសន្យា ឬវិសាលភាពដែលកិច្ចសន្យាត្រូវបានបំពេញរួច ភាគីម្ខាងអាចប្តឹងទាមទារសំណងជំងឺចិត្តពីភាគីម្ខាងទៀតបាន ។

៨.១.៦. បញ្ហាដែលកើតឡើង គឺថា ជារឿយៗ RAs បានផ្តល់ប្រាក់ឱ្យគ្រួសារពលករខ្មែរ និង/ឬបានចំណាយប្រាក់ទៅលើការបណ្តុះបណ្តាលពលករ ។ ក្នុងករណីដែលមានការអះអាងដោយជោគជ័យថា កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ តើអាចទៅរួចទេ ដែលថា ពលករ និង/ឬគ្រួសាររបស់ពលករនឹងក្លាយជាអ្នកដែលត្រូវសងប្រាក់ទៅឱ្យ RA នោះ ?

៨.១.៧. ផ្នែក ៤០១ នៃក្រមរដ្ឋប្បវេណី ផ្តល់ការណែនាំខ្លះៗស្តីពីឆន្ទានុសិទ្ធិរបស់តុលាការនៅក្នុងសេណារីយ៉ូនេះ ដោយថែងថា ក្នុងករណីដែលមានបណ្តឹងកិច្ចសន្យាដែលកើតចេញពីការប្រព្រឹត្តមិនស្មោះត្រង់របស់ RA តុលាការអាចបង្គាប់ឱ្យ RA សងទៅឱ្យពលករជាសំណងជំងឺចិត្ត និងប្រាក់ចំណេញ ឬផលប្រយោជន៍ដែលទទួលបានដោយ RA ។

៨.១.៨. ដូចគ្នានេះដែរ ក្នុងករណីដែល RA ជាអ្នកទារសំណងជំងឺចិត្តពីពលករ មាត្រា ៤០២ ផ្តល់ការណែនាំអំពីមូលហេតុសម្រាប់ការបន្ថយសំណងជំងឺចិត្ត ដោយថែងថា ក្នុងករណីដែលភាពធ្វេសប្រហែស ឬកំហុសរបស់ដើមបណ្តឹងរួមចំណែកបង្កការខូចខាត តុលាការអាចកាត់បន្ថយសំណងជំងឺចិត្តដែលត្រូវសងទៅឱ្យចុងចម្លើយ ក្នុងវិសាលភាពយោងទៅលើកំហុសរបស់ដើមបណ្តឹងដែលបានរួមចំណែកបង្កការខូចខាតនោះ ។

## ៨.២. បណ្ដឹងព្រហ្មទណ្ឌ

៨.២.១. នៅក្រោយការផ្ដន្ទាទោសបទព្រហ្មទណ្ឌប្រកបដោយជោគជ័យ ពលករ/ដើមបណ្ដឹងមានសិទ្ធិធ្វើបណ្ដឹងរដ្ឋប្បវេណី ដើម្បីទាមទារជំងឺចិត្ត/សំណងប្រឆាំងនឹងជនល្មើស[៨០] ។

## ៨.៣. ហេតុផលដែលប្រើប្រាស់ដោយ RAs ដើម្បីជៀសវាងបណ្ដឹង

៨.៣.១. ក្នុងករណីដែលពលករ និង/ឬគ្រួសាររបស់ពលករបានចូលរួមសមគំនិតនៅក្នុងការកែអត្តសញ្ញាណរបស់ពលករ ឬ អំពីខុសច្បាប់ផ្សេងទៀត RA អាចនឹងគំរាមប្ដឹងតបវិញជាវិធីបំបាក់ទឹកចិត្តចំពោះការចាត់វិធានការតាមផ្លូវច្បាប់ណាមួយ ។ ក្នុងកាលៈទេសៈទាំងនេះ ភាពងាយរងគ្រោះ និងកង្វះចេតនាប្រព្រឹត្តល្មើសច្បាប់របស់ពលករ និង/ឬ គ្រួសារ អាចផ្ដល់ហេតុផលដោះបន្ទុកចំពោះអំពើរបស់ពួកគេ និង/ឬបណ្ដឹងព្រហ្មទណ្ឌ/រដ្ឋប្បវេណីបន្ថែមទៀតប្រឆាំងនឹង RA ។

### ចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

៨.៣.២. ក្នុងករណីដែលគ្រួសាររបស់ សុភាព គិតចង់ស្វែងរកការចោទប្រកាន់បទព្រហ្មទណ្ឌប្រឆាំងនឹង RA ពីបទធ្វើលិខិតឆ្លងដែនដោយផ្អែកតាមឯកសារអត្តសញ្ញាណក្លែងបន្លំ RA អាចនឹងឆ្លើយតបដោយគំរាមដាក់ពាក្យបណ្ដឹងស្រដៀងគ្នានេះប្រឆាំងនឹងគ្រួសាររបស់ សុភាព ពីបទអនុញ្ញាតឱ្យ សុភាព ប្រើឯកសារអត្តសញ្ញាណបងស្រីរបស់នាង ។ ប៉ុន្តែ មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ (២០០៩) ចែងថា មិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌឡើយ ប្រសិនបើគ្មានចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ ដូច្នេះ ផ្អែកតាមហេតុផល គ្រួសាររបស់ សុភាព អាចថ្លែងការពារជំទាស់នឹងបណ្ដឹងព្រហ្មទណ្ឌណាមួយដែលប្ដឹងប្រឆាំងនឹងពួកគេ ដោយសំអាងលើមូលដ្ឋានដែលថា ពួកគេមិនចេះច្បាប់ ហើយគ្មានចេតនាប្រព្រឹត្តការបោកប្រាស់/ក្លែងបន្លំ ដែលទាក់ទងនឹងបទល្មើសនេះទេ ប៉ុន្តែ គ្រាន់តែធ្វើតាមអ្វីដែលពួកគេត្រូវបានណែនាំឱ្យធ្វើដើម្បីជួយដល់កូនស្រីរបស់ខ្លួនតែប៉ុណ្ណោះ ។

### ការកេងប្រវ័ញ្ចបន្តរបស់ RA

៨.៣.៣. ក្នុងករណីដែលគេអាចបង្ហាញថា មេខ្យល់កេងប្រយោជន៍លើកង្វះការអប់រំ/អនក្ខរភាពនៃគ្រួសាររបស់ សុភាព ទង្វើនេះអាចជាបទល្មើសព្រហ្មទណ្ឌនៅក្រោមមាត្រា ៣៨៣ នៃក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) "ការកេងប្រយោជន៍ពីភាពទន់ខ្សោយ" ដែលផ្ដន្ទាទោសអំពើនៃការបំពានដោយចេតនាទៅលើភាពអវិជ្ជា ឬភាពទន់ខ្សោយនៃជនណាម្នាក់ដោយសារការមានផ្ទៃពោះ ជំងឺ ឬភាពពិការរបស់ជននោះ ដើម្បីបង្ខំឱ្យជននេះប្រព្រឹត្ត ឬមិនប្រព្រឹត្តអំពើមួយ ដែល

---

[៨០] មាត្រា ៤៦ LSHTSE (ឆ្នាំ១៩៩៧) ។

ប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជននោះ ។ ករណីនេះចាំបាច់ត្រូវសាកល្បង ប៉ុន្តែ មានលទ្ធភាពដែលថា អនក្ខរភាពរបស់ជនណាម្នាក់អាចត្រូវបានឱ្យនិយមន័យថាជា "ការខ្វះលទ្ធភាព"ដែលបង្កឱ្យមាន"ភាពអវិជ្ជា" ឬ "ភាពទន់ខ្សោយ" ដែលជាបទល្មើសព្រហ្មទណ្ឌ នៅពេលត្រូវបានកេងប្រវ័ញ្ចដោយ RA ។

៨.៣.៤. ស្រដៀងគ្នានេះដែរ ក្រមរដ្ឋប្បវេណីរួមបញ្ចូលនូវបទប្បញ្ញត្តិមួយនៅត្រង់មាត្រា ៣៤៩ ស្តីពីការបំពានកាលៈទេសៈ ដែលចែងថា ក្នុងករណីដែលភាគីមួយប្រើប្រាស់ស្ថានភាពផ្នែកសេដ្ឋកិច្ច ឬឋានៈសង្គមរបស់ខ្លួនដើម្បីឱ្យភាគីម្ខាងទៀតមិនអាចជំទាស់ទៅនឹងការរៀបចំធ្វើកិច្ចសន្យា ភាគីម្ខាងទៀតនេះអាចលុបចោលកិច្ចសន្យានោះបាន ។

៨.៣.៥. នៅក្នុងការប្រើប្រាស់ការគំរាមកំហែងដើម្បីបន្ទុចបង្អាក់ពលករ/គ្រួសាររបស់ពលករកុំឱ្យធ្វើការប្តឹង RA ក៏អាចនឹងត្រូវមានទោសពីបទគំរាមហែកកេរ្តិ៍ ។ មាត្រា ៣៧២ នៃក្រមព្រហ្មទណ្ឌ ក៏ផ្តន្ទាទោសអំពើគំរាមហែកកេរ្តិ៍ផងដែរ ដោយឱ្យនិយមន័យថាជា *"អំពើនៃការទទួលបានហត្ថលេខា ការសន្យា ... ដោយមធ្យោបាយគំរាមបញ្ចេញឱ្យដឹង ឬទម្លាក់កំហុសលើការពិត ក្នុងចេតនាដើម្បីបង្ខូចកិត្តិយស ឬមិត្តភាពរបស់ជនណាម្នាក់"* ។

៨.៣.៦. ការស្រាវជ្រាវរកច្បាប់ដែលមានសម្រាប់ប្រើប្រាស់ប្រឆាំងនឹង RAs ដែលប្រើប្រាស់ការគំរាមកំហែង គឺជាការដែលមានប្រយោជន៍ ពីព្រោះការគំរាមកំហែងនេះត្រូវបានមើលឃើញថាជាវិធីទូទៅបំផុតនៃការបន្ទុចបង្អាក់ពលករ និងគ្រួសាររបស់ពួកគេមិនឱ្យធ្វើការប្តឹង ។

## ៩. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### សេចក្តីសន្និដ្ឋាន

ច្បាប់ LSHTSE និងក្រមព្រហ្មទណ្ឌ រួមគ្នាបង្កើតជាក្របខ័ណ្ឌគតិយុត្តព្រហ្មទណ្ឌគ្រប់គ្រាន់ ដែលពលករទាំងឡាយដែលរងគ្រោះដោយសារអំពើជួញដូរ និងអំពើព្រហ្មទណ្ឌផ្សេងទៀត អាចមានសិទ្ធិប្តឹងប្រឆាំងនឹងជនល្មើស ។ ប៉ុន្តែ ជាការអនុវត្តជាក់ស្តែង ភ័ស្តុតាងដាក់បន្ទុកធ្វើឱ្យដំណើរការផ្តន្ទាទោសមានការលំបាក ដូច្នេះហើយ ការទាមទារសំណងរដ្ឋប្បវេណីក៏ត្រូវតែស្វែងរកផងដែរ ជាមធ្យោបាយដើម្បីធ្វើឱ្យជនដែលកេងចំណេញពីការកេងប្រវ័ញ្ចកោតញញើត ។

រាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងអនុម័តអនុក្រឹត្យថ្មីមួយស្តីពីការងាររបស់ពលករចំណាកស្រុក (ដែលមិនទាន់ចេញជាសេចក្តីព្រាងនៅឡើយ) ហើយក្រមរដ្ឋប្បវេណីថ្មី (ឆ្នាំ២០០៧) ដែលបានចូលជាធរមាននាពេលថ្មីៗកន្លងទៅនេះ[៨១] ។ ច្បាប់ទាំងពីរនេះ នឹងមានផលប៉ះពាល់ដ៏ច្រើនទៅលើការការពារពលករចំណាកស្រុក និងផ្តល់ដល់ពួកគេនូវលិខិតូបករណ៍ដើម្បីធ្វើមោឃភាពលក្ខខណ្ឌកិច្ចសន្យាដែលកេងប្រវ័ញ្ច និងខុសច្បាប់ ។ ប៉ុន្តែ នេះមិនបានដោះស្រាយបញ្ហាដែលពលករ និងគ្រួសាររបស់ពួកគេប្រឈមមុខ នៅពេលដាក់បណ្តឹងប្រឆាំងនឹង RAs ។ ដើម្បីធ្វើឱ្យ RAs ផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន និងបង្កើនបទដ្ឋាននៃការជ្រើសរើស និងការបណ្តុះបណ្តាល ជាដំបូង បណ្តឹងប្រឆាំងនឹង RAs ចាំបាច់ត្រូវតែទទួលបានជោគជ័យ ។ ក្នុងន័យនេះ ពលករ និងគ្រួសាររបស់ពួកគេនឹងទទួលបានផលប្រយោជន៍ពីការគាំទ្រ និងការការពារកាន់តែច្រើនឡើង នៅក្នុងអំឡុងនៃដំណើរការប្តឹងប្រឆាំងនឹង RAs ។

ប៉ុន្តែ ដើម្បីធានាថា ការការពារពលករទាំងនេះនៅតែបន្ត នៅពេលដែលពួកគេចាកចេញពីប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាត្រូវតែទាមទារឱ្យមានកិច្ចព្រមព្រៀងទ្វេភាគីកាន់តែរឹងមាំជាមួយប្រទេសទទួលពលករ និងអនុវត្តយន្តការតាមដាន និងវាយតម្លៃ ដើម្បីធានាថា ពលករទទួលបានប្រព្រឹត្តកម្មដោយយុត្តិធម៌ និងត្រឹមត្រូវ ខណៈដែលកំពុងធ្វើការងារនៅក្រៅប្រទេស ។ ជាពិសេស ភាពងាយរងគ្រោះរបស់ពលករបម្រើការងារតាមផ្ទះនៅក្នុងប្រទេសម៉ាឡេស៊ី មានយ៉ាងពិតប្រាកដ ដោយគ្មានការការពារពីច្បាប់ជាតិ និងដោយមានជំនួយតិចតួចពីសន្ធិសញ្ញាតំបន់ និងអន្តរជាតិ ដែលប្រទេសម៉ាឡេស៊ីជាភាគី ។ ប្រទេសម៉ាឡេស៊ីមានតម្រូវការកើនឡើងសម្រាប់ពលករបម្រើការងារតាមផ្ទះ ហើយនេះអាចជាទីផ្សារដែលផ្តល់ផលចំណេញដ៏ច្រើនដល់កម្ពុជា ។ ប៉ុន្តែ ទីផ្សារនេះត្រូវតែជាទីផ្សារដែលគេអាចពង្រឹងការអនុវត្តបទដ្ឋានការងារ ហើយពលករដែលត្រូវបានកេងប្រវ័ញ្ច មានសិទ្ធិស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ប្រឆាំងនឹងនិយោជករបស់ពួកគេ ។

ច្បាស់ណាស់ថា គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើនចំនួនពលករដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស គឺជាគោលនយោបាយដ៏សំខាន់មួយ ។ គោលនយោបាយនេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ការកែលម្អស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងផ្តល់ផលប្រយោជន៍ដល់ពលករខ្លួនឯង ដែលប្រហែលជានឹងត្រូវរស់នៅក្នុងជីវភាពក្រីក្រ ប្រសិនបើមិនធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសទេនោះ ។ ប៉ុន្តែ បច្ចុប្បន្ន ជោគជ័យនៃ

---

[៨១] សូមមើលកំណត់សម្គាល់លេខ ១៧ ខាងលើ ។

គោលគំនិតនៃការធ្វើចំណាកស្រុកបានបោះជំហានលឿនជាងការតាក់តែងក្របខ័ណ្ឌគតិយុត្តនៅក្នុងប្រទេសកម្ពុជា ដែលនឹងគ្រប់គ្រង ត្រួតពិនិត្យ និងការពារពលករចំណាកស្រុក ។ ដូច្នេះ មនុស្សកាន់តែកេងចំណេញលើចន្លោះប្រហោងដែលរីកកាន់តែធំ ដែលការធ្វើចំណាកស្រុកមិនប្រក្រតីអាចធ្វើឡើងដោយមានហានិភ័យតិចតួច ឬគ្មានហានិភ័យទាល់តែសោះ ។ ចំពោះពលករទាំងឡាយដែលចង់ស្វែងរកប្រយោជន៍ពីប្រភពទ្រព្យថ្មីនេះ កង្វះព័ត៌មាន និងភាពចន្លោះប្រហោងនានា មានន័យថា ពួកគេនឹងមិនដឹងថា ពួកគេស្ថិតនៅក្នុងចំណោមមនុស្សដែលគ្មានភ័ព្វសំណាង ឬយ៉ាងណានោះទេ ហើយបើដឹង គឺយឺតពេលទៅហើយ ។

**អនុសាសន៍**

របាយការណ៍នេះ ផ្ដល់នូវអនុសាសន៍ដូចខាងក្រោម ៖

***ច្បាប់***

១) ធ្វើវិសោធនកម្មវិសាលភាពនៃច្បាប់ការងារ ដើម្បីដាក់បញ្ចូលទាំងពលករបម្រើការងារតាមផ្ទះ ។

២) ធ្វើវិសោធនកម្មវិសាលភាពនៃច្បាប់ការងារ ដើម្បីគ្របដណ្ដប់ការជ្រើសរើស និងការបណ្ដុះបណ្ដាលពលករនៅក្នុងប្រទេសកម្ពុជា ទោះបីជាកិច្ចសន្យាការងារត្រូវអនុវត្តនៅទីកន្លែងណាក៏ដោយ ។

៣) រៀបចំធ្វើបច្ចុប្បន្នកម្មអនុក្រឹត្យស្ដីពីពលករចំណាកស្រុកសម្រាប់ការពិគ្រោះយោបល់ ដោយរួមបញ្ចូលទាំង ៖

ក. គំរូកិច្ចសន្យាការងារជាស្ដង់ដារសម្រាប់ RAs

ខ. លក្ខខណ្ឌតម្រូវឱ្យ RAs ផ្ដល់សេចក្ដីលម្អិតអំពីការចំណាយជាមុនសម្រាប់ការធ្វើដំណើរ និងការចំណាយផ្សេងៗទៀត ដល់ពលករចំណាកស្រុកដែលមានសក្ដានុពល ដើម្បីកែលម្អតម្លាភាព ។

គ. បញ្ជាក់ឱ្យច្បាស់ថា RAs ត្រូវទទួលខុសត្រូវក្នុងការផ្ទៀងផ្ទាត់អាយុរបស់ពលករនៅមុនពេលជ្រើសរើស

ឃ. បញ្ញត្តិស្ដីពីការអនុវត្តការជ្រើសរើសដែលអាចទទួលយកបាន ឧ. ហាមប្រាមការផ្សាយពាណិជ្ជកម្មបំភ័ន្ត ដោយធានាថា ពលករយល់ច្បាស់អំពីលក្ខខណ្ឌនៃកិច្ចសន្យា និងមិនអនុញ្ញាតឱ្យពលករចុះកិច្ចសន្យាដែលនឹងមានបទដ្ឋានការងារទាបជាងនៅក្នុងប្រទេសកម្ពុជា ។

ង. ការបញ្ជាក់អំពីវិធានការដែលត្រូវអនុវត្តប្រឆាំងនឹង RAs នៅពេលដែលពួកគេមិនគោរពតាមអនុក្រឹត្យ

ច. បទប្បញ្ញត្តិជាក់លាក់ស្ដីពីការប្រើប្រាស់ប្រាក់ធានា ១០០.០០០ដុល្លារសហរដ្ឋអាមេរិក ។

***ការផ្ដល់អាជ្ញាប័ណ្ណដល់ RAs***

៤) ដាក់ឱ្យស្ថិតក្រោមច្បាប់នូវតួនាទីរបស់មេខ្យល់ និងភាគីទីបី នៅក្នុងដំណើរការជ្រើសរើសពលករ តាមរយៈការផ្ដល់អាជ្ញាប័ណ្ណដោយផ្ទាល់ ឬតាមរយៈទំនាក់ទំនងកិច្ចសន្យាជាកាតព្វកិច្ច ។

***ការជ្រើសរើស/ធ្វើកិច្ចសន្យាជាមួយពលករ***

៥) អនុវត្តការផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌប្រឆាំងនឹង RAs ទាំងឡាយណា ដែលជ្រើសរើសពលករមិនគ្រប់អាយុ និង/ឬដែលបានចូលរួមពាក់ព័ន្ធនៅក្នុងការក្លែងបន្លំឯកសារអត្តសញ្ញាណ ។

*ការបណ្តុះបណ្តាល/ការស្នាក់អាស្រ័យ/ការដឹកជញ្ជូន*

៦) ដាក់ឱ្យអនុវត្តកម្មវិធីផ្លូវការមួយ សម្រាប់ការបណ្តុះបណ្តាលពលករចំណាកស្រុកនៅមុនពេលចេញដំណើរ ដែលមានលក្ខណៈជាក់លាក់តាមវិស័យការងារ និងតាមប្រទេស ។

៧) ដាក់ឱ្យអនុវត្តបទដ្ឋានអប្បបរមាសម្រាប់ការដឹកជញ្ជូន និងការស្នាក់អាស្រ័យរបស់ពលករចំណាកស្រុក ។

*ការឆ្លងកាត់/ការមកដល់នៅក្នុងប្រទេសទទួល*

៨) ពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីព្រលានយន្តហោះ ឆ្នាំព្រំដែន នគរបាលអន្តោប្រវេសន៍ និងភ្នាក់ងារគយ ដើម្បីអាចធ្វើសកម្មភាពនៅពេលដែលពួកគេមានការសង្ស័យសមហេតុផលថា ពលករមានអាយុក្រោម ១៨ឆ្នាំ ។

*លក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល*

៩) ពន្លឿនដំណើរការចុះកិច្ចព្រមព្រៀងលើ MoU ជាមួយប្រទេសម៉ាឡេស៊ី ដើម្បីដាក់បញ្ចូលកាតព្វកិច្ចនៅលើព្រំដែនម៉ាឡេស៊ី ដើម្បីប៉ាន់ប្រមាណអាយុរបស់ពលករចំណាកស្រុក និងដាក់បញ្ចូលនូវបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌការងារ និងការធ្វើបទដ្ឋានកម្មប្រាក់ឈ្នួល ។

១០) ប្រើប្រាស់ប្រព័ន្ធផ្តល់លិខិតអនុញ្ញាតការងាររបស់ប្រទេសកូរ៉េ ជាមូលដ្ឋានតស៊ូមតិសម្រាប់ការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការងាររបស់ពលករចំណាកស្រុក ។

១១) ដាក់សម្ពាធទៅលើប្រទេសទទួលឱ្យលើកកម្ពស់បទដ្ឋានការងារ ដោយបដិសេធមិនបញ្ជូនពលករទៅ រហូតទាល់តែបទដ្ឋានទាំងឡាយត្រូវបានព្រមព្រៀង ។

១២) តែងតាំងសេនានុព័ន្ធការងារ ដែលអាចធ្វើទំនាក់ទំនងជាមួយប្រទេសទទួល និងទទួលខុសត្រូវក្នុងការតាមដានលក្ខខណ្ឌការងាររបស់ពលករខ្មែរនៅក្រៅប្រទេស ព្រមទាំងជួយដល់ការកែលម្អលក្ខខណ្ឌទាំងនោះ ។

*ការធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសកម្ពុជា*

១៣) បណ្តុះបណ្តាលស្ថានទូតកម្ពុជានៅក្នុងប្រទេសទទួល ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងសំណើសុំជំនួយពីពលករ និង/ឬដើម្បីជួយពលរដ្ឋខ្មែរដែលត្រូវបានចាប់និងឃុំខ្លួនជាអន្តោប្រវេសន៍ខុសច្បាប់ ។

១៤) ចរចាឡើងវិញនូវ MoU ស្តីពីអំពើជួញដូរមនុស្ស ដើម្បីឱ្យកិច្ចព្រមព្រៀងទាំងនោះរួមបញ្ចូលផងដែរនូវការទប់ស្កាត់ និងការពារជនរងគ្រោះនៃអំពើជួញដូរដែលជាបុរស ។

*បណ្តឹង*

១៥) បង្កើនការការពារដល់ពលករទាំងឡាយ និងគ្រួសាររបស់ពួកគេ ដែលសម្រេចចិត្តស្វែងរកការប្តឹងតាមផ្លូវច្បាប់ប្រឆាំងនឹង RAs ។

## ១០. ក្របខ័ណ្ឌគតិយុត្ត ៖ ដ្យាក្រាម និងតារាងច្បាប់

*ដ្យាក្រាមនៅក្នុងផ្នែកនេះ បង្ហាញអំពីដំណាក់កាលនីមួយៗនៃចំណាកស្រុក និងភាពខុសគ្នា/សកម្មភាពនានា ដែលកើតឡើងនៅក្នុងដំណាក់កាលនីមួយៗ ដោយផ្តល់សេចក្តីសន្និដ្ឋានអំពីច្បាប់ (រដ្ឋប្បវេណី និងព្រហ្មទណ្ឌ) ដែលអាចប្រើប្រាស់ដើម្បីទប់ស្កាត់ និងផ្តន្ទាទោសជនល្មើស និងការពារជនរងគ្រោះនៃចំណាកស្រុកមិនប្រក្រតី និងការកេងប្រវ័ញ្ច ។*



*តារាងខាងក្រោមនេះ រួមមានព័ត៌មានបន្ថែមទៀតអំពីច្បាប់នីមួយៗដែលលើកឡើងនៅក្នុងដ្យាក្រាម ។*

| ដំណាក់កាលនៃការជ្រើសរើស/ចំណាកស្រុក | ច្បាប់ព្រហ្មទណ្ឌ | ច្បាប់រដ្ឋប្បវេណី |
|---|---|---|
| **ការផ្តល់អាជ្ញាប័ណ្ណដល់ RAs** | - | - មាត្រា ៥ អនុក្រឹត្យលេខ ៥៧ ចែងអំពីលក្ខខណ្ឌតម្រូវឱ្យ RA ដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពី MoLVT ។<br>- មាត្រា ៧ អនុក្រឹត្យលេខ ៥៧ ចែងអំពីប្រាក់ធានា ១០០.000ដុល្លារសហរដ្ឋអាមេរិក ដើម្បីផ្តល់សំណងដល់ពលករ ក្នុងករណីដែល RA ខកខានមិនបានអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យា ។<br>- មាត្រា ២០ អនុក្រឹត្យលេខ ៥៧ បុគ្គលណាដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយរំលោភអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ ។<br>- ផ្នែកទី៤ ក្រមរដ្ឋប្បវេណី វិធានស្តីពីទីភ្នាក់ងារ |
| **ការជ្រើសរើស/ធ្វើកិច្ចសន្យាជាមួយពលករ** | - មាត្រា ៩ LSHTSE ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ ។<br>- មាត្រា ១០ LSHTSE ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ។<br>- មាត្រា ១១ LSHTSE ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ។<br>- មាត្រា ១២ LSHTSE ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់ការកេងប្រវ័ញ្ច ។<br>- មាត្រា ១៤ LSHTSE អំពើលក់-ដូរមនុស្ស ។<br>- មាត្រា ១៥ LSHTSE អំពើលក់-ដូរមនុស្សដោយមានគោលដៅ ។ | - មាត្រា ៣ អនុក្រឹត្យលេខ៥៧ RAs ត្រូវតែជ្រើសរើសពលករដែលមានអាយុលើស ១៨ឆ្នាំ ។<br>- មាត្រា ៩ អនុក្រឹត្យលេខ ៥៧ លក្ខខណ្ឌតម្រូវនៃកិច្ចសន្យាការងាររវាង RA និងពលករ ។<br>- មាត្រា ៣ អនុក្រឹត្យលេខ ៣៨ កិច្ចសន្យាមួយមានសុពលភាព លុះត្រាតែកិច្ចសន្យានោះមានកម្មវត្ថុជាក់លាក់ អាចអនុវត្តបាន ស្របច្បាប់ និងស្របជាមួយនឹងសណ្តាប់ធ្នាប់សាធារណៈ និងប្រពៃណីល្អ ។<br>- មាត្រា ៥ អនុក្រឹត្យលេខ ៣៨ កិច្ចសន្យាទាំងឡាយនឹងចាត់ទុកជាមោឃៈ នៅពេលដែលកិច្ចសន្យានោះមិនស្របច្បាប់ ផ្ទុយពីផលប្រយោជន៍សង្គម និងរំលោភសីលធម៌សង្គម ។<br>- មាត្រា ៦ អនុក្រឹត្យលេខ ៣៨ កិច្ចសន្យាមួយត្រូវចាត់ទុកជាមោឃៈ នៅពេលដែលភាគីម្ខាងមិនមានសមត្ថភាពផ្លូវច្បាប់ ។ |

| ដំណាក់កាលនៃការជ្រើសរើស/ចំណាកស្រុក | ច្បាប់ព្រហ្មទណ្ឌ | ច្បាប់រដ្ឋប្បវេណី |
|---|---|---|
| | - មាត្រា ១៦ LSHTSE អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន ។<br>- មាត្រា ៣២៧ ក្រមព្រហ្មទណ្ឌ ការនាំយកអនីតិជនចេញ ។ | |
| ការបណ្តុះបណ្តាល/ការស្នាក់អាស្រ័យ/ការដឹកជញ្ជូន | - មាត្រា ១៧ LSHTSE ការដឹកជញ្ជូនដោយមានគោលដៅ ។<br>- មាត្រា ១៨ LSHTSE ការដឹកជញ្ជូនឆ្លងដែន (អំពើនាំឆ្លងដែន) ។<br>- មាត្រា ១៩ LSHTSE ការទទួលយកមនុស្សដោយមានគោលដៅ ។<br>- មាត្រា ២០ LSHTSE ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស ។<br>- មាត្រា ២៥៣ ក្រមព្រហ្មទណ្ឌ ការចាប់ឃុំខ្លួន ឬការបង្ខាំងទុកដោយមិនស្របច្បាប់ (មាត្រា ២១ LSHTSE) ។<br>- មាត្រា ៣៣៧ ក្រមព្រហ្មទណ្ឌ អំពើបង្អត់អាហារ ឬការថែទាំចំពោះអនីតិជនអាយុក្រោម ១៥ឆ្នាំ ។ | - មាត្រា ១៤ អនុក្រឹត្យលេខ ៥៧ RA នឹងទទួលបន្ទុកលើការបណ្តុះបណ្តាលពលករអំពីប្រព័ន្ធការងារ ទំនៀមទម្លាប់ប្រពៃណី និងច្បាប់ជាមូលដ្ឋានរបស់ប្រទេសទទួល ។<br>- មាត្រា ៣ អនុក្រឹត្យលេខ ៣៨ កិច្ចសន្យាមួយមានសុពលភាព លុះត្រាតែកិច្ចសន្យានោះមានកម្មវត្ថុជាក់លាក់ អាចអនុវត្តបាន **ស្របច្បាប់** និងស្របជាមួយនឹងសណ្តាប់ធ្នាប់សាធារណៈ និងប្រពៃណីល្អ ។<br>- មាត្រា ៥ អនុក្រឹត្យលេខ ៣៨ កិច្ចសន្យាទាំងឡាយនឹងត្រូវចាត់ទុកជាមោឃៈ នៅពេលដែលខុសច្បាប់ ។<br>- មាត្រា ១ និង ៣ ប្រកាសលេខ១០៨ RA ត្រូវទទួលខុសត្រូវលើការបណ្តុះបណ្តាលពលករអំពីប្រព័ន្ធការងារ ទំនៀមទម្លាប់ប្រពៃណី និងច្បាប់ជាមូលដ្ឋានរបស់ប្រទេសដែលពួកគេនឹងបម្រើការងារ ។<br>- មាត្រា ៩ ICCPR មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាព និងសន្តិសុខ ។<br>- មាត្រា ៧ ICCPR គ្មានជនណាម្នាក់ត្រូវទទួលរងទារុណកម្ម ឬការមើលងាយឡើយ ។ |

| ដំណាក់កាលនៃការជ្រើសរើស/ចំណាកស្រុក | ច្បាប់ព្រហ្មទណ្ឌ | ច្បាប់រដ្ឋប្បវេណី |
|---|---|---|
| ការឆ្លងកាត់/ការមកដល់នៅក្នុងប្រទេសទទួល | - មាត្រា ៣៧៧ ក្រមព្រហ្មទណ្ឌ និយមន័យនៃការបោកបន្លំ ។<br>- មាត្រា ៦២៦ ក្រមព្រហ្មទណ្ឌ ធាតុផ្សំនៃការក្លែងបន្លំ ។<br>- មាត្រា ៦២៨ ក្រមព្រហ្មទណ្ឌ ការប្រើប្រាស់ឯកសារក្លែងបន្លំ ។<br>- មាត្រា៦២៩ ក្រមព្រហ្មទណ្ឌ ការក្លែងបន្លំឯកសារសាធារណៈ ។<br>- មាត្រា ៦៣០ ក្រមព្រហ្មទណ្ឌ ការប្រើប្រាស់ឯកសារសាធារណៈក្លែងបន្លំ ។<br>- មាត្រា ៦៣១ ក្រមព្រហ្មទណ្ឌ ការផ្ដល់ឯកសារដោយក្លែងបន្លំ ។<br>- មាត្រា ៦៣៦ ក្រមព្រហ្មទណ្ឌ ការប្រើប្រាស់លិខិតបញ្ជាក់ក្លែងក្លាយ ឬបន្លំ ។<br>- មាត្រា ៦៣៧ ក្រមព្រហ្មទណ្ឌ ការទទួលសំណូកដោយជនដែលមានសិទ្ធិចេញឯកសារក្លែងបន្លំ ។ | - អនុក្រឹត្យលេខ៣៩ (ឆ្នាំ២០០៩) លិខិតឆ្លងដែនសម្រាប់ពលករចំណាកស្រុក ។<br>- ប្រទេសថៃ : ច្បាប់អន្តោប្រវេសន៍ ព.ស. ២៥២២ ។<br>- ប្រទេសម៉ាឡេស៊ី : ច្បាប់អន្តោប្រវេសន៍ ១៩៥៩/៦៣ ។ |
| លក្ខខណ្ឌការងារនៅក្នុងប្រទេសទទួល | - មាត្រា ២៧៤ ក្រមព្រហ្មទណ្ឌ ការដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌការងារ ដែលមិនសមស្របនឹង | - មាត្រា ៩ អនុក្រឹត្យលេខ ៥៧ លក្ខខណ្ឌជាក់លាក់នៃកិច្ចសន្យាការងារ ។<br>- មាត្រា ១០ អនុក្រឹត្យលេខ ៥៧ ពលករត្រូវតែមានសិទ្ធិឈប់សម្រាក ១,៥ថ្ងៃក្នុងមួយខែ ដោយ RA ជា |

| ដំណាក់កាលនៃការជ្រើសរើស/ចំណាកស្រុក | ច្បាប់ព្រហ្មទណ្ឌ | ច្បាប់រដ្ឋប្បវេណី |
|---|---|---|
| | សេចក្ដីថ្លៃថ្នូររបស់មនុស្ស ។<br>- មាត្រា ៣៣៩ ក្រមព្រហ្មទណ្ឌ ការដាក់អនីតិជននៅក្នុងលក្ខខណ្ឌការងារ ដែលបង្កគ្រោះថ្នាក់ដល់សុខភាព ។ | អ្នកចេញការចំណាយ ។<br>- មាត្រា ១១ អនុក្រឹត្យលេខ ៥៧ កិច្ចសន្យាការងារមិនត្រូវលើសពី ២ឆ្នាំឡើយ ។<br>- មាត្រា ៧ អនុក្រឹត្យលេខ ៣៨ ប្រសិនបើកិច្ចសន្យាមួយកើតឡើងដោយសារកំហុស ការបង្ខិតបង្ខំ ឬការក្លែងបន្លំ កិច្ចសន្យានោះពុំមានសុពលភាពឡើយ ។<br>- មាត្រា ១០ អនុក្រឹត្យលេខ ៣៨ ការក្លែងបន្លំ គឺជាមូលហេតុសម្រាប់ការធ្វើមោឃភាពកិច្ចសន្យា នៅពេលមានអំពើបោកបន្លំ ភាពមិនស្មោះត្រង់ ឬការផ្ដល់ព័ត៌មានក្លែងបន្លំ ដែលប្រព្រឹត្តដោយភាគីមួយនៃកិច្ចសន្យា ដែលប្រសិនបើគ្មានអំពើបែបនេះទេ ភាគីម្ខាងទៀតនឹងមិនចុះកិច្ចសន្យាជាមួយឡើយ ។<br>- ប្រទេសថៃ : ច្បាប់ស្ដីពីការការពារពលករ ព.ស. ២៥៤១ ។<br>- MoU ជាមួយប្រទេសថៃ ស្ដីពីកិច្ចសហប្រតិបត្តិការលើការងាររបស់ពលករ (ឆ្នាំ២០០៣)<br>- ប្រទេសម៉ាឡេស៊ី : ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៥៥ ។<br>- នីតិវិធីជ្រើសរើសពលរដ្ឋខ្មែរឱ្យធ្វើការងារ នៅក្នុងប្រទេសម៉ាឡេស៊ី (ឆ្នាំ១៩៩៨) |
| **ការធ្វើមាតុភូមិនិវត្តន៍** | | - មាត្រា ១៨ អនុក្រឹត្យលេខ ៥៧ RA នឹងជូនដំណឹងដល់ក្រសួងក្នុងរយៈពេល ៤៥ថ្ងៃ នៅមុនពេលដែលពលករត្រូវធ្វើមាតុភូមិនិវត្តន៍ ហើយ RA និងក្រសួងត្រូវរៀបចំកាលបរិច្ឆេទសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ។<br>- មាត្រា ៧ អនុក្រឹត្យលេខ ៣៨ ប្រសិនបើកិច្ចសន្យាមួយកើតឡើងដោយសារកំហុស ការបង្ខិតបង្ខំ ឬការក្លែងបន្លំ កិច្ចសន្យានោះពុំមានសុពលភាពឡើយ ។ |

| ដំណាក់កាលនៃការជ្រើសរើស/ចំណាកស្រុក | ច្បាប់ព្រហ្មទណ្ឌ | ច្បាប់រដ្ឋប្បវេណី |
|---|---|---|
| | | - មាត្រា ១០ អនុក្រឹត្យលេខ ៣៨ ការក្លែងបន្លំ គឺជាមូលហេតុសម្រាប់ការធ្វើមោឃភាពកិច្ចសន្យា នៅពេលមានអំពើបោកបន្លំ ភាពមិនស្មោះត្រង់ ឬការផ្តល់ព័ត៌មានក្លែងបន្លំ ដែលប្រព្រឹត្តដោយភាគីមួយនៃកិច្ចសន្យា ដែលប្រសិនបើគ្មានអំពើបែបនេះទេ ភាគីម្ខាងទៀតនឹងមិនចុះកិច្ចសន្យាជាមួយឡើយ ។<br>- អនុក្រឹត្យលេខ ១៦២ — គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។<br>- MoU ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សក្នុងមហាអនុតំបន់ទន្លេមេគង្គ (ឆ្នាំ២00៤) |
| បណ្តឹង : នីតិវិធី និងដំណោះស្រាយផ្លូវច្បាប់ | - មាត្រា ៤ ក្រមព្រហ្មទណ្ឌ គោលការណ៍នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល<br>- មាត្រា ៣៧២ ក្រមព្រហ្មទណ្ឌ ការគំរាមកំហែងរកប្រយោជន៍<br>- មាត្រា៣៨៣ ក្រមព្រហ្មទណ្ឌ ការកេងប្រយោជន៍ពីភាពទន់ខ្សោយ | - មាត្រា ៧ អនុក្រឹត្យលេខ ៥៧ ប្រាក់ធានា ១00.000ដុល្លារសហរដ្ឋអាមេរិក ដើម្បីផ្តល់សំណងដល់ពលករ ក្នុងករណីដែល RA មិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃកិច្ចសន្យា ។<br>- មាត្រា ២0 អនុក្រឹត្យលេខ ៥៧ RAs ដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស ដោយរំលោភលើអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ។<br>- មាត្រា ១៩ អនុក្រឹត្យលេខ ៣៨ នៅក្រោយការជូនដំណឹង ភាគីមិនសុខចិត្ត ឬជនណាម្នាក់ដែលមានផលប្រយោជន៍ស្របច្បាប់នៅក្នុងបណ្តឹង អាចប្តឹងដើម្បីលុបកិច្ចសន្យាក្នុងរយៈពេលយ៉ាងយូរបំផុត ១២ ខែ ។<br>- មាត្រា ៣៤៩ ក្រមរដ្ឋប្បវេណី ការបំពានកាលៈទេសៈ : ក្នុងករណីដែលភាគីមួយប្រើប្រាស់ស្ថានភាពសេដ្ឋកិច្ច ឬសង្គមរបស់ខ្លួន ដើម្បីកុំឱ្យភាគីម្ខាងទៀតអាចជំទាស់តវ៉ានឹងការធ្វើកិច្ចសន្យា ភាគីម្ខាងទៀតនេះអាចលុបចោលកិច្ចសន្យានោះបាន ។ |

## **ឯកសារយោង**

**ច្បាប់អន្តរជាតិ**

***សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ***

មហាសន្និបាតអង្គការសហប្រជាជាតិ *ប្រកាសសាកលស្ដីពីសិទ្ធិមនុស្ស* ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ។

មហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ប្រឆាំងស្ត្រី* ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ ។

មហាសន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ។

មហាសន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌* (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាប្រឆាំងឧក្រិដ្ឋកម្មចាត់តាំងអន្តរជាតិ* (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាស្ដីពីសិទ្ធិកុមារ* (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *ពិធីសារទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មចាត់តាំងអន្តរជាតិ* (ឆ្នាំ២០០០) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាស្ដីពីការការពារសិទ្ធិពលករចំណាកស្រុក និងសមាជិកគ្រួសារ* (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩០) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *ពិធីសារប្រឆាំងការរត់ពន្ធជនចំណាកស្រុកតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស* (ឆ្នាំ២០០០) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *ពិធីសារស្ម័គ្រចិត្តបំពេញបន្ថែមលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ ស្ដីពីការលក់ដូរកុមារ ពេស្យាចារកុមារ និងអំពើរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ* (ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០០) ។

មហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ និងស្ថាប័ន និងការអនុវត្តដែលស្រដៀងទៅនឹងទាសភាព* (ឆ្នាំ១៩៥៦) ។

អង្គការពលកម្មអន្តរជាតិ *អនុសញ្ញាស្តីពីពលកម្មដោយបង្ខំ (លេខ ២៩)* ។

អង្គការពលកម្មអន្តរជាតិ *អនុសញ្ញាស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ (លេខ ១០៥)* ។

អង្គការពលកម្មអន្តរជាតិ *អនុសញ្ញាស្តីពីអាយុអប្បបរមា (លេខ ១៣៨)* ។

អង្គការពលកម្មអន្តរជាតិ *អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (លេខ ១៨២)* ។

**ច្បាប់តំបន់/ទ្វេភាគី**

ប្រកាសអាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករចំណាកស្រុក (ឆ្នាំ២០០៧) ។

MoU ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (ឆ្នាំ២០០៤) ។

ប្រកាសអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ឆ្នាំ២០០៤) ។

MoU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរកុមារ និងស្ត្រី និងជួយជនរងគ្រោះនៃអំពើជួញដូរ (ឆ្នាំ២០០៣) ។

MoU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការលើការងាររបស់ពលករ (ឆ្នាំ២០០៣) ។

សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីបត្យាប័ន (ឆ្នាំ១៩៩៨) ។

នីតិវិធីជ្រើសរើសសម្រាប់ពលរដ្ឋកម្ពុជាដែលធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី (ឆ្នាំ១៩៩៩) ។

**ច្បាប់កម្ពុជា**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ វិសោធនកម្ម) ។

ច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧) ។

ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) ។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៩) ។

អនុក្រឹត្យលេខ ៣៨ ស្តីពីច្បាប់ស្តីពីកិច្ចសន្យា និងសំណងផ្សេងៗ (ឆ្នាំ១៩៨៨) ។

អនុក្រឹត្យលេខ ៥៧ ស្តីពីការនាំពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស (ឆ្នាំ១៩៩៥) ។

អនុក្រឹត្យលេខ ៧០ ស្តីពីការបង្កើតគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅក្រៅប្រទេស (ឆ្នាំ២០០៦) ។

អនុក្រឹត្យលេខ ១៩៥ ស្តីពីការចេញលិខិតឆ្លងដែនឱ្យពលករចំណាកស្រុកខ្មែរ (ឆ្នាំ២០០៨) ។

អនុក្រឹត្យលេខ១៦២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

អនុក្រឹត្យលេខ ៦៧ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិដើម្បីការងារ និងពលកម្ម (ឆ្នាំ២០០៩) ។

អនុក្រឹត្យលេខ ៣៩ ស្តីពីការចេញលិខិតឆ្លងដែនធម្មតាឱ្យពលករខ្មែរដែលទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស (ឆ្នាំ២០០៩) ។

ប្រកាសលេខ ១០៨ ស្តីពីការអប់រំអំពីមេរោគអេដស៍/ជំងឺអេដស៍ ចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិការងារសម្រាប់ពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស (ឆ្នាំ២០០៦) ។

ប្រកាសលេខ ០១២ ស្តីពីការបង្កើតក្រុមការងារចំណាកស្រុកដើម្បីការងារ (ឆ្នាំ២០០៧) ។

**ច្បាប់កម្ពុជា : គោលការណ៍ណែនាំ គោលនយោបាយ និងសេចក្តីណែនាំ**

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជា (២០០២) ។

ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា *សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧* ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧ ។

កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំស្តីពីការអនុវត្ត និងកិច្ចសហប្រតិបត្តិការ រវាងស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងករណីជួញដូរមនុស្ស (ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៧) ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា *គោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស* (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩) គោលនយោបាយលេខ០៦២ស.អ.យ. រាជធានីភ្នំពេញ ។

ក្រសួងមហាផ្ទៃ *សេចក្តីណែនាំស្តីពីការអនុវត្តប្រតិបត្តិការសង្គ្រោះជនរងគ្រោះនៃអំពើជួញដូរមនុស្សនិង/ឬការកេងប្រវ័ញ្ចផ្លូវភេទនៅតាមកន្លែងមុខសញ្ញា* (ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០) សេចក្តីណែនាំលេខ ០០៩ រាជធានីភ្នំពេញ ។

ព្រះរាជាណាចក្រកម្ពុជា *គោលនយោបាយស្តីពីចំណាកស្រុកដើម្បីការងារសម្រាប់កម្ពុជា* (MOLVT/ILO ខែមិថុនា ឆ្នាំ២០១០) ។

លិខិតរបស់លោក សេង សក្ដា (លេខ ២៦៤៧) ជូននាយកទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា អំពីការណែនាំស្តីពីការជ្រើសរើស បណ្តុះបណ្តាល ផ្ញើរ និងគ្រប់គ្រងពលករខ្មែរដែលទៅធ្វើការនៅក្រៅប្រទេស (ឆ្នាំ២០១០) ។

**ច្បាប់មិនមែនជាច្បាប់កម្ពុជា**

**ច្បាប់របស់ប្រទេសថៃ**

ច្បាប់អន្តោប្រវេសន៍ ព.ស. ២៥២២ ។

ច្បាប់ការពារការងារ ព.ស. ២៥៤១ (ឆ្នាំ១៩៩៨) ។

បទបញ្ជាលេខ ២៨២/២៥៥៣ ប្រកាសលុបចោលបទបញ្ជា (ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០) របស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី លេខ២៦៩/២៥៥៣ : ស្តីពីការបង្កើតមជ្ឈមណ្ឌលបង្ក្រាប ចាប់ខ្លួន និងផ្តន្ទាទោសពលករបរទេស ដែលធ្វើការដោយលួចលាក់ និងដំណើរការជួញដូរមនុស្ស ។

**ច្បាប់របស់ប្រទេសម៉ាឡេស៊ី**

ច្បាប់ការងារ (ឆ្នាំ១៩៥៥) ។

ច្បាប់អន្តោប្រវេសន៍ (ឆ្នាំ១៩៥៩/៦៣) ។

**សៀវភៅ**

សមាគមច្បាប់ប្រៀបធៀបនៃកម្ពុជា *សៀវភៅប្រចាំឆ្នាំស្តីពីការសិក្សាច្បាប់ប្រៀបធៀបនៅកម្ពុជា* (ខែមីនា ឆ្នាំ២០១០) IL Virtue Unions Publisher ហុងកុង ។

Kirst-Ashman, K, *ឥរិយាបថមនុស្ស សហគមន៍ អង្គការ និងក្រុមនៅក្នុងបរិស្ថានម៉ាក្រូសង្គម* (ឆ្នាំ២០០៨) Thomson Learning Inc. ។

គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក *ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់អាស៊ី : មគ្គុទ្ទេសក៍ស្តីពីលិខិតូបករណ៍អន្តរជាតិ និងតំបន់* (ឆ្នាំ២០០៣) ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ ។

**របាយការណ៍**

ច័ន្ទ សុផល "របាយការណ៍ស្តីពីការគ្រប់គ្រង គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិសម្រាប់ចំណាកស្រុកដើម្បីការងារ នៅក្នុងប្រទេសកម្ពុជា" ឯកសារការងាររបស់ ILO ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក (ខែឧសភា ឆ្នាំ២០០៩ ILO ជប៉ុន) ។

Chen Chen Lee "ការជ្រើសរើសពលករដែលមានលក្ខណៈកេងប្រវ័ញ្ចនៅក្នុងប្រទេសកម្ពុជា : តួនាទី និងការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសពលករឯកជន" (ឆ្នាំ២០០៧ ILO IPEC-TICW) ។

Commit "ការសិក្សាអំពីការជ្រើសរើសពលករដែលមានលក្ខណៈកេងប្រវ័ញ្ច នៅក្នុងប្រទេសកម្ពុជា" (ខែមីនា ឆ្នាំ ២០០៧) ។

HRW "ត្រូវការជំនួយ : ការរំលោភបំពានប្រឆាំងនឹងពលការិនីបម្រើការងារតាមផ្ទះ នៅក្នុងប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី" (ខែកក្កដា ឆ្នាំ២០០៤ ឆ្នាំទី១៦ ច្បាប់ចេញផ្សាយលេខ ៩(ខ)) ។

HRW របាយការណ៍ពិភពលោក (ឆ្នាំ២០០៨) ។

HRW, "ឥណ្ឌូនេស៊ី/ម៉ាឡេស៊ី : បញ្ឈប់ការកេងប្រវ័ញ្ចប្រាក់ឈ្នួលរបស់ពលករបម្រើការងារតាមផ្ទះ" (ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០) ដែលអាចបើកមើលនៅលើ :
http://www.hrw.org/en/news/2010/05/10/indonesiamalaysia-end-wage-exploitation-demestic-workers ។

Lara Fergus, របាយការណ៍ ACSSA លេខ ៥ "ការជួញដូរស្ត្រីដើម្បីកេងប្រវ័ញ្ចផ្លូវភេទ" (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០០៥) ទំព័រទី៦ ។

បណ្តាញឆ្លើយតបព័ត៌មានជាយុទ្ធសាស្ត្ររបស់ UNIAP (SIREN) *ឯកសារទិន្នន័យស្តីពីការជួញដូរមនុស្សសម្រាប់ប្រទេសនៅក្នុងតំបន់មេគង្គ* (កញ្ញា ២០១០) http://www.no-trafficking.org/story_2010ht_datasheets.html បើកមើលនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

UNIFEM កម្មវិធីពង្រឹងអំណាចពលការិនីចំណាកស្រុកនៅក្នុងតំបន់អាស៊ី "ពលការិនីចំណាកស្រុកខ្មែរ : ការរកឃើញពីការសិក្សាអំពីផែនទីចំណាកស្រុក" (ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៦) ។

**អត្ថបទព័ត៌មាន**

"ពុំទាន់មានកិច្ចព្រមព្រៀងជាក់លាក់ស្តីពីពលករចំណាកស្រុកឥណ្ឌូនេស៊ីនៅក្នុងប្រទេសម៉ាឡេស៊ីនៅឡើយ" The Jakarta Globe (ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០) ដែលអាចបើកមើលនៅលើ : http://www.thejakartaglobe.com/home/no-firm-agreement-yet-on-indonesian-migrant-workers-in-malaysia/375755 ។

Brooke Lewis និង Mom Kunthear "បុគ្គលិកសម្រុកទៅធ្វើការនៅប្រទេសម៉ាឡេស៊ី" កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី ៤ ខែតុលា ឆ្នាំ២០១០) http://new.asiaviews.org/?content=153499ym32dddw4&headline=20101021150200&month=10&year=2010 បើកមើលនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

May Kunmakara "តម្រូវការពលកម្មកើនឡើង" កាសែត ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០) ។

បុគ្គលិករបស់ ភ្នំពេញប៉ុស្តិ៍ "សិក្ខាកាមរងរបួសនៅពេលរត់គេចចេញពីក្រុមហ៊ុន" ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១០) http://www.cam111.com/photonews/2010/09/06/46333.html បើកមើលនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១០ ។

"ឪពុកម្តាយបានទទួលយកប្រាក់ពីទីភ្នាក់ងារជ្រើសរើសពលករ" ឌឹ ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០) អាចបើកមើលនៅលើ : http://cambodia.world.countries.net/archives/25000 ។

អនាមិក "លិខិតឆ្លងដែនខ្មែរដែលត្បិតត្បៀតបង្កទុក្ខសោកដល់ពលករចំណាកស្រុកខ្មែរ ដែលធ្វើការនៅក្នុងប្រទេសថៃ" (ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០) http://ki-media.blogspot.com/2010/11/skimpy-cambodian-passport-caused-grief.html បើកមើលនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

"ពលករឥណ្ឌូនេស៊ីចេញ ពលករខ្មែរចូល" (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០) អាចបើកមើលនៅលើ : http://www.mmail.com.my/content/24542-indonesians-out-cambodians ។

**ផ្សេងៗ**

បញ្ជីទីភ្នាក់ងារជ្រើសរើសពលករដែលមានអាជ្ញាប័ណ្ណសម្រាប់ប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និង/ឬអារ៉ាប់/គូវ៉ែត/លីប៊ី ដែលចេញដោយនាយកដ្ឋានការងារ និងបាត្តពលិក នៃ MoLVT (ឆ្នាំ២០១០) ។

បែបបទពាក្យសុំសម្រាប់អ្នកបម្រើការងារតាមផ្ទះជាជនបរទេស នីតិវិធី និងលក្ខខណ្ឌ កថាខ័ណ្ឌទី៨ អាចបើកមើលនៅលើ : http://www.imi.gov.my/index.php/en/services/employer/373-pra ។

## <u>ឧបសម្ព័ន្ធ</u>

### ឧបសម្ព័ន្ធ ក : សេចក្តីសង្ខេបអំពីច្បាប់ជាតិ តំបន់ និងអន្តរជាតិដែលពាក់ព័ន្ធនឹងចំណាកស្រុកដើម្បីការងារ

មានច្បាប់ជាតិ តំបន់ និងអន្តរជាតិមួយចំនួន ដែលរួមគ្នាបង្កើតបានជាក្របខ័ណ្ឌគតិយុត្តិដែលអាចអនុវត្តចំពោះការធ្វើចំណាកស្រុកដើម្បីការងារនៅក្នុងប្រទេសកម្ពុជា ។ ច្បាប់ទាំងនេះត្រូវបានរាយឈ្មោះដូចខាងក្រោម រួមជាមួយនឹងសេចក្តីពណ៌នាសង្ខេបអំពីច្បាប់នីមួយៗ ។

### ច្បាប់ជាតិ

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (វិសោធនកម្មឆ្នាំ១៩៩៩) ("រដ្ឋធម្មនុញ្ញ")**

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ចែងថា ព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ប្រកាសសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ ។ មាត្រា ៣២ ចែងថា ពលរដ្ឋខ្មែរដែលរស់នៅក្រៅប្រទេស ត្រូវទទួលបានការការពារពីរដ្ឋ ។ មាត្រា ៣៨ ចែងថា ការឃុំខ្លួនជនណាម្នាក់ត្រូវធ្វើឡើងស្របទៅតាមច្បាប់ ។

**ច្បាប់ការងារ (ឆ្នាំ១៩៩៧)**

ច្បាប់ការងារផ្តល់នូវក្របខ័ណ្ឌច្បាប់ដែលអនុវត្តចំពោះកិច្ចសន្យាការងារ ដែលគ្របដណ្តប់លើការងារ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ ច្បាប់នេះមិនគ្របដណ្តប់លើការងារបម្រើតាមផ្ទះ ឬការងារដែលអនុវត្តនៅក្រៅប្រទេសឡើយ ។

**ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ចូលជាធរមាននៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១**

ក្រមរដ្ឋប្បវេណី មានគោលបំណងបម្រើជាច្បាប់រដ្ឋប្បវេណីគ្រប់ជ្រុងជ្រោយមួយ ដែលរួមបញ្ចូលនូវបទប្បញ្ញត្តិទូទៅសម្រាប់ទំនាក់ទំនងឯកជនតាមផ្លូវច្បាប់ទាំងអស់ ព្រមទាំងពង្រីកនូវច្បាប់កិច្ចសន្យា និងសំណងរដ្ឋប្បវេណីបច្ចុប្បន្នផងដែរ ។

**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ (ឆ្នាំ២០០៨) (LSHTSE)**

LSHTSE មានគោលបំណងបម្រើជាច្បាប់គ្រប់ជ្រុងជ្រោយមួយ ដែលចែងអំពីបទល្មើសជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេសកម្ពុជា ស្របទៅតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជានៅក្រោមពិធីសារ Palermo ។ ច្បាប់នេះ ចែងអំពីនិយមន័យ និងទោសប្បញ្ញត្តិដែលអនុវត្តចំពោះការជ្រើសរើស ការនាំមនុស្សឆ្លងដែន និងអំពើលក់ដូរមនុស្សដោយខុសច្បាប់សម្រាប់គោលដៅកេងប្រវ័ញ្ច ។

**ក្រមព្រហ្មទណ្ឌ ( ឆ្នាំ២០០៩)**

ក្រមព្រហ្មទណ្ឌចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១០ ។ ក្រមព្រហ្មទណ្ឌ រួមបញ្ចូលនូវមាត្រាដែលចែងអំពីការបង្ខាំងមនុស្សដោយខុសច្បាប់ ព្រមទាំងការក្លែងបន្លំឯកសារផ្លូវការ ការសូកប៉ាន់មន្ត្រី និងការក្លែងបន្លំអត្តសញ្ញាណ ។

**អនុក្រឹត្យលេខ ៣៨ ស្តីពីច្បាប់ស្តីពីកិច្ចសន្យា និងសំណងផ្សេងៗ ( ឆ្នាំ១៩៨៨)**

អនុក្រឹត្យនេះ ចែងអំពីបទប្បញ្ញត្តិជាមូលដ្ឋានសម្រាប់ច្បាប់កិច្ចសន្យានៅក្នុងប្រទេសកម្ពុជា ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌដែលកិច្ចសន្យាមួយអាចចាត់ទុកថាគ្មានសុពលភាព មោឃៈ ឬអាចធ្វើមោឃភាពបាន ក្នុងករណីដែលកិច្ចព្រមព្រៀងមួយកើតឡើងជាលទ្ធផលនៃការបោកបញ្ឆោត ។

**អនុក្រឹត្យលេខ ៥៧ ស្តីពីការនាំពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស ( ឆ្នាំ១៩៩៥)**

អនុក្រឹត្យនេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌគតិយុត្តិ ដែលអាចអនុវត្តចំពោះគ្រប់ដំណាក់កាលនៃការធ្វើចំណាកស្រុកដើម្បីការងារ ។ អនុក្រឹត្យនេះ ចែងអំពីការតម្រូវឱ្យភ្នាក់ងារជ្រើសរើសពលករសុំអាជ្ញាប័ណ្ណ និងលក្ខខណ្ឌជាមូលដ្ឋានសម្រាប់កិច្ចសន្យាការងារ ។ គួរកត់សម្គាល់ថា អាចនឹងមានលិខិតបទដ្ឋានថ្មីដែលនឹងជំនួសអនុក្រឹត្យនេះ ។

**អនុក្រឹត្យលេខ ៧០ ស្តីពីការបង្កើតគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅក្រៅប្រទេស ( ឆ្នាំ២០០៦)**

អនុក្រឹត្យនេះចែងអំពីគោលការណ៍ណែនាំសម្រាប់ការអនុវត្តប្រព័ន្ធជ្រើសរើសពលករជាសាធារណៈ ដែលនឹងអនុវត្តស្របគ្នាជាមួយនឹងទីភ្នាក់ងារឯកជន ។ អនុក្រឹត្យនេះ បង្កើតឡើងដោយទាក់ទងជាក់លាក់ទៅនឹងការបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង ។

**អនុក្រឹត្យលេខ ១៩៥ ស្តីពីការចេញលិខិតឆ្លងដែនសម្រាប់ពលករចំណាកស្រុកកម្ពុជា ( ឆ្នាំ២០០៨)**

ចែងថា ពលករចំណាកស្រុកស្របច្បាប់អាចទទួលបានលិខិតឆ្លងដែនក្នុងរយៈពេល ២០ថ្ងៃ នៅក្រោយការដាក់ពាក្យស្នើសុំ ហើយថ្លៃចំណាយត្រូវរ៉ាប់រងដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) ។

**អនុក្រឹត្យលេខ ៦៧ ស្តីពីការបង្កើត និងដាក់ឱ្យប្រតិបត្តិការទីភ្នាក់ងារជាតិសម្រាប់មុខរបរ និងការងារ ( ឆ្នាំ២០០៩)**

ពាក់ព័ន្ធនឹងច្បាប់ និងបទប្បញ្ញត្តដែលទាក់ទងនឹងការវិនិយោគ និងធុរកិច្ច ។

**អនុក្រឹត្យលេខ ៣៩ ស្តីពីការចេញលិខិតឆ្លងដែនធម្មតាដល់ពលករកម្ពុជាដែលទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ ( ឆ្នាំ២០០៩)**

ការកែប្រែអនុក្រឹត្យលេខ ១៩៥ ។

**ប្រកាសលេខ ១០៨ ស្តីពីការអប់រំអំពីមេរោគអេដស៍/ជំងឺអេដស៍ ចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិការងារ សម្រាប់ពលករកម្ពុជាដែលធ្វើការនៅក្រៅប្រទេស ( ឆ្នាំ២០០៦)**

ត្រូវបានអនុវត្តដើម្បីលើកទឹកចិត្តឱ្យក្រសួង និងទីភ្នាក់ងារជ្រើសរើសពលកររៀបចំការបណ្តុះបណ្តាលនៅមុនពេល ក្នុងពេល និងក្រោយពេលចេញដំណើរ អំពីការថែទាំសុខភាព (ជាពិសេស ទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍) និងសិទ្ធិមនុស្ស សម្រាប់ពលករចំណាកស្រុក និងគ្រួសាររបស់ពួកគេ ។

**ប្រកាសលេខ ១០២ ស្តីពីការបង្កើតក្រុមការងារចំណាកស្រុកដើម្បីការងារ (ឆ្នាំ២០០៧)**

ត្រូវបានតាក់តែងឡើងដើម្បីអនុវត្តគោលនយោបាយ និងផែនការសកម្មភាព នៅក្រោមផ្នែកចំណាកស្រុកដើម្បីការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**លិខិតរបស់លោក សេង សក្កា (លេខ ២៦៤៧) ជូននាយកទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ស្តីពីការណែនាំអំពីការជ្រើសរើស បណ្តុះបណ្តាល ផ្ញើរ និងគ្រប់គ្រងពលករកម្ពុជាដែលទៅធ្វើការនៅក្រៅប្រទេស (ឆ្នាំ២០១០)**

ផ្តល់គោលការណ៍ណែនាំបន្ថែមទៀត សម្រាប់ការជ្រើសរើសពលករកម្ពុជាស្របច្បាប់ឱ្យទៅធ្វើការនៅក្រៅប្រទេស ដោយរាប់បញ្ចូលទាំងការហាមឃាត់ការឱ្យខ្ចីប្រាក់នៅមុនពេលចេញដំណើរ និងការដាក់ទោសការក្លែងបន្លំឯកសារផ្លូវការ ។

**កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំសម្រាប់ការអនុវត្ត និងកិច្ចសហប្រតិបត្តិការ រវាងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងការគាំទ្រជនរងគ្រោះនៅក្នុងករណីនៃអំពើជួញដូរមនុស្ស (ឆ្នាំ២០០៧)**

កិច្ចព្រមព្រៀងនេះ ផ្តល់ការការពារដល់ជនរងគ្រោះចាប់ពីពេលដែលរកឃើញបទល្មើស ការសង្គ្រោះជនរងគ្រោះ និងតាមរយៈដំណើរការតាមផ្លូវតុលាការ ។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា *គោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស* (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩)**

មានគោលបំណងដើម្បីធានានិរន្តរភាពនៃការថែទាំសម្រាប់ជនរងគ្រោះ ដែលជារឿយៗ ពាក់ព័ន្ធជាមួយនឹងអ្នកផ្តល់សេវាជាច្រើន ពីមណ្ឌលជម្រក ទៅដល់អ្នកពិគ្រោះបញ្ហា និងអាជ្ញាធរអនុវត្តច្បាប់ ។

**យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជា (ឆ្នាំ២០០២)**

គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីលើកទឹកចិត្តដល់ការនាំពលករចេញទៅក្រៅប្រទេសជាផ្លូវការ ដើម្បីលើកកម្ពស់សុខុមាលភាព កែលម្អជំនាញ កាត់បន្ថយភាពគ្មានការងារធ្វើ និងបង្កើនចំណូលរដ្ឋ ។ គោលដៅរបស់ អ្រដ គឺដើម្បីតាក់តែងគោលនយោបាយ និងបទប្បញ្ញត្តិ ព្រមទាំងកិច្ចព្រមព្រៀងទ្វេភាគីសមស្រប ដែលមិនដំឡើងការចំណាយ ប៉ុន្តែ ការពារផលប្រយោជន៍របស់ពលករដែលនាំចេញទៅក្រៅប្រទេសឱ្យបានគ្រប់គ្រាន់ ។

**តំបន់/ទ្វេភាគី**

**សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីបត្យាប័ន (ឆ្នាំ១៩៩៨)**

ភាគីទាំងពីរព្រមព្រៀងគ្នាធ្វើបត្យាប័នទៅមក នូវជនដែលត្រូវបានរកឃើញនៅលើទឹកដីនៃភាគីម្ខាង ដែលត្រូវចាប់ខ្លួនដើម្បីផ្តន្ទាទោស ឬជំនុំជម្រះទោសនៅក្នុងទឹកដីរបស់ភាគីម្ខាងទៀត សម្រាប់បទល្មើសដែលត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារលើសពី ១ឆ្នាំ ។

**នីតិវិធីជ្រើសរើសពលរដ្ឋកម្ពុជាសម្រាប់ការងារនៅក្នុងប្រទេសម៉ាឡេស៊ី (ឆ្នាំ១៩៩៨)**

ចែងអំពីលក្ខខណ្ឌកិច្ចសន្យាជាក់លាក់រវាងនិយោជក និងនយោជិត និងរាប់បញ្ចូលនូវកាតព្វកិច្ចបង់ថ្លៃចំណាយលើការដឹកជញ្ជូន និងធ្វើមាតុភូមិនិវត្តន៍ និងទម្រង់កិច្ចសន្យាអប្បបរមា ។ មិនអនុវត្តចំពោះពលករដែលបម្រើការងារតាមផ្ទះឡើយ ។

**អនុស្សរណៈនៃការយោគយល់គ្នា (“MoU”) រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគដើម្បីលុបបំបាត់អំពើជួញដូរកុមារ និងស្ត្រី និងជួយជនរងគ្រោះនៃអំពើជួញដូរមនុស្ស (ឆ្នាំ២០០៣)**

ភាគីនៃ MoU នេះ ព្រមព្រៀងធ្វើកំណែទម្រង់ច្បាប់ដែលចាំបាច់ និងអនុវត្តកិច្ចប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីទប់ស្កាត់ការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ និងទទួលនូវអនីតិជនអាយុក្រោម ១៨ឆ្នាំ ដោយមធ្យោបាយបង្ខិតបង្ខំក្នុងគោលដៅកេងប្រវ័ញ្ច (ដោយរាប់បញ្ចូលទាំងការអនុវត្ត ដែលស្រដៀងទៅនឹងទាសភាព ផងដែរ) ។

**MoU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងាររបស់ពលករ (ឆ្នាំ២០០៣)**

MoU នេះ ផ្តោតទៅលើវិស័យសំខាន់ៗចំនួន ៤ : នីតិវិធីការងារត្រឹមត្រូវ កិច្ចសហប្រតិបត្តិការ ឬការធ្វើមាតុភូមិនិវត្តន៍ពលករប្រកបដោយប្រសិទ្ធភាព ការការពារពលករ និងការទប់ស្កាត់ និងវិធានការប្រឆាំងនឹងអំពើឆ្លងដែន និងជួញដូរមនុស្សខុសច្បាប់ និងការងារខុសច្បាប់ ។

**MoU ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងនឹងអំពើជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) (ឆ្នាំ២០០៤)**

ផ្នែកនៃកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយសកម្មភាពជួញដូរមនុស្សនៅក្នុង GMS គឺការបង្កើតគម្រោងសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីប្រទេសតំបន់ទន្លេមេគង្គប្រឆាំងការជួញដូរមនុស្ស (COMMIT) ។ ជាផ្នែកនៃគម្រោងផ្តួចផ្តើមនេះ បណ្តាប្រទេសនានា ដោយរាប់ទាំងកម្ពុជា និងថៃផង បានចុះហត្ថលេខាលើ MoU នេះ ដោយព្រមព្រៀងធ្វើកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនោះរាប់បញ្ចូលទាំងការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងដែនលើវិស័យអនុវត្តន៍ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះនៃអំពើជួញដូរគ្រប់រូបដែលត្រូវបានកំណត់អត្តសញ្ញាណ ។

**ប្រកាសអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ឆ្នាំ២០០៤)**

ប្រកាសដែលធ្វើឡើងដោយបណ្តាប្រទេសសមាជិកអាស៊ាន (ដោយរាប់ទាំងកម្ពុជា ថៃ និងម៉ាឡេស៊ីផង) ដើម្បីអនុវត្តកិច្ចប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្ស ជាពិសេស ដើម្បីអនុវត្តវិធានការដើម្បីការពារភាពសុចរិតនៃ

លិខិតឆ្លងដែន ឯកសារអត្តសញ្ញាណ និងឯកសារធ្វើដំណើរពីការក្លែងបន្លំ ។ បណ្តាប្រទេសទាំងនេះ ក៏ព្រមព្រៀងផងដែរដើម្បីបែងចែកជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងធានាថា ជនរងគ្រោះត្រូវបានប្រព្រឹត្តចំពោះប្រកបដោយមនុស្សធម៌ ។

**កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់អំពើជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះនៃអំពើជួញដូរ (ឆ្នាំ២០០៥)**

កិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគី ដែលចុះហត្ថលេខានៅឆ្នាំ២០០៣ ដោយរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាមនេះ ដាក់កាតព្វកិច្ចឱ្យរដ្ឋទាំងពីរអនុវត្តការបណ្តុះបណ្តាលរួមគ្នា និងចែករំលែកព័ត៌មាន និងភ័ស្តុតាង ។ មាត្រា ៧ នៃកិច្ចព្រមព្រៀង ចែងថា អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសទាំងពីរ ត្រូវធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយគ្នា ជាពិសេសនៅតាមព្រំដែន លើការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រី និងកុមារទាំងនៅក្នុងស្រុក និងឆ្លងដែន ។

**ប្រកាសរបស់អាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករចំណាកស្រុក (ឆ្នាំ២០០៧)**

ក្នុងនាមជាហត្ថលេខីនៃប្រកាសនេះ ប្រទេសកម្ពុជាបានព្រមព្រៀងកែលម្អវិធានការដើម្បីការពារ និងលើកកម្ពស់សិទ្ធិពលករចំណាកស្រុក ដោយរាប់បញ្ចូលទាំងការបង្កើនការត្រួតពិនិត្យការជ្រើសរើស និងការបណ្តុះបណ្តាល ។

**កិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពីបទដ្ឋាននីតិវិធីប្រតិបត្តិការ (SOP) សម្រាប់ការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនដែលត្រូវគេជួញដូរ រវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម (ឆ្នាំ២០០៩)**

ក្រុមការងារមួយ ត្រូវបានបង្កើតឡើងដើម្បីអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីបទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់កំណត់អត្តសញ្ញាណ និងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ។

**អនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃសាធារណរដ្ឋកូរ៉េ ស្តីពីការបញ្ជូនពលករទៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតការងារ (EPS)**

MoU នេះ ចែងអំពីបទប្បញ្ញត្តិជាក់លាក់សម្រាប់ការបញ្ជូនពលករខ្មែរទៅប្រទេសកូរ៉េខាងត្បូង ដែលនឹងទទួលបានផលប្រយោជន៍ពីប្រព័ន្ធ EPS ដែលផ្តល់ដល់ពលករចំណាកស្រុកនូវសិទ្ធិដូចគ្នានឹងពលករជាតិដែរ ដូចជា ប្រាក់ឈ្នួល ផលប្រយោជន៍ និងសិទ្ធិការងារស្មើភាពគ្នា ។

**អនុស្សរណៈនៃការយោគយល់គ្នាស្តីពីវិស័យនៃការផ្លាស់ប្តូរពលករ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលរដ្ឋគូវ៉ែត**

បង្កើតទំនាក់ទំនងរវាងកម្ពុជា និងគូវ៉ែត ស្តីពីការបញ្ជូនពលករចំណាកស្រុកទៅធ្វើការនៅប្រទេសគូវ៉ែត ។

**MoU រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសម៉ាឡេស៊ី ស្តីពីពលករចំណាកស្រុក (សំណើ)**

MoU រវាងប្រទេសកម្ពុជា និងម៉ាឡេស៊ី ត្រូវបានស្ថិតនៅលើតុចរចាចាប់តាំងពីឆ្នាំ២០០៥មកម្ល៉េះ ។ ប៉ុន្តែរហូតមក ដល់ពេលនេះ ពុំទាន់មានសេចក្តីព្រាងនៃ MoU នេះនៅឡើយ ។

**អន្តរជាតិ**

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី (ឆ្នាំ១៩៧៩) (CEDAW)**

ត្រូវបានចាត់ទុកជាច្បាប់សិទ្ធិមនុស្សរបស់ស្ត្រី CEDAW ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ឱ្យនិយមន័យអំពីអ្វីដែលជាការរើសអើងប្រឆាំងនឹងស្ត្រី និងកំណត់របៀបវារៈសម្រាប់សកម្មភាពជាតិ ដើម្បីបញ្ចប់ការរើសអើងបែបនេះ ។

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (ឆ្នាំ១៩៨៩) (CRC)**

នៅខែតុលា ឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ជជ្រ ដែលផ្តល់ការការពារដល់កុមារពីគ្រប់ទម្រង់នៃការរើសអើង និងបញ្ជាក់ថា នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ឧត្តមប្រយោជន៍របស់កុមារត្រូវទទួលបានការពិចារណាជាចម្បង ។

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារសិទ្ធិពលករចំណាកស្រុកគ្រប់រូប និងសមាជិកគ្រួសារ (ឆ្នាំ១៩៩០) (CMW)**

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញានេះ កាលពីខែកញ្ញា ឆ្នាំ២០០៤ (ប៉ុន្តែ ពុំទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឡើយទេ)[៨២] ។ អនុសញ្ញានេះ ត្រូវបានតាក់តែងឡើងដើម្បីផ្តល់ការការពារជាអន្តរជាតិដល់ពលករចំណាកស្រុក និងគ្រួសាររបស់ពួកគេនៅក្នុងដំណើរការចំណាកស្រុកទាំងមូល ចាប់តាំងពីការរៀបចំរហូតដល់ការឆ្លងកាត់ ប្រាក់ឈ្នួល និងការវិលត្រឡប់មកវិញ ។

**កតិកាសញ្ញាអន្តរជាតិនៃអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឆ្នាំ១៩៩៦) (ICCPR)**

ជាអនុសញ្ញាមួយក្នុងចំណោមអនុសញ្ញាជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ។ រដ្ឋភាគីនៃ ICCPR ធានាការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានសេរីភាព ការធ្វើដំណើរ និងសិទ្ធិមិនត្រូវបានបង្ខាំងក្នុងទាសភាព ឬសេវភាព ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ជជភរ នៅខែឧសភា ឆ្នាំ១៩៩២ ។

**កតិកាសញ្ញាអន្តរជាតិនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)**

ICESCR ចែងថា រដ្ឋភាគីត្រូវទទួលស្គាល់សិទ្ធិទទួលបានការងារសមរម្យ ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងសុខភាព ។

**អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មចាត់តាំង (ឆ្នាំ២០០០) ("អនុសញ្ញា Palermo")**

អនុសញ្ញា Palermo ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០០៥ និងចែងអំពីការផ្តន្ទាទោសការចូលរួមនៅក្នុងឧក្រិដ្ឋកម្មចាត់តាំង និងការលាងលុយកខ្វក់ដែលបានមកពីឧក្រិដ្ឋកម្ម ។ សកម្មភាពនៃការជួញដូរមនុស្ស (TIP) ត្រូវបានចាត់ទុកថាស្ថិតក្នុងជំពូកនៃឧក្រិដ្ឋកម្មចាត់តាំង ។

---

[៨២] ការចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិមួយដោយរដ្ឋភាគី គឺជាការបញ្ជាក់ថា រដ្ឋភាគីទទួលយកកាតព្វកិច្ចដាក់ជូនសន្ធិសញ្ញានេះទៅស្ថាប័នរដ្ឋដែលត្រឹមត្រូវដើម្បីធ្វើការពិនិត្យ និងផ្តល់សច្ចាប័ន ។ កាតព្វកិច្ចនេះ ក៏បញ្ជាក់អំពីការព្រមព្រៀងថា រដ្ឋភាគីនឹងជៀសវាងនូវរាល់ទង្វើណាមួយដែលផ្ទុយនឹងលក្ខខណ្ឌនៃសន្ធិសញ្ញា ។ ការផ្តល់សច្ចាប័ន គឺជាទង្វើដែលរដ្ឋភាគីផ្តល់ការអនុម័តជាស្ថាពរចំពោះសន្ធិសញ្ញានេះ ។

**ពិធីសារអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ឆ្នាំ២០០០) ("ពិធីសារ Palermo")**

បំពេញបន្ថែមទៅលើអនុសញ្ញា ភាលរមៀ ពិធីសារ Palermo ចែងអំពីបទប្បញ្ញត្តិជាក់លាក់ដែលទាក់ទងទៅនឹងការទប់ស្កាត់សកម្មភាព TIPs និងការការពារជនរងគ្រោះនៃអំពើនេះ ។ ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើពិធីសារនេះ នៅខែកក្កដា ឆ្នាំ២០០៧ ។

**ពិធីសារអង្គការសហប្រជាជាតិប្រឆាំងការរត់ពន្ធពលករតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស (ឆ្នាំ២០០០)**

ដោយបំពេញបន្ថែមលើអនុសញ្ញា Palermo និងត្រូវបានផ្ដល់សច្ចាប័នដោយប្រទេសកម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០០៥ គោលបំណងនៃពិធីសារនេះ គឺដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការរត់ពន្ធពលករ លើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងចំណោមរដ្ឋភាគី និងការពារសិទ្ធិពលករដែលត្រូវបានរត់ពន្ធ ។

**ពិធីសារតាមជម្រើសរបស់អង្គការសហប្រជាជាតិដែលបំពេញបន្ថែមលើ CRC ស្ដីពីការលក់ដូរកុមារ ពេស្យាចារកុមារ និងរូបភាព និងសម្ភារៈអាសអាភាសរបស់កុមារ (ឆ្នាំ២០០០)**

ពិធីសារតាមជម្រើសនេះ ដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័ននៅខែឧសភា ឆ្នាំ២០០២ ចែងថា រដ្ឋភាគីត្រូវហាមឃាត់ការផ្ទេរកុមារសម្រាប់គោលដៅឱ្យកុមារចូលរួមនៅក្នុងពលកម្មដោយបង្ខំ ។

**អនុសញ្ញាបំពេញបន្ថែមនៃអង្គការសហប្រជាជាតិ ស្ដីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ និងស្ថាប័ន និងការអនុវត្តដែលស្រដៀងទៅនឹងទាសភាព (ឆ្នាំ១៩៥៦)**

នៅពេលផ្ដល់សច្ចាប័នលើអនុសញ្ញានេះ ប្រទេសកម្ពុជាបានព្រមព្រៀងចាត់វាល់វិធានការច្បាប់ដែលចាំបាច់ និងអាចអនុវត្តបាន ដើម្បីលុបបំបាត់ការអនុវត្តនៃការដាក់បញ្ចាំខ្លួនដើម្បីដោះបំណុល ទាសករ និងពលកម្មកុមារ ។

**អង្គការពលកម្មអន្តរជាតិ *អនុសញ្ញាស្ដីពីពលកម្មដោយបង្ខំ (ឆ្នាំ១៩៣០) (លេខ ២៩) និងអនុសញ្ញាស្ដីពីការលុបបំបាត់ពលកម្មដោយបង្ខំ (១៩៥៧) (លេខ ១០៥)***

ដោយផ្ដល់សច្ចាប័នលើអនុសញ្ញា ILO ទាំងនេះ ប្រទេសកម្ពុជាធានាបង្ក្រាបការប្រើប្រាស់ការងារ ឬសេវា ដែលទាញយកពីជនណាម្នាក់ក្រោមការគំរាមដាក់ទណ្ឌកម្ម និងបន្ទបង្ក្រាបសកម្មភាពបែបនេះ ជាវិធីមួយនៃការប្រមូលផ្ដុំ និងប្រើប្រាស់ពលកម្មក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច ។

**អនុសញ្ញាអង្គការពលកម្មអន្តរជាតិ ស្ដីពីអាយុអប្បបរមា (ឆ្នាំ១៩៧៣) (លេខ ១៣៨) និងអនុសញ្ញាស្ដីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (ឆ្នាំ១៩៩៩) (លេខ ១៨២)**

អនុសញ្ញាលេខ ១៣៨ ចែងថា កម្ពុជាត្រូវធានាលុបបំបាត់ពលកម្មកុមារ និងពង្រឹងការអនុវត្តច្បាប់ទាក់ទងនឹងអាយុអប្បបរមា ១៥ឆ្នាំសម្រាប់ការធ្វើការងារ ។ អនុសញ្ញាលេខ ១៨២ តម្រូវឱ្យហាមឃាត់ជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាពនូវរាល់ទម្រង់នៃពលកម្មកុមារ ដោយរាប់បញ្ចូលទាំងការដាក់បញ្ចាំខ្លួនដើម្បីដោះបំណុល និងទាសភាព ផង ។

## ឧបសម្ព័ន្ធ ខ ៖ ដ្យាក្រាមមេ


ក្នុងគោលដៅកេងប្រវ័ញ្ច
មាត្រា ១៤
អនុក្រឹត្យ ៩៧
ការនាំយកចេញ/ការជ្រើសរើសដោយមិនស្របច្បាប់
មែន
មិនមែនទេ
ការនាំចេញ/ការជ្រើសរើសដោយមិនស្របច្បាប់
មិនមែនទេ
មែន
ពលករអាយុ ១៨ឆ្នាំ
ជ្រើសរើសដោយ RA
ភ្នាក់ងារជ្រើសរើស ("RA")
ការជ្រើសរើស/កិច្ចសន្យា
ការបណ្តុះបណ្តាល
គ្មានសេរីភាពក្នុងការដើរហើរ
មាត្រា ២៥៣ ក្រមព្រហ្មទណ្ឌ
មាត្រា ៥ អនុក្រឹត្យ ៣៨
មាត្រា ៩
ICCPR
ការស្នាក់នៅ
ប្រព្រឹត្តកម្មមិនល្អ
មាត្រា ៣៣៧
ក្រមព្រហ្មទណ្ឌ, មាត្រា ៧
ICCPR
ការស្នាក់នៅ
ការដឹងពីគោលដៅកេងប្រវ័ញ្ចរបស់ម្ចាស់ផ្ទះសំណាក់
LSHTSE
- មាត្រា ១៩
- មាត្រា ២០
ការធ្វើមាតុភូមិនិវត្តន៍
បណ្តឹង
លក្ខខណ្ឌការងារ
ការដឹកជញ្ជូន
លិខិតឆ្លងដែន/ទិដ្ឋាការ
ឆ្លងដែន
មិនមែនទេ
ការដឹងពីគោលដៅកេងប្រវ័ញ្ចរបស់អ្នកដឹកជញ្ជូន
មាត្រា ១៧
LSHTSE
មែន
ការដឹងអំពីការនាំយកចេញដោយមិនស្របច្បាប់របស់អ្នកដឹកជញ្ជូន
មាត្រា ១៨
LSHTSE
ពិធីសារសហប្រជាជាតិ ស្តីពីការរត់ពន្ធ
មិនមែនទេ
មែន
ថៃ
ម៉ាឡេស៊ី
មិនមែនទេ
អនុក្រឹត្យ ៣៩/១៩៩៥
ក្រមព្រហ្មទណ្ឌ